សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅ
# របស់អាជ្ញាធរជាតិសំបូរព្រៃគុក

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: កញ្ញា **ចន្ថា សុនិតា**
លោក **តាំង មុន្នីរត្ន**

សាស្ត្រាចារ្យណែនាំ
**លោកបណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **១៩**
ឆ្នាំចូលសិក្សា **២០១៥**
ឆ្នាំសរសេរសារណា **២០១៩**

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅ របស់អាជ្ញាធរជាតិសំបូរព្រៃគុក

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ចន្ថា សុនិតា**
លោក **តាំង មុន្នីរត្ន**

សាស្ត្រាចារ្យណែនាំ
**លោកបណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **១៩**
ឆ្នាំចូលសិក្សា **២០១៥**
ឆ្នាំសរសេរសារណា **២០១៩**

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋម យើងខ្ញុំជាកូនៗ សូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិបតន៍សម្តែងនូវក្តីកតញ្ញូយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **លោកឪពុកអ្នកម្តាយមានគុណទាំងទ្វេ**។ លោកទាំងពីរបានបង្កើតនូវរូបរាងកាយ រួមទាំងចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន តម្រែតម្រង់ ប្រៀនប្រដៅកូនៗឱ្យបានរីកធំធាត់មកទល់ពេលបច្ចុប្បន្ននេះ។ ដោយក្តីប្រាថ្នាចង់ឱ្យកូនៗមានអនាគតភ្លឺស្វាង លោកទាំងពីរបានខិតខំប្រឹងប្រែងពុះពារយ៉ាងសស្រាក់សស្រាំ ដើម្បីបញ្ជូនកូនៗឱ្យបានចូលសិក្សារៀនសូត្រតាំងពីថ្នាក់បឋមដល់ថ្នាក់បរិញ្ញាបត្រ ដែលនឹងបញ្ចប់នាពេលអនាគតខាងមុខនេះ។ វត្តមានដ៏ថ្លៃថ្លារបស់លោកទាំងពីរ ពិតជាគុណូបការៈដ៏មហាធំធេង គ្មានអ្វីប្រៀបផ្ទឹមបាននោះទេ នៅក្នុងជម្រៅក្រអៅដួងចិត្តកូនៗ ដោយពុំអាចនឹងបំភ្លេចបានឡើយ។

ព្រមជាមួយគ្នាផងដែរ ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ សូមថ្លែងអំណរគុណជាអនេកប្បការជូនទៅដល់ **លោក និងលោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានបំពេញតួនាទីជាឪពុកម្តាយទីពីរ ដោយផ្តល់នូវចំណេះដឹង និងបទពិសោធន៍ជាច្រើន នៅក្នុងវិស័យមួយនេះតាំងពីឆ្នាំទី ១ រហូតដល់ឆ្នាំទី ៤។ ជាពិសេស យើងខ្ញុំក៏សូមថ្លែងអំណរគុណប្រកបដោយក្តីសោមនស្សរីករាយខ្លាំងក្រៃលែងជូនដល់ **លោកបណ្ឌិត អ៊ុន សកក្កដា** ដែលបានយល់ព្រមជួយជ្រោមជ្រែងធ្វើជាប្រទីបបំភ្លឺណែនាំ កែតម្រូវ និងលើកទឹកចិត្តយើងខ្ញុំទាំងពីរ ក្នុងការរៀបរៀងកិច្ចការមួយនេះតាំងពីដើមទីរហូតដល់ចុងបញ្ចប់។ បើទោះបីការស្រាវជ្រាវ និងរៀបរៀង បានជួបប្រទះនូវការលំបាកក្តី ក៏លោកបានខិតខំប្រឹងប្រែងដឹកនាំ ពិនិត្យ កែតម្រូវយើងខ្ញុំទាំងពីរនាក់ ដែលសបញ្ជាក់ថា ពិតជាការរួមចំណែកដ៏ធំធេងដោយមិនអាចកាត់ថ្លៃបានឡើយ នៅក្នុងការជំរុញការស្រាវជ្រាវ និងរៀបរៀងកិច្ចការរបស់យើងខ្ញុំនេះឱ្យមានភាពរលូនទៅមុខ និងជោគជ័យគួរជាទីមោទនៈ។

យើងខ្ញុំក៏មិនភ្លេចផងដែរ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់ **មិត្តនិស្សិតថ្នាក់ L4A02 ជំនាន់ទី ១៩** ដែលបានរួមដំណើរនៅក្នុងការសិក្សាជាមួយគ្នាអស់រយៈពេលជិត ៤ ឆ្នាំមកនេះ។ ដំណើររួមគ្នានេះ បានផ្តល់ឱកាសឱ្យពួកយើងទាំងអស់គ្នាបានរៀនសូត្រដកស្រង់ចំណេះដឹង និងបទពិសោធន៍ពីគ្នាទៅវិញទៅមក ដែលជាអនុស្សាវរីយ៍គួរជាទីចងចាំនៅក្នុងដំណើរជីវិត។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពបួងសួងសូមឱ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទេវតា វត្ថុស័ក្តិសិទ្ធិនានានៅក្នុងលោក សូមប្រសិទ្ធិពរជ័យនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងថែរក្សាអស់លោកអ្នកទាំងឡាយឱ្យជួបប្រទះនឹងសេចក្តីសុខ សុភមង្គល សុខុដុមរមនា និងសេចក្តីចម្រើនកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅសារណាបញ្ចប់ការសិក្សាស្តីពី "**ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិសំបូរព្រៃគុក**" ដែលលោក លោកស្រី និស្សិត និងអ្នកស្រាវជ្រាវកំពុងតែអានក្នុងដៃនេះ អាចសន្មតបានថាជាសមិទ្ធិផលដំបូងបង្អស់ក្នុងសំណេរកិច្ចការស្រាវជ្រាវទំហំធំរបស់យើងខ្ញុំទាំងពីរនាក់ ដែលបានកើតចេញពីការខិតខំសិក្សាស្រាវជ្រាវ និងរៀបរៀងឡើង ដោយមានការដឹកនាំ និងណែនាំរបស់**លោកបណ្ឌិត អ៊ុន សកក្តដា** អស់រយៈពេលអស់ជិត ៥ ខែកន្លងមកនេះ។

ហេតុចម្បងដែលនាំឱ្យយើងខ្ញុំសម្រេចចិត្តជ្រើសយកប្រធានបទនេះ មកធ្វើជាសារណាបញ្ចប់ការសិក្សា គឺដោយសារយើងខ្ញុំមានក្រឡេកឃើញអំពីកត្តាចំនួន ២ ធំៗ។ កត្តាទី ១ គឺការទទួលបានភាពជោគជ័យរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរជាតិសំបូរព្រៃគុកជាសេនាធិការ ក៏ដូចជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការដាក់បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីអំឡុងពាក់កណ្តាលឆ្នាំ ២០១៧។ រីឯកត្តាទី ២ គឺភាពពុំសូវទូលំទូលាយនៃការសិក្សាស្រាវជ្រាវជុំវិញអាជ្ញាធរជាតិសំបូរព្រៃគុក មិនដូចអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរជាតិព្រះវិហារឡើយ គួបផ្សំជាមួយភាពពុំងាយស្រួលនៅក្នុងការស្វែងរកលិខិតបទដ្ឋានគតិយុត្តនានាដែលមានទំនាក់ទំនងនឹងអាជ្ញាធរនេះ នៅតាមបណ្ណាបណ្ណាល័យ បណ្ណាគារ ព្រមទាំងនៅលើបណ្តាញអ៊ិនធើណេតផងដែរ។

សៀវភៅសារណាបញ្ចប់ការសិក្សានេះ ត្រូវបានតាក់តែងឡើងដើម្បីឆ្លើយតបនឹងកត្តាទាំងពីរខាងលើ ដោយនឹងជ្រៀតខ្លួនចូលធ្វើឯកសារជំនួយស្មារតីថ្មីមួយសម្រាប់លោក លោកស្រី និស្សិត និងអ្នកស្រាវជ្រាវ ដែលមានបំណងចង់សិក្សាស្រាវជ្រាវស្វែងយល់ជុំវិញប្រធានបទស្តីពី អាជ្ញាធរជាតិសំបូរព្រៃគុក ជាពិសេសវិធានគតិយុត្តទាំងឡាយដែលមានទំនាក់ទំនងនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរនេះ រួមជាមួយនឹងនត្យូបនីយកម្មរបស់អាជ្ញាធរនេះនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបច្ចុប្បន្នអាជ្ញាធរនេះកំពុងបំពេញបេសកកម្ម តួនាទី និងភារកិច្ចយ៉ាងសកម្មនៅក្នុងរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក។

ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំទាំងពីរនាក់មានការជឿជាក់យ៉ាងប្រាកដថា សារណាបញ្ចប់ការសិក្សានេះប្រាកដច្បាស់ជាមានកង្វះខាត រួមទាំងកំហុសឆ្គង ដែលតែងតែកើតមានឡើងដោយប្រការណាមួយជាក់ជាមិនខាន។ អាស្រ័យហេតុនេះ យើងខ្ញុំរមែងមានសេចក្តីសោមនស្សរីករាយ និងសូមស្វាគមន៍ជានិច្ច នូវរាល់ការរិះគន់នៅក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រី និស្សិត និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីញ៉ាំងឱ្យសារណានេះក្លាយជាឯកសារស្រាវជ្រាវមួយ ដែលមានខ្លឹមសារត្រឹមត្រូវ និងមានអត្ថប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវនាពេលអនាគតតទៅ។

# មាតិកា

**ចំណងជើង** **ទំព័រ**

**សេចក្តីផ្តើម** ---------- ០១

**ជំពូកទី ១. ស្ថានភាពគតិយុត្តនៃអាជ្ញាធរជាតិសំបូរព្រៃគុក** ---------- ០៣

**១.១. គ្រឹះស្ថានសាធារណៈរដ្ឋបាលអាជ្ញាធរជាតិសំបូរព្រៃគុក** ---------- ០៣

១.១.១. សញ្ញាណទូទៅ ---------- ០៤

១.១.១.១. គោលបំណងនៃការបង្កើត ---------- ០៤

១.១.១.២. រដ្ឋបាល និងការគ្រប់គ្រង ---------- ០៤

១.១.១.៣. បេសកកម្ម ---------- ០៥

១.១.១.៤. តួនាទី និងភារកិច្ច ---------- ០៥

១.១.១.៥. សិទ្ធិផ្តាច់មុខ ---------- ០៦

១.១.២. ក្រុមប្រឹក្សាភិបាល ---------- ០៦

១.១.២.១. សមាសភាព ---------- ០៦

១.១.២.២. សិទ្ធិអំណាច ---------- ០៧

១.១.២.៣. ភារកិច្ច និងសិទ្ធិអនុម័ត ---------- ០៨

១.១.២.៤. កិច្ចប្រជុំ ---------- ០៨

១.១.៣. ប្រធានក្រុមប្រឹក្សាភិបាល ---------- ០៩

១.១.៣.១. សិទ្ធិអំណាច ---------- ០៩

១.១.៣.២. តួនាទី និងភារកិច្ច ---------- ០៩

១.១.៣.៣. តួនាទី និងភារកិច្ចបន្ថែម ---------- ១០

១.១.៤. មូលនិធិ និងប្រភពធនធាន ---------- ១០

១.១.៤.១. មូលនិធិ ---------- ១០

១.១.៤.២. ប្រភពធនធាន ---------- ១១

**១.២. សេនាធិការនៃអាជ្ញាធរជាតិសំបូរព្រៃគុក** ---------- ១១

១.២.១. សញ្ញាណទូទៅ ---------- ១២

១.២.១.១. រចនាសម្ព័ន្ធ និងការគ្រប់គ្រង ---------- ១២

១.២.១.២. ការត្រួតពិនិត្យហិរញ្ញវត្ថុ ---------- ១២

១.២.១.៣. មុខងារ និងភារកិច្ច------------------------------------------------------ ១៣
១.២.២. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ--------------------១៤
១.២.៣. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសណ្ដាប់ធ្នាប់ -----------------------------១៦
១.២.៤. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស ១៧
១.២.៥. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ -១៨
១.២.៦. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ ---------------------១៨
១.២.៧. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថាន-----------១៩
**ជំពូកទី ២. នគរូបនីយកម្មក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក**----------------------២០
**២.១. ការកំណត់តំបន់រមណីយដ្ឋានសំបូរព្រៃគុក** ------------------------------------២០
២.១.១. សញ្ញាណទូទៅ -------------------------------------------------------------២១
២.១.១.១. គោលបំណង----------------------------------------------------------២១
២.១.១.២. ភាពចាំបាច់នៃការកំណត់ ---------------------------------------------២១
២.១.១.៣. ការការកែប្រែ -------------------------------------------------------២១
២.១.២. ការកំណត់តំបន់-------------------------------------------------------------២២
២.១.២.១. តំបន់ស្នូល -----------------------------------------------------------២២
២.១.២.២. តំបន់ទ្រនាប់---------------------------------------------------------- ២៣
២.១.២.៣. តំបន់រណប ----------------------------------------------------------២៤
**២.២. ការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក**------------------២៤
២.២.១. កិច្ចការបុរាណវិទ្យា----------------------------------------------------------២៥
២.២.២. ការគ្រប់គ្រងទេសចរ និងអ្នកស្រាវជ្រាវ ----------------------------------------២៦
២.២.៣. សំណង់ទេសចរណ៍---------------------------------------------------------- ២៧
២.២.៤. រមណីយដ្ឋានវប្បធម៌ -------------------------------------------------------២៨
២.២.៥. ការគ្រប់គ្រងធនធានធម្មជាតិ ------------------------------------------------២៨
២.២.៦. ប្រជាជន ------------------------------------------------------------------២៩
២.២.៧. វត្តអារាម ----------------------------------------------------------------- ៣០
២.២.៨. សិប្បកម្ម និងសេវាកម្ម ------------------------------------------------------ ៣០
២.២.៩. បណ្ដាញចរន្តអគ្គិសនី ------------------------------------------------------ ៣១
២.២.១០. ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន----------------------------------------- ៣១

២.២.១១. ការបណ្តុះបណ្តាលធនធានមនុស្ស ---------------------------------------- ៣១
២.២.១២. ការអភិវឌ្ឍ ---------------------------------------------------------------- ៣២
**២.៣. ដំណើរក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោក** ------------------------------------ ៣២
២.៣.១. លក្ខណៈវិនិច្ឆ័យដើម្បីចុះបញ្ជីបេតិកភណ្ឌពិភពលោក ------------------------ ៣២
២.៣.២. ដំណើរការចុះបញ្ជីនៃប្រាសាទសំបូរព្រៃគុក------------------------------------ ៣៤
២.៣.៣. កត្តាត្រូវយកចិត្តទុកដាក់------------------------------------------------------ ៣៦
**សេចក្តីសន្និដ្ឋាន** ---------------------------------------------------------------------- ៣៨
**អនុសាសន៍**------------------------------------------------------------------------------- ៣៩
**ឯកសារយោង** ----------------------------------------------------------------------------- ៤០
**ឧបសម្ព័ន្ធ**--------------------------------------------------------------------------------៤២

# សេចក្ដីផ្ដើម

យោងទៅតាមប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា រមណីយដ្ឋានសំបូរព្រៃគុក ដើមឡើយ គឺជាអតីតរាជធានីខ្មែរមួយនៃអាណាចក្រចេនឡា នាសម័យចុងសតវត្សទី ៦ ដល់ដើមសតវត្សទី ៧ នៃគ្រឹស្តសករាជ។ អតីតរាជធានីនេះត្រូវបានកសាងឡើងនៅក្នុងរាជ្យរបស់ព្រះមហាក្សត្រខ្មែរមួយអង្គព្រះនាម **ព្រះបាទឥសានវរ្ម័នទី ១** ដែលបានគ្រងរាជ្យពីឆ្នាំ ៦១៦ ដល់ឆ្នាំ ៦៣៧ នៃគ្រឹស្តសករាជ និងបានប្រសិទ្ធិនាមអតីតរាជធានីនេះថា **ឥសានបុរៈ**។ ស្ថិតនៅក្នុងអាយុកាលច្រើនជាង ១៣ សតវត្ស អតីតរាជធានីនេះបានរងនូវការបំផ្លិចបំផ្លាញដោយសារសង្គ្រាមស្ទើរតែទាំងស្រុង ជាពិសេសសង្គ្រាមនៅក្រោយឆ្នាំ ១៩៧១ ដែលធ្វើឱ្យតំបន់នេះទទួលរងគ្រោះយ៉ាងដំណំពីការទម្លាក់គ្រាប់បែក។ កន្លងផុតទៅអស់រយៈពេលជិត ៣ ទសវត្ស ក្រោយពេលសង្គ្រាមបានបញ្ចប់ ដោយមើលឃើញអំពីបញ្ហានៅចំពោះមុខ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៃរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជានីតិកាលទី ១ បានចាប់ផ្ដើមស្ដារ និងការពារអតីតរាជធានីនេះជាថ្មី ព្រមទាំងបានកំណត់តំបន់នេះថា ជារមណីយដ្ឋានសំបូរព្រៃគុកមកទល់សព្វថ្ងៃផងដែរ។

នៅឆ្នាំ ២០១៥ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានបង្កើតនូវសេនាធិការរបស់ខ្លួនមួយ ដែលមានឈ្មោះថា **អាជ្ញាធរជាតិសំបូរព្រៃគុក** និងបានប្រគល់ឱ្យអាជ្ញាធរថ្មីនេះផងដែរនូវបេសកកម្មក្នុងការការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ចាប់តាំងពីពេលនោះមកដល់បច្ចុប្បន្ននេះ។ ថ្វីត្បិតតែអាជ្ញាធរជាតិសំបូរព្រៃគុក បានដំណើរការការងាររបស់ខ្លួនអស់រយៈពេលជិត ៤ ឆ្នាំមកហើយក្ដី ក៏សិក្សាស្រាវជ្រាវនានាជុំវិញអាជ្ញាធរនេះហាក់បីពុំទាន់សំបូរបែបដូចនឹងអាជ្ញាធរដទៃឡើយ។ ផ្អែកលើការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំរយៈពេលជិត ៥ ខែនេះបានរកឃើញថា ឯកសារភាគច្រើនដែលបានស្វែងរក និងប្រទះឃើញ ភាគច្រើនគឺជាឯកសារប្រវត្តិសាស្ត្រនៃរមណីយដ្ឋានសំបូរព្រៃគុក ផ្ទុយទៅវិញឯកសារលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងអាជ្ញាធរជាតិសំបូរព្រៃគុក គឺមានតិចតួច និងមិនងាយរកឃើញនៅតាមបណ្ណាល័យ បណ្ណាគារ និងលើបណ្ដាញសង្គមនានានោះទេ។ ស្ថានភាពនេះបានក្លាយជាចំណុចរាំងស្ទះទៅដល់ការសិក្សាស្វែងយល់នានារបស់លោក លោកស្រី និស្សិត និងអ្នកស្រាវជ្រាវ ជុំវិញអាជ្ញាធរជាតិសំបូរព្រៃគុក។

តើអាជ្ញាធរជាតិសំបូរព្រៃគុកជាអ្វី? តើមានលិខិតបទដ្ឋានគតិយុត្តណាខ្លះទាក់ទងនឹងអាជ្ញាធរជាតិសំបូរព្រៃគុក? តើតាមរយៈឯកសារទាំងនេះបានចែងកំណត់យ៉ាងដូចម្ដេចខ្លះ? ហើយតើលិខិតបទដ្ឋានគតិយុត្តទាំងអស់នេះបានវិវត្តន៍ កែប្រែ ផ្លាស់ប្ដូរ និងបានធ្វើវិសោធនកម្មយ៉ាងណាខ្លះ? ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងស្វែងរកចម្លើយនៃចម្ងល់ខាងលើ ដើម្បីសម្រួលដល់ការស្វែងយល់នានារបស់លោក លោកស្រី និស្សិត និងអ្នកស្រាវជ្រាវ ជុំវិញប្រធានបទនេះ។

ប្រធានបទស្តីពី "**ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរសំបូរព្រៃគុក**" មានវិសាលភាពគ្របដណ្តប់ទៅលើដំណើរការនីតិវិធីនានានៃអាជ្ញាធរជាតិសំបូរព្រៃគុកដូចជា ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិសំបូរព្រៃគុក និងសេនាធិការរបស់ខ្លួន (សេនាធិការនៃអាជ្ញាធរនេះរួមមានអគ្គនាយកដ្ឋាន ដែលគ្រប់គ្រងលើនាយកដ្ឋានផ្សេងៗទៀត) ព្រមទាំងការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក នៅក្នុងក្របខណ្ឌច្បាប់ជាតិ ដោយគិតរាប់ចាប់ពីសម័យនីតិកាលទី ១ នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជារហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។

ការសិក្សាស្រាវជ្រាវនេះផងដែរនឹងផ្តល់នូវអត្ថប្រយោជន៍ដល់លោក លោកស្រី និស្សិត និងអ្នកស្រាវជ្រាវឱ្យបានយល់ដឹងអំពីដំណើរការនីតិវិធីនានារបស់អាជ្ញាធរជាតិសំបូរព្រៃគុក។ ចំណេះដឹងនេះផងដែរ ក៏អាចយកទៅប្រើប្រាស់ផ្សព្វផ្សាយបញ្ជ្រាបដល់ប្រជាជនទាំងអស់ទូទាំងប្រទេស ជាពិសេសប្រជាជនដែលរស់ស្ថិតនៅក្នុង និងជុំវិញតំបន់រមណីយដ្ឋានសំបូរព្រៃគុកឱ្យបានយល់ដឹងច្បាស់អំពីបេសកកម្ម និងសមត្ថកិច្ចរបស់អាជ្ញាធរសំបូរព្រៃគុក ក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ដើម្បីចៀសវាង និងបង្ការនូវការយល់ច្រឡំ ព្រមទាំងចូលរួមក្នុងការទប់ស្កាត់នូវការបោកប្រាស់ ការក្លែងបន្លំ ការរំលោភបំពានដែលកើតពីពពួកជនខិលខូចមួយចំនួនផងដែរ។

ការស្រាវជ្រាវលើប្រធានបទនេះ គឺយោងទៅលើការធ្វើអត្ថាធិប្បាយ និងពន្យល់បំភ្លឺលើលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលទាក់ទងនឹងអាជ្ញាធរជាតិសំបូរព្រៃគុក។ តាមរយៈការអត្ថាធិប្បាយ និងពន្យល់ខាងលើនេះ បានញែកសារណាបញ្ចប់ការសិក្សានេះជាជំពូកចំនួន ២ ធំៗ រួមជាមួយនឹងរចនាសម្ព័ន្ធរៀងៗខ្លួនដូចខាងក្រោមនេះ៖

- ជំពូកទី ១. ស្ថានភាពគតិយុត្តនៃអាជ្ញាធរជាតិសំបូរព្រៃគុក ដែលក្នុងជំពូកនេះត្រូវបានបែងចែកចេញជាផ្នែកចំនួន ២ គឺ ផ្នែក ១.១. ដែលបកស្រាយអំពីគ្រឹះស្ថានសាធារណៈរដ្ឋបាលអាជ្ញាធរជាតិសំបូរព្រៃគុកនាបច្ចុប្បន្នកាល និងផ្នែក ១.២. ដែលបកស្រាយអំពីសេនាធិការនៃអាជ្ញាធរជាតិសំបូរព្រៃគុក។
- ជំពូកទី ២. នគរូបនីយកម្មក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ដែលក្នុងជំពូកនេះត្រូវបានបែងចែកចេញជាផ្នែកចំនួន ២ ផងដែរគឺ ផ្នែក ២.១. ដែលបកស្រាយអំពីការកំណត់តំបន់រមណីយដ្ឋានសំបូរព្រៃគុក និងផ្នែក ២.២. ដែលបកស្រាយអំពីការរៀបចំ និងគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

# ជំពូកទី ១

# ស្ថានភាពគតិយុត្តនៃអាជ្ញាធរជាតិសំបូរព្រៃគុក

ពាក្យ "ស្ថានភាព" ត្រូវបានកំណត់និយមន័យថា ស្ថានការណ៍, ហេតុភេទ, ដំណើរទំនង, បែបបទ, ជើងការ, ដំណើរការដែលប្រព្រឹត្តទៅ[1]។ រីឯពាក្យ "គតិយុត្ត" ត្រូវបានកំណត់និយមន័យថា តាមគន្លងច្បាប់ ដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវតាមច្បាប់[2]។ តាមរយៈអត្ថន័យទាំងនេះ នាំឱ្យពាក្យ "ស្ថានភាពគតិយុត្តនៃអាជ្ញាធរជាតិសំបូរព្រៃគុក" មាននិយមន័យរួមថា ដំណើរការដែលប្រព្រឹត្តទៅតាមគន្លងច្បាប់នៃអាជ្ញាធរជាតិសំបូរព្រៃគុក។

ក្នុងជំពូកទី ១ នេះ យើងនឹងសិក្សាដោយផ្តោតសំខាន់ទៅលើការកំណត់នូវចំណុចផ្សេងៗនៃអាជ្ញាធរជាតិសំបូរព្រៃគុក ដូចមានចែងកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការបង្កើត ក៏ដូចជាការរៀបចំ និងការប្រព្រឹត្តទៅទាំងឡាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុក បូករួមទាំងសេនាធិការរបស់ខ្លួនផងដែរ។ ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីផ្តើមខាងលើ រចនាសម្ព័ន្ធនៃជំពូកនេះមានត្រូវបានបែងចែកជា ២ ផ្នែកគឺ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាជ្ញាធរជាតិសំបូរព្រៃគុក (១.១.) និងសេនាធិការនៃអាជ្ញាធរជាតិសំបូរព្រៃគុក (១.២.)។

## ១.១. គ្រឹះស្ថានសាធារណៈរដ្ឋបាលអាជ្ញាធរជាតិសំបូរព្រៃគុក

ពាក្យ "គ្រឹះស្ថានសាធារណៈរដ្ឋបាល" ត្រូវបានកំណត់និយមន័យថា គឺជានីតិបុគ្គលនៃច្បាប់សាធារណៈដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈ រដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬបច្ចេកទេស។[3]

ក្នុងក្របខណ្ឌនេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖[4]

១- មាននាមករណ៍ និងទីស្នាក់ការ

២-មានកម្មវត្ថុ ដែលកំណត់ពីប្រភេទសកម្មភាព

៣-មានក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងដោយឡែក

៤- មានថវិកាផ្ទាល់ខ្លួន

៥- មានទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាព ដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់គ្រឹះស្ថាន

---

[1] វចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត

[2] វាក្យសព្ទច្បាប់អេឡិចត្រូនិច ឬ Traju Lexicon

[3] ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, លេខ នស/រកត/១២៩៧/៩១, ៣១ ធ្នូ ១៩៩៧, មាត្រា ១ (តទៅនេះហៅថា ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១)

[4] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ២

៦- មានសមត្ថភាពចុះកិច្ចសន្យា និងប្តឹង ឬការពារនៅតុលាការ

៧-ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីទៅលើទង្វើរបស់អ្នកតំណាងស្របច្បាប់ ឬនិយោជិតរបស់ខ្លួនក្នុងពេលបំពេញការងារជូនគ្រឹះស្ថាន។

អាជ្ញាធរជាតិសំបូរព្រៃគុក ក៏ជាគ្រឹះស្ថានមួយក្នុងចំណោមគ្រឹះស្ថានជាច្រើនដទៃទៀត ដែលត្រូវបានបង្កើតឡើងដោយយោងទៅតាមលក្ខន្តិកៈនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ អាជ្ញាធរនេះត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក។

នៅក្នុងផ្នែក ១.១. ស្តីពីគ្រឹះស្ថានសាធារណៈរដ្ឋបាលអាជ្ញាធរជាតិសំបូរព្រៃគុកនេះ យើងនឹងសិក្សាជុំវិញបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងព្រះរាជក្រឹត្យខាងលើនេះ ហើយដើម្បីបង្កនូវលក្ខណៈងាយស្រួលក្នុងការសិក្សា យើងខ្ញុំបានបែងចែកផ្នែកនេះជា ៤ ចំណុចតូចៗបន្ថែមទៀត គឺ សញ្ញាណទូទៅ (១.១.១.) ក្រុមប្រឹក្សាភិបាល (១.១.២.) ប្រធានក្រុមប្រឹក្សាភិបាល (១.១.៣.) និងចំណុចចុងក្រោយគឺ មូលនិធិ និងប្រភពធនធាន (១.១.៤.)។

### ១.១.១. សញ្ញាណទូទៅ

#### ១.១.១.១. គោលបំណងនៃការបង្កើត

អាជ្ញាធរជាតិសំបូរព្រៃគុក ដែលសរសេរជាអក្សរកាត់ថា **អ.ជ.ស.ព.** គឺជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្ត មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក។ គ្រឹះស្ថានសាធារណៈនេះស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ បច្ចុប្បន្ននេះ អាជ្ញាធរជាតិសំបូរព្រៃគុកមានទីស្នាក់ការស្ថិតជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានអាសយដ្ឋាននៅមហាវិថីព្រះនរោត្តម លេខ ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

#### ១.១.១.២. រដ្ឋបាល និងការគ្រប់គ្រង

អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលជាអង្គការជាន់ខ្ពស់បំផុតនៃគ្រឹះស្ថាននេះ ហើយប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានអាជ្ញាធរជាតិសំបូរព្រៃគុកនេះតែម្តង។ អាជ្ញាធរជាតិសំបូរព្រៃគុកមានអគ្គនាយកដ្ឋានមួយ ដែលគ្រប់គ្រងទៅលើនាយកដ្ឋានផ្សេងៗទៀតចំនួន។ អាជ្ញាធរនេះមានសិទ្ធិប្រើប្រាស់ត្រាដោយឡែក និងអាចមានទីប្រឹក្សា ព្រមទាំងជំនួយការតាមការចាំបាច់។ អាជ្ញាធរជាតិសំបូរព្រៃគុកផងដែរក៏មានប្រភពធនធាន រួមជាមួយនឹងគណនីពិសេសមួយទៀតផងដែរគឺ មូលនិធិបុរាណវិទ្យាប្រាសាទសំបូរព្រៃគុក។

**១.១.១.៣. បេសកកម្ម**

អាជ្ញាធរជាតិសំបូរព្រៃគុក មានបេសកកម្មអភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ស្ដីពីការកែសម្រួលមាត្រា ៤ មាត្រា ៥ និងមាត្រា ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

**១.១.១.៤. តួនាទី និងភារកិច្ច**

អាជ្ញាធរជាតិសំបូរព្រៃគុក មានតួនាទី និងភារកិច្ចដូចតទៅ៖

- ការពារ ថែរក្សា អភិរក្ស និងលើកតម្លៃឧទ្យានបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គិតគូរនិងអនុវត្តឱ្យបានសម្រេចនូវផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកប្រកបដោយចីរភាព
- គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ទប់ស្កាត់បទល្មើសព្រៃឈើ និងអំពើអនាធិបតេយ្យ នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវការងារដែលបានកំណត់ក្នុងផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ដូចមានរៀបរាប់ខាងលើ
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្ដល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- សហការជាមួយក្រសួង ស្ថាប័ន មូលនិធិ អង្គការ សហគមន៍ជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានទិសដៅស្របនឹងសមត្ថកិច្ចរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- ចុះកិច្ចសន្យាជាមួយនឹងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលមានគម្រោងផែនការដើម្បីរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និងការផ្ដល់សេវាផ្សេងៗជាយថាហេតុ

- ចុះកិច្ចព្រមព្រៀង ស្តីពីគម្រោង ឬកម្មវិធីនានាជាមួយអង្គការជាតិ និងអន្តរជាតិ
- លើកគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីដំណើរការអាជ្ញាធរជាតិសំបូរព្រៃគុក
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់អាជ្ញាធរជាតិសំបូរព្រៃគុកជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**១.១.១.៥. សិទ្ធិផ្តាច់មុខ**

អាជ្ញាធរជាតិសំបូរព្រៃគុក គឺជាអាជ្ញាធរតែមួយគត់ដែលមានសិទ្ធិផ្តាច់មុខក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់រាល់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ ចំពោះការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេងក្រៅពីអាជ្ញាធរជាតិសំបូរព្រៃគុក ទាក់ទងទៅនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកត្រូវទុកជាមោឃៈ។

ផ្ទុយទៅវិញ អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវចូលរួមសហការជាមួយនឹងអាជ្ញាធរជាតិសំបូរព្រៃគុកក្នុងការទប់ស្កាត់ការសាងសង់ខុសច្បាប់ និងបទល្មើសផ្សេងៗដែលកើតឡើងនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

**១.១.២. ក្រុមប្រឹក្សាភិបាល**

**១.១.២.១. សមាសភាព**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ចាំបាច់ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ក្នុងនាមរបស់គ្រឹះស្ថានសម្រាប់ចាត់ចែងការងារ ក្នុងក្របខណ្ឌនៃកម្មវត្ថុរបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន។[5]

ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានកំណត់ចំនួនសមាជិកយ៉ាងតិច ០៥ (ប្រាំ) រូប និងយ៉ាងច្រើន ១១ (ដប់មួយ) រូប ដែលក្នុងនោះចាំបាច់ត្រូវមាន៖[6]

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តំណាងក្រសួងអាណាព្យាបាលបច្ចេកទេស
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី។

ពុំមានអ្វីខុសគ្នាអំពីគ្រឹះស្ថានសាធារណៈរដ្ឋបាលដទៃឡើយ អាជ្ញាធរជាតិសំបូរព្រៃគុកក៏ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដោយនៅក្នុងនោះមានសមាជិកសរុបចំនួន ១១ (ដប់មួយ) រូប រាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាលផងដែរ។ សមាសភាពទាំងនោះមានដូចតទៅ៖

[5] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ៥

[6] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ៦

- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក សមាជិក និងជាលេខាធិការ។

សមាជិកក្រុមប្រឹក្សាភិបាលមានអាណត្តិរយៈពេល ០៣ (បី) ឆ្នាំ និងអាចបន្តសារជាថ្មីបាន ចំណែកឯការបញ្ចប់អាណត្តិសមាជិកណាម្នាក់ គឺត្រូវធ្វើឡើងតាមសំណើររបស់ក្រសួងសាមី។

**បញ្ជាក់៖** សមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិសំបូរព្រៃគុកនេះ ត្រូវតែងតាំងដោយអនុក្រឹត្យ។[7] ចំណែកឯបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាល ទៅតាមសំណើរបស់ក្រុមប្រឹក្សាភិបាល។[8]

### ១.១.២.២. សិទ្ធិអំណាច

ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិស្តីពី ការអនុវត្តអាណាព្យាបាលរបស់រដ្ឋ ក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់នូវបេសកកម្មទូទៅមួយសម្រាប់ការតម្រង់ទិស និងការត្រួតពិនិត្យគ្រឹះស្ថាន។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាលមានត្រូវមានសិទ្ធិអំណាចដូចខាងក្រោម៖[9]

- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះផ្សេងៗដទៃទៀត

[7] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក, លេខ នស/រកត/០៧១៥/៨១០, ៣១ កក្កដា ២០១៥, មាត្រា ៤ (តទៅនេះហៅថា ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០)

[8] ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០, មាត្រា ៨

[9] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ៨

- សម្រេចលើចំណូល និងចំណាយប្រចាំឆ្នាំ និងលើថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- ពិនិត្យសម្រេចលើរបាយការណ៍គ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- ជម្រុញដំណើរការរបស់គណៈកម្មាធិកា និងគណៈកម្មការដែលមានគ្រោងក្នុងអនុក្រឹត្យ ស្ដីពីការបង្កើតគ្រឹះស្ថាន ឬក្នុងបទបញ្ជាផ្ទៃក្នុង ហើយចាត់ការបង្កើតគណៈកម្មការ និងគណៈកម្មការ ប្រសិនបើមានការចាំបាច់
- កំណត់នូវបែបបទធ្វើការជ្រើសរើស ការតម្លើងឋានន្តរសក្តិ ឬការផ្តល់លាភការ ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ ឬបទបញ្ជាពាក់ព័ន្ធដល់ប្រយោជន៍របស់គ្រឹះស្ថាន
- សម្រេចលើក្របខណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់គ្រឹះស្ថាន
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្ម
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ នូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត។

**១.១.២.៣. ភារកិច្ច និងសិទ្ធិអនុម័ត**

ក្រុមប្រឹក្សាភិបាលមានភារកិច្ចដឹកនាំអាជ្ញាធរជាតិសំបូរព្រៃគុក និងមានសិទ្ធិអនុម័តលើៈ

- ការតម្រង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- ការអនុញ្ញាតឱ្យប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាអន្តរជាតិទាំងឡាយ ស្របតាមនីតិវិធីជាធរមាន
- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- គម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- របាយការណ៍ប្រចាំឆ្នាំដែលប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក បានដាក់ជូន
- ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែប ដែលអាជ្ញាធរជាតិសំបូរព្រៃគុក ប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់វិធានការ និងដំណោះស្រាយបញ្ហា ដែលប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក ដាក់ជូនពិនិត្យ។

**១.១.២.៤. កិច្ចប្រជុំ**

តាមនីតិវិធីជាធរមាន ក្រុមប្រឹក្សាភិបាលត្រូវប្រជុំ ០៣ (បី) រៀងរាល់ខែម្តង តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល (កិច្ចប្រជុំសាមញ្ញ)។ ក្រៅពីនេះ ការប្រជុំអាចកើតមានឡើងក្នុងករណីតាមការចាំបាច់ បើសិនមានការស្នើសុំពីប្រធាន ឬសមាជិកយ៉ាងតិចចំនួន ១/៤ (មួយភាគបួន)

(កិច្ចប្រជុំវិសាមញ្ញ)។ ទាំងកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជន ឬអ្នកជំនាញ និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនានា មកចូលរួមក្នុងអង្គប្រជុំបានតាមការចាំបាច់ ដើម្បីជាប្រយោជន៍ដល់អាជ្ញាធរជាតិសំបូរព្រៃគុក។

### ១.១.៣. ប្រធានក្រុមប្រឹក្សាភិបាល

#### ១.១.៣.១. សិទ្ធិអំណាច

ប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិសំបូរព្រៃគុក គឺជាប្រធានអាជ្ញាធរជាតិសំបូរព្រៃគុកនេះតែម្តង។ អនុលោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ក្រុមប្រឹក្សាភិបាលអាចផ្ទេរនូវអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃរបស់គ្រឹះស្ថានទៅឱ្យប្រធានក្រុមប្រឹក្សាភិបាល ប៉ុន្តែការផ្ទេរអំណាចនេះពុំមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ។

បើទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវរក្សានូវអំណាចចំនួន ២ ប្រភេទគឺៈ[10]

ក- អំណាចដែលកំណត់ក្នុង **១.១.២.២. សិទ្ធិអំណាច** នៃ **១.១.២. ក្រុមប្រឹក្សាភិបាល** ខាងលើ ដែលជាអំណាចក្នុងសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល

ខ- អំណាចទាំងឡាយ ដែលការបែងចែកគឺអាស្រ័យទៅលើការកំណត់ដោយផ្ទាល់របស់ក្រុមប្រឹក្សាភិបាល។

#### ១.១.៣.២. តួនាទី និងភារកិច្ច

ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីជាតំណាងរបស់គ្រឹះស្ថានក្នុងការទំនាក់ទំនងជាមួយនឹងតតិយជន ព្រមទាំងមានភារកិច្ចដូចខាងក្រោមៈ[11]

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដាក់ឱ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ នូវភារកិច្ចរបស់អង្គការចំណុះនានានៃគ្រឹះស្ថាន
- បំពេញមុខតំណែងរបស់គ្រឹះស្ថាន ក្នុងកម្រិតក្របខណ្ឌចំនួនបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងដោយគោរពទៅតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក

[10] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ៩

[11] ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១, មាត្រា ១២

- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់គ្រឹះស្ថាន
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមទៅតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្ដីពីការបែងចែកអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតពីបញ្ហានេះ
- ជារួមបំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យខ្លួនតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

#### ១.១.៣.៣. តួនាទី និងភារកិច្ចបន្ថែម

ក្រៅពីតួនាទី និងភារកិច្ចដូចដែលបានរៀបរាប់នៅខាងលើ ប្រធានក្រុមប្រឹក្សាភិបាលក៏នូវមានតួនាទី និងភារកិច្ចបន្ថែមទៀតដូចខាងក្រោមៈ

- ជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធី និងការចរចាដែលពាក់ព័ន្ធទៅនឹងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ទទួលអនុវត្តរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការគ្រប់គ្រងក្នុងដំណើរការរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- ជាអាណាប័កដើមខ្សែរនៃអាជ្ញាធរជាតិសំបូរព្រៃគុក ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ
- លើកសំណើតែងតាំង និងតម្លើងឋានៈមន្ត្រី និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល
- ដឹកនាំ និងគ្រប់គ្រងសកម្មភាពការងាររបស់អាជ្ញាធរជាតិសំបូរព្រៃគុក។

### ១.១.៤. មូលនិធិ និងប្រភពធនធាន

#### ១.១.៤.១. មូលនិធិ

អាជ្ញាធរជាតិសំបូរព្រៃគុក មានគណនីពិសេសមួយ ដែលត្រូវបានបង្កើតឡើងដើម្បីប្រមូល និងទទួលយកមូលនិធិ ព្រមទាំងវិភាគទាន និងអំណោយពីសហគមន៍ជាតិ និងអន្តរជាតិ សម្រាប់ជាប្រយោជន៍ក្នុងកម្មវិធីទ្រទ្រង់ប្រាសាទសំបូរព្រៃគុក។ គណនីពិសេសនេះមានឈ្មោះថា "មូលនិធិបុរាណវិទ្យាប្រាសាទសំបូរព្រៃគុក"។

មូលនិធិប្រាសាទសំបូរព្រៃគុកនេះផងដែរ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់របស់ប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក។

#### ១.១.៤.២. ប្រភពធនធាន

អាជ្ញាធរជាតិសំបូរព្រៃគុកមានប្រភពធនធាន ផ្គត់ផ្គង់កញ្ចប់ថវិកាជាតិដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

អាជ្ញាធរជាតិសំបូរព្រៃគុក មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់ទៅតាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀតដូចជា៖

- វិភាគទានពីរដ្ឋ
- អំណោយ និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិសំបូរព្រៃគុក
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរជាតិសំបូរព្រៃគុកដូចជាបំណុល ថ្លៃឈ្នួលបានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ
- ប្រាក់កម្រៃបានមកពីប្រភពសេវាផ្សេងៗ ផ្តល់ដោយអង្គការសាធារណៈ ឬឯកជន
- កម្ចីដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិសំបូរព្រៃគុក
- ចលនវត្ថុ និងអចលនវត្ថុដែលសប្បុរសជន អង្គការជាតិ និងអន្តរជាតិប្រគល់ឱ្យ។

**បញ្ជាក់៖** គម្រោងចំណូល និងចំណាយសម្រាប់នៅឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែ កញ្ញា ជារៀងរាល់ឆ្នាំ។[12]

### ១.២. សេនាធិការនៃអាជ្ញាធរជាតិសំបូរព្រៃគុក

ក្រៅអំពីអ្វីដែលបានរៀបរាប់នៅខាងលើ អាជ្ញាធរជាតិសំបូរព្រៃគុកក៏មានអគ្គនាយកដ្ឋានមួយជាសេនាធិការផងដែរ។ អគ្គនាយដ្ឋាននេះត្រូវបានដឹកនាំដោយអគ្គនាយកចំនួន ០១ (មួយ) រូប អមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់ រីឯការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិសំបូរព្រៃគុក កំណត់ដោយអនុក្រឹត្យ[13]។ ជាក់ស្តែងអនុក្រឹត្យដែលកំពុងត្រូវបានដាក់ឱ្យប្រើប្រាស់ជាធរមាននាពេលបច្ចុប្បន្ននេះគឺ អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក។

នៅក្នុងផ្នែក ១.២. ស្តីពីសេនាធិការនៃអាជ្ញាធរជាតិសំបូរព្រៃគុកនេះ យើងនឹងសិក្សាជុំវិញរាល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុក្រឹត្យខាងលើនេះ ហើយដើម្បីបង្កនូវលក្ខណៈងាយស្រួលក្នុងការសិក្សា យើងខ្ញុំបានបែងចែកផ្នែកនេះជាចំណុចចំនួន ៧ តូចៗបន្ថែមទៀតគឺ សញ្ញាណ

[12] ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០, មាត្រា ១៧

[13] ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០, មាត្រា ១០

ទូទៅ (១.២.១.) តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (១.២.២.) តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសណ្តាប់ធ្នាប់ (១.២.៣) តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស (១.២.៤) តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ (១.២.៥) តួនាទី និងភារកិច្ចរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ (១.២.៦) ហើយនិងចំណុចចុងក្រោយគឺ តួនាទី និងភារកិច្ចរបស់នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថាន (១.២.៧)។

**១.២.១. សញ្ញាណទូទៅ**

**១.២.១.២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង**

អគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវបានដឹកនាំដោយអគ្គនាយក ០១ (មួយ) រូប និងមានអគ្គនាយកដ្ឋានរងចំនួនយ៉ាងច្រើនបំផុត ០៥ (ប្រាំ) រូប។ នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធាននាយកដ្ឋានចំនួនយ៉ាងច្រើនបំផុតពី ០៣ (បី) រូបទៅ ០៥ (ប្រាំ) រូប ហើយនាយកដ្ឋាននីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។

អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិសំបូរព្រៃគុក មាននាយកដ្ឋានចំនួន ៦ ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានសណ្តាប់ធ្នាប់
- នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស
- នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជារាស្ត្រ
- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
- នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថាន។

**បញ្ជាក់៖** អង្គការលេខរបស់អគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក មានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ។[14] ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលជាប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក។[15]

**១.២.១.២. ការត្រួតពិនិត្យហិរញ្ញវត្ថុ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ០១ (មួយ) រូប នៅអមអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក ដោយអនុលោមតាមអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ

[14] ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក (តទៅនេះហៅថា អនុក្រឹត្យលេខ ១១៧ អនក្រ.បក)

[15] អនុក្រឹត្យលេខ ១១៧ អនក្រ.បក, មាត្រា ៤

វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងតាមអង្គភាពដែលមានលក្ខណៈរដ្ឋបាល។

**១.២.១.៣. មុខងារ និងភារកិច្ច**

អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិសំបូរព្រៃគុក មានតួនាទីជាសេនាធិការជូនអាជ្ញាធរជាតិសំបូរព្រៃគុក និងមានមុខងារ និងភារកិច្ចដូចទៅះ

- សម្របសម្រួល និងរៀបចំផែនការសម្រាប់រយៈពេលខ្លី មធ្យម និងវែង ស្តីពីការអភិរក្ស និងការអភិវឌ្ឍក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- អនុវត្តផែនការនានាដើម្បីលើកតម្លៃ ជំរុញផ្សព្វផ្សាយ និងគ្រប់គ្រងការធ្វើអាជីវកម្ម និងសេវាកម្មទេសចរណ៍នៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ចាត់វិធានការបង្ការ ការពារ ថែរក្សា និងគ្រប់គ្រងប្រាសាទនានា រួមទាំងទេសភាព និងបរិស្ថានដែលនៅជុំវិញប្រាសាទទាំងនោះ
- ធ្វើការស្ទង់មើល និងធ្វើកំណាយបុរាណវិទ្យា
- ធ្វើការសិក្សា ស្រាវជ្រាវ និងចងក្រងឯកសារស្តីពីវប្បធម៌នៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងតំបន់ពាក់ព័ន្ធផ្សេងទៀត
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្តល់ជាគុណប្រយោជន៍ទៅដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរណ៍ និងផ្តល់ពត៌មានដល់ភ្នាក់ងារ និងអ្នកផ្តល់សេវាកម្មទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរៀបចំអភិវឌ្ឍតំបន់រណប (តំបន់ ៣) ឱ្យបានល្អប្រសើរ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងអំពើអនាធិបតេយ្យក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំ និងគ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធនានា ដែលបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សិក្សាវាយតម្លៃ និងផ្តល់ការអនុញ្ញាតលើគម្រោងវិនិយោគនានា នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងតាមដានការអនុវត្តគម្រោងវិនិយោគទាំងនោះ

- រៀបចំចេញលិខិតអនុញ្ញាតសាងសង់សំណង់នានា និងចាត់វិធានការចំពោះសំណង់គ្មានច្បាប់អនុញ្ញាតនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យគុណភាពលើការធ្វើអាជីវកម្ម និងសេវាកម្មនានាក្នុងគោលដៅការពារបរិស្ថាន និងអភិវឌ្ឍប្រកបដោយចីរភាព
- រៀបចំកិច្ចសន្យាជាមួយវិនិយោគិន និង/ឬសម្បទានិក ព្រមទាំងធ្វើការដោះស្រាយវាល់វិវាទទាំងឡាយ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំ ចាត់ចែង គ្រប់គ្រងនូវចំណូលចំណាយថវិកា និងទ្រព្យសម្បត្តិរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បង្កើតការងារ និងជំរុញឱ្យមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សម្របសម្រួលលើការងារទាក់ទងនឹងពិធីការ និងបដិសណ្ឋារកិច្ច ជូនគណៈប្រតិភូជាតិ និងអន្តរជាតិដែលអញ្ជើញមកទស្សនាតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពចំណូល និងចំណាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុកជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូនអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានអាជ្ញាធរជាតិសំបូរព្រៃគុកប្រគល់ជូន។

**១.២.២. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររួមមាន រដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ផែនការ សម្ភារៈបរិក្ខារ ស្ថិតិ នីតិកម្ម និងពិធីការ
- សម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាល ក្នុងក្របខណ្ឌអាជ្ញាធរជាតិសំបូរព្រៃគុកជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ព្រមទាំងទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ
- គ្រប់គ្រង និងសម្របសម្រួលការផ្តល់សេវាកម្មរដ្ឋបាលនានា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- ពិនិត្យ និងគ្រប់គ្រងការងាររបៀបរួមមាន លិខិតចេញចូល ចរាចរណ៍លិខិតផ្ទៃក្នុង និងតម្កល់ឯកសារ

- គ្រប់គ្រង និងអនុវត្តសិទ្ធិអំណាចតាមឋាននុក្រមលើបុគ្គលិកទាំងអស់របស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិសំបូរព្រៃគុក
- រៀបចំផែនការ ស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិក ព្រមទាំងធ្វើតារាងការងារដែលអគ្គនាយកដ្ឋានបានអនុវត្តកន្លងមក និងត្រូវអនុវត្តបន្តនៅពេលអនាគត
- អនុវត្តតាមតារាងកំណត់បៀវត្សរ៍ ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភ សម្រាប់ការងារនីមួយៗរបស់មន្ត្រីរាជការ និងបុគ្គលិក តាមការកំណត់របស់ប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក
- រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានា នូវកម្មវិធីស្តីពីការកំណត់តំណែងឯកទេស ការបែងចែកធនធានមនុស្ស និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការ និងបុគ្គលិក
- រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធ នូវសំណើសុំថវិកា ឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់
- តាក់តែងកិច្ចសន្យាគម្រោងវិនិយោគ និងអាជីវកម្មនានា ព្រមទាំងពិនិត្យ និងតាមដាននូវរាល់ការអនុវត្តកិច្ចសន្យា ដើម្បីធានាការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាព
- ប្រមូលប្រាក់ចំណូល និងចាត់ចែងចំណាយឱ្យមានតម្លាភាព
- រក្សាទុក និងចាត់ចែងការប្រើប្រាស់មូលនិធិ និងរូបិយវត្ថុ
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកនូវលិខិតយុត្តិការបណ្ណសារ
- គ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិសំបូរព្រៃគុក
- រៀបចំនូវបញ្ជីសារពើភណ្ឌ សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលបន្ទុកការងារថែទាំ ជួសជុលអគារការិយាល័យ គ្រឿងបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនរបស់អាជ្ញាធរជាតិសំបូរព្រៃគុក
- គ្រប់គ្រង និងផ្គត់ផ្គង់ប្រេងឥន្ធនៈ និងបរិក្ខារផ្សេងៗជូនអាជ្ញាធរជាតិសំបូរព្រៃគុក
- ពិនិត្យ និងរៀបចំការងារលទ្ធកម្មសាធារណៈ ដែលពាក់ព័ន្ធការងារផ្គត់ផ្គង់សម្ភារៈប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ព្រមទាំងសម្រាប់ការងារចាំបាច់បន្ទាន់របស់អាជ្ញាធរជាតិសំបូរព្រៃគុក
- សហការជាមួយបណ្តានាយកដ្ឋាននានានៃអាជ្ញាធរជាតិសំបូរព្រៃគុក ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- រៀបចំបទដ្ឋានគតិយុត្តនានា និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- សហការក្នុងការរៀបចំពត៌មានស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការ
- សហការ និងសម្របសម្រួលជាមួយនឹងបណ្តាក្រសួង ស្ថាប័ន អង្គទូត អង្គការជាតិ និង អង្គការអន្តរជាតិ សមាគមន៍នានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀង និងគម្រោងស្នើសុំជំនួយ ដើម្បីអភិរក្ស និងអភិវឌ្ឍ ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្តល់ជាគុណប្រយោជន៍ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានដែលស្ថិតនៅជុំវិញ ដោយអនុលោមគោលនយោបាយស្តីពី កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយនឹងរដ្ឋបាលខេត្តកំពង់ធំ និងស្ថាប័នដែលពាក់ព័ន្ធ ទទួលបន្ទុកលើពិធីការ និងមគ្គុទ្ទេសក៍ទេសចរណ៍ជូនគណៈប្រតិភូជាតិ និងអន្តរជាតិសំខាន់ៗ ដែលអញ្ជើញមករមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំផែនការផ្សព្វផ្សាយអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគក្នុងតំបន់រណប (តំបន់ ៣)
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីចំណូលចំណាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ជូនប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់អគ្គនាយកដ្ឋាន តាមរយៈអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក ជូនប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

### ១.២.៣. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសណ្តាប់ធ្នាប់

នាយកដ្ឋានសណ្តាប់ធ្នាប់មានតួនាទី និងភារកិច្ចដូចតទៅ៖

- ការពារនិងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- លើកផែនការ និងចាត់ចែងកងកម្លាំងការពារនៅតាមគោលដៅនានាដែលបានកំណត់
- អង្កេត តាមដាន និងទប់ស្កាត់សកម្មភាពល្មើសផ្សេងៗ ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឯកសារ និងបំពេញបែបបទ ដែលពាក់ព័ន្ធនឹងបទល្មើសក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់

- សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធ ដើម្បីមានវិធានការទប់ស្កាត់ចំពោះការសាងសង់ដែលគ្មានការអនុញ្ញាត ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដី ការគាស់រុករក ការលួចវត្ថុបុរាណ និងសកម្មភាពដែលបង្កឱ្យមានការខូចខាតដល់រចនាសម្ព័ន្ធប្រាសាទនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ជូន។

### ១.២.៤. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស

នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស មានតួនាទី និងភារកិច្ចដូចតទៅះ

- រៀបចំផែនការមេស្តីពីការគ្រប់គ្រង អភិរក្ស និងថែទាំប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយរួមបញ្ចូលនូវបញ្ជីស្តីពីស្ថានភាពប្រាសាទ ផែនទីចង្អុលកន្លែងគ្រោះថ្នាក់ និងស្ថានភាពនៃការអភិរក្សជាដើម
- រៀបចំកម្មវិធី និងអនុវត្តការងារអភិរក្សប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើការអង្កេតវាស់ស្ទង់ និងធ្វើកំណាយបុរាណវិទ្យា ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងចាត់វិធានការបង្ការ ឬសង្គ្រោះស្ថានីយតាមការចាំបាច់
- ស្រាវជ្រាវបេតិកភណ្ឌរូបី និងអរូបី ព្រមទាំងចងក្រងឡើងវិញនូវស្ថានភាពដើមរបស់ចម្លាក់ និងរចនាសម្ព័ន្ធប្រាសាទ
- ត្រួតពិនិត្យ និងសម្របសម្រួលលើការដ្ឋានអន្តរជាតិនៃកម្មវិធីអភិរក្សប្រាសាទ និងបុរាណវិទ្យា
- ចុះបញ្ជីសារពើភណ្ឌប្រាសាទនិងគ្រប់គ្រងតាមប្រព័ន្ធពត៌មានភូមិសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទព្រៃគុក
- រួមចំណែកក្នុងការធ្វើវិក្រឹតការ ឬបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេស
- ផ្សព្វផ្សាយអំពីតម្លៃបេតិកភណ្ឌនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដល់ប្រជាពលរដ្ឋ
- កំណត់ទីតាំងសម្រាប់ការរៀបចំពិធីផ្សេងៗក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានា ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋាន

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ជូន។

### ១.២.៥. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រមានតួនាទី និងភារកិច្ចដូចតទៅ៖

- ពិនិត្យសំណើសុំសាងសង់ និងរៀបចំលិខិតអនុញ្ញាតសាងសង់ ដោយត្រូវគោរពនូវតម្លៃបេតិកភណ្ឌ និងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានពិនិត្យការសាងសង់
- សិក្សា និងកំណត់រចនាបថនៃសំណង់ដែលអាចអនុញ្ញាតឱ្យសាងសង់ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំបែបបទធ្វើបណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លីឱ្យសមស្របជាមួយទិន្នន័យសុរិយោដី និងតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំឯកសារស្តីពីដីធ្លី ដែលស្ថិតក្នុងគម្រោងរៀបចំអភិវឌ្ឍន៍រមណីយដ្ឋានសំបូរព្រៃគុក
- រៀបចំឱ្យមានមូលដ្ឋានទិន្នន័យប្រជាសាស្ត្រ ដើម្បីវិភាគ វាយតម្លៃ និងតាមដានការវិវត្តប្រជាសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- តាមដានការប្រែប្រួលកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដើម្បីបង្កើនការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគ និងអភិវឌ្ឍទាំងឡាយក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

### ២.១.៦. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍មានតួនាទី និងភារកិច្ចដូចតទៅ៖

- សហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ក្នុងការរៀបចំ និងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- កំណត់ទិសដៅ និងផែនការអភិវឌ្ឍទេសចរណ៍ នៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ឱ្យស្របទៅនឹងគោលនយោបាយជាតិលើវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល
- ធ្វើស្ថិតិភ្ញៀវទេសចរដែលមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ជំរុញនូវការផ្សព្វផ្សាយ និងសិក្សាទីផ្សារ ដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យចូលមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយដៃគូជាតិ និងអន្តរជាតិដែលមានជំនាញក្នុងវិស័យទេសចរណ៍
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំការត្រួតពិនិត្យជាប្រចាំលើគុណភាពសេវាកម្មទេសចរណ៍ នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**១.២.៧. តួនាទី និងភារកិច្ចរបស់នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថាន**

នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថានមានតួនាទី និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងសំណល់រឹង គ្រប់គ្រងទឹក ទាំងបរិមាណនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងព្រៃឈើនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុករួមមាន ការអភិរក្ស ការថែទាំ ការដាំកូនឈើឡើងវិញ និងការកំណត់អត្តសញ្ញាណដើមឈើ
- សិក្សាពីរុក្ខជាតិ និងសត្វនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ការពារ និងលើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិដែលមានទំនាក់ទំនងនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរ
- សិក្សា និងតាមដានពត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុនៅតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

# ជំពូកទី ២
# នគរូបនីយកម្មក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក

ពាក្យ "នគរូបនីយកម្ម" ត្រូវបានកំណត់និយមន័យថា ដំណើរនៃការរៀបចំដែនដី និងកិច្ចអភិវឌ្ឍន៍ទីក្រុង ឬខេត្តនានា នៅក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅ[16]។ តាមរយៈអត្ថន័យខាងលើនេះនាំឱ្យពាក្យ "នគរូបនីយកម្មក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក" មាននិយមន័យរួមថា ដំណើរការនៃការរៀបចំដែនដី និងកិច្ចអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

ក្នុងជំពូកទី ២ នេះ យើងនឹងសិក្សាដោយផ្តោតសំខាន់ទៅលើការកំណត់នូវចំណុចផ្សេងៗនៃនគរូបនីយកម្មរបស់អាជ្ញាធរជាតិសំបូរព្រៃគុក នៅក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ដូចមានចែងកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការកំណត់ ការរៀបចំ និងការគ្រប់គ្រងទាំងឡាយក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។ ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីផ្តើមខាងលើ រចនាសម្ព័ន្ធនៃជំពូកនេះមានត្រូវបានបែងចែកជា ២ ផ្នែកគឺ ការកំណត់តំបន់រមណីយដ្ឋានសំបូរព្រៃគុក (២.១) ការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក (២.២.) និងចំណុចចុងក្រោយគឺ សមិទ្ធិផលរបស់អាជ្ញាធរជាតិសំបូរព្រៃគុក (២.៣.)។

## ២.១. ការកំណត់តំបន់រមណីយដ្ឋានសំបូរព្រៃគុក

ពាក្យ "រមណីយដ្ឋានដែលត្រូវការពារ" ត្រូវបានផ្តល់និយមន័យសំដៅទៅលើ ឧទ្យានដែលមានបុរាណវត្ថុ ឬរមណីយដ្ឋានដទៃទៀតដែលមានអត្ថប្រយោជន៍សម្រាប់បុរាណវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន ហើយព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារនេះត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ។[17]

រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ក៏បានក្លាយជារមណីយដ្ឋានការពារ យោងទៅតាមព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក។

នៅក្នុងផ្នែក ២.១. ស្តីពីការកំណត់តំបន់រមណីយដ្ឋានសំបូរព្រៃគុកនេះ យើងនឹងសិក្សាជុំវិញបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងព្រះរាជក្រឹត្យខាងលើនេះ ហើយដើម្បីបង្កនូវលក្ខណៈងាយស្រួលក្នុងការសិក្សា យើងខ្ញុំបានបែងចែកផ្នែកនេះជា ៣ ចំណុចតូចៗបន្ថែមទៀតគឺ សញ្ញាណទូទៅ (២.១.១.) និងការកំណត់ (២.១.២.)។

[16] សៀវភៅនីតិនគរូបនីយវិទ្យា របស់លោកបណ្ឌិត អ៊ុន សកក្កដា ទំព័រទី ៣០

[17] ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌, លេខ នស/រកម/០១៩៦/២៦, ២៥ មករា ១៩៩៦, មាត្រា ៦

### ២.១.១. សញ្ញាណទូទៅ

#### ២.១.១.១. គោលបំណង

ការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ជារមណីយដ្ឋានការពារ គឺមានគោលបំណង៖

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និងលើកកម្រិតតម្លៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និងអភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង។

#### ២.១.១.២. ភាពចាំបាច់នៃការកំណត់

នៅក្នុងដំណើរការនៃបេសកកម្ម តួនាទី និងភារកិច្ចរបស់ខ្លួន ដែលជាស្ថាប័នមានសមត្ថកិច្ចនៅក្នុងការការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក អាជ្ញាធរជាតិសំបូរព្រៃគុក តែងតែត្រួតពិនិត្យនូវរាល់ការអភិវឌ្ឍ ដោយគោរពទៅតាមប្លង់កំណត់តំបន់ និងការចាត់ចែងគ្រប់គ្រងតាមចំណាត់ថ្នាក់តំបន់នីមួយៗដែលត្រូវការពារ។

ចំណែកឯនៅក្នុងការអភិរក្សរាល់តំបន់នីមួយៗ ក៏មិនខុសគ្នាពីការអភិវឌ្ឍប៉ុន្មានដែរ ពោលគឺសុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របទៅតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចដែលមាននៅក្នុងប្លង់កំណត់តំបន់ និងកម្រិតសារៈសំខាន់ដោយឡែកៗ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតម្លៃកាន់តែខ្ពស់ឡើង។

តាមការលើកឡើងសបញ្ជាក់ថា ពិតជាមានភាពចាំបាច់ណាស់ ក្នុងការកំណត់តំបន់។

#### ២.១.១.៣. ការកែប្រែ

ទោះជាយ៉ាងណាក្តី បរិវេណ និងរាល់សកម្មភាពរបស់តំបន់ដូចដែលបានរៀបរាប់នៅខាងលើទាំងនេះអាចត្រូវពិនិត្យ និងកែប្រែឡើងវិញបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តភាព។

**បញ្ជាក់៖** ការកែប្រែតំបន់ និងរាល់សកម្មភាពពាក់ព័ន្ធទៅនឹងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ទៅតាមសំណើរបស់រាជរដ្ឋាភិបាល។[18]

[18] មាត្រា ៧ ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា ៥ និងមាត្រា ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក (តទៅនេះហៅថា ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨)

តាមការសិក្សាស្រាវជ្រាវ យើងបានរកឃើញថា ដើមឡើយរមណីយដ្ឋានសំបូរព្រៃគុកត្រូវបានកំណត់តំបន់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក។ ប៉ុន្តែក្រោយមកព្រះរាជក្រឹត្យថ្មីមួយ ត្រូវបានបង្កើតឡើងដើម្បីធ្វើវិសោធនកម្មព្រះរាជក្រឹត្យខាងលើ ហើយព្រះរាជក្រឹត្យថ្មីនោះគឺ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ស្ដីពីការកែសម្រួលមាត្រា ៤ មាត្រា ៥ និងមាត្រា ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក។

**បញ្ជាក់៖** ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកទាំងចាស់[19] និងថ្មី[20] មានភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យរៀងៗខ្លួន។

### ២.១.២. ការកំណត់តំបន់

#### ២.១.២.១. តំបន់ស្នូល

តំបន់ស្នូល គឺជាតំបន់មានប្រាសាទសំខាន់ជាងគេ និងជាតំបន់ឧទ្យានប្រាសាទតូចធំ រួមទាំងសម្បត្តិវប្បធម៌ បុរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដី ឬកប់ក្នុងដីកំពុងស្រាវជ្រាវ ឬពុំទាន់ស្រាវជ្រាវរកឃើញដោយអ្នកបុរាណវិទ្យា ហើយត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។

តាមលិខិតបទដ្ឋានគតិយុត្តចាស់ តំបន់ស្នូលមានផ្ទៃក្រឡាសរុបចំនួន ៣៨១.១១ ហិកតា និងត្រូវបានបែងចែកជា ០៣ (បី) តំបន់តូចៗបន្ថែមទៀតគឺ តំបន់ ក តំបន់ ខ និងតំបន់ គ ដែលជាតំបន់មានប្រាសាទសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ និងត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។ តំបន់ស្នូលត្រូវបានកំណត់ដូចខាងក្រោម៖

- តំបន់ ក គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច៖
  - A1 (504939;1423496) , B1 (504521;1423004)
  - C1 (504210;1422372) , D1 (504110;1421913)
  - E1 (504262;1421680) , F1 (504580;1421665)
  - G1 (504536;1421428) , H1 (504380;1421102)
  - I1 (504391;1420751) , J1 (504462;1420736)
  - K1 (504680;1421187) , L1 (504773;1421665)
  - M1 (505094;1421665) , N1 (505224;1421950)

[19] ព្រះរាជក្រឹត្យស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក, លេខ នស/រកត/០៣០៣/១១៦, ១១ មីនា ២០០៣, ឧបសម្ព័ន្ធ (ពីពេលនេះតទៅហៅថា ព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៣/១១៦)

[20] ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨, ឧបសម្ព័ន្ធ

- T1 (506889; 1422109) , S1 (506575;1422575)
- P1 (505365; 1422549) , Q1 (505513;1423064)
- R1 (505376; 1423437)

- តំបន់ ខ គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុចៈ
  - $A_2$ (503211;1425262) , $B_2$ (502904;1424858)
  - $C_2$ (503081;1424185) , $D_2$ (504458;1424288)
  - $E_2$ (504613;1425289)
- តំបន់ គ គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុចៈ
  - $U_3$ (502552;1421073) , $V_3$ (502045;1420962)
  - $W_3$ (501557;1423004) , $Z_3$ (503577;1423256) ។

ចំណែកឯតាមលិខិតបទដ្ឋានគតិយុត្តថ្មីវិញ តំបន់ស្នូលមានផ្ទៃក្រឡាសរុបចំនួន ១,៣៥៨.២៦ ហិកតា ប៉ុន្តែពុំមានការបែងចែកតំបន់តូចដូចជា តំបន់ ក តំបន់ ខ និងតំបន់ គ ទៀតឡើយ។ តំបន់នេះមានកំណត់នៅក្នុងនិយាមកាដូចខាងក្រោមៈ

- $A_1$ (503211;1425262) , $B_1$ (502904;1424858)
- $C_1$ (502873;1423171) , $D_1$ (501557;1423004)
- $E_1$ (502045;1420962) , $F_1$ (504536;1421428)
- $G_1$ (504380;1421102) , $H_1$ (504310;1420606)
- $I_1$ (504355;1420592) , $J_1$ (504462;1420736)
- $K_1$ (504680;1421187) , $L_1$ (504773;1421665)
- $M_1$ (505094;1421665) , $N_1$ (505224;1421950)
- $O_1$ (507688;1422128) , $P_1$ (507571;1422434)
- $Q_1$ (504458;1424288) , $R_1$ (504613;1425289) ។

#### ២.១.២.២. តំបន់ទ្រនាប់

តំបន់ទ្រនាប់ គឺជាតំបន់សម្បូរដោយសំណល់បុរាណវត្ថុ និងជាឧទ្យានបុរាណវត្ថុដែលមានបន្សល់ទុកនូវស្លាកស្នាមកប់ក្នុងដីរាក់ ឬជ្រៅ ហើយពុំទាន់រុករកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាជនជាដើម ដែលត្រូវការពារ ទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍមិនសមស្រប។

តាមលិខិតបទដ្ឋានគតិយុត្តចាស់ តំបន់ទ្រនាប់មានផ្ទៃក្រឡាសរុប ២,៩៨២.៤៥ ហិកតា។ តំបន់ទ្រនាប់ស្ថិតនៅក្រៅបរិវេណនៃតំបន់ ក តំបន់ ខ និងតំបន់ គ នៃតំបន់ស្នូល ហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុចដូចខាងក្រោមៈ

- A (502721;1426711) , B (501633;1425998)
- C (500537;1423348) , D (501733;1418978)
- E (504456;1420172) , F (505480;1420622)

- G (505567;1421717) , H (508911;1421701)
- I (508909;1422487) , J (505583;1424066)
- K (505604;1425246) ។

រីឯតាមលិខិតបទដ្ឋានគតិយុត្តថ្មី តំបន់ទ្រនាប់មានផ្ទៃក្រឡា ២,០០៩.៣០ ហិកតា។ តំបន់នេះស្ថិតនៅជុំវិញតំបន់ស្នូល ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

- A (502721;1426711) , B (501633;1425998)
- C (500537;1423348) , D (501733;1418978)
- E (504456;1420172) , F (505480;1420622)
- G (505567;1421717) , H (508911;1421701)
- I (508909;1422487) , J (505583;1424066)
- K (505604;1425246) ។

#### ២.១.២.៣. តំបន់រណប

តំបន់រណប គឺជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទម្លាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច A B C D E F G H I J K ចម្ងាយ ១,៥០០ ម៉ែត្រ។ តំបន់រណបជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឱ្យមានចីរភាព និងមានការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន។

**បញ្ជាក់៖** ទាំងនៅក្នុងលិខិតបទដ្ឋានចាស់ និងថ្មី ពុំបានចែងពីបម្រែបម្រួលនៃតំបន់រណបនេះឡើយ ពោលគឺរក្សានៅដដែល។

### ២.២. ការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក

ក្រៅពីការកំណត់តំបន់នីមួយៗដូចបានរៀបរាប់នៅខាងលើ យើងនៅមានចំណុចមួយចំនួនទៀតគឺ បែបបទ និងនីតិវិធីនៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានសំបូរព្រៃគុកនេះ។ បែបបទ និងនីតិវិធីខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ[21]។ ជាក់ស្តែងអនុក្រឹត្យដែលកំពុងត្រូវបានដាក់ឱ្យប្រើប្រាស់ជាធរមាននាពេលបច្ចុប្បន្ននេះគឺ អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

នៅក្នុងផ្នែក ២.២. ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុកនេះ យើងនឹងសិក្សាជុំវិញរាល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុក្រឹត្យខាងលើនេះ ហើយដើម្បីបង្កនូវលក្ខណៈងាយស្រួលក្នុងការសិក្សា យើងខ្ញុំបានបែងចែកផ្នែកនេះជាចំណុចចំនួន ១២ តូចៗ

[21] ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦, មាត្រា ៦

បន្ថែមទៀតគឺ កិច្ចការបុរាណវិទ្យា (២.២.១.) ការគ្រប់គ្រងទេសចរ និងអ្នកស្រាវជ្រាវ (២.២.២.) សំណង់ទេសចរណ៍ (២.២.៣.) រមណីយដ្ឋានវប្បធម៌ (២.២.៤.) ការគ្រប់គ្រងធនធានធម្មជាតិ (២.២.៥.) ប្រជាជន (២.២.៦.) វត្តអារាម (២.២.៧.) សិប្បកម្ម និងសេវាកម្ម (២.២.៨.) បណ្ដាញចរន្តអគ្គិសនី (២.២.៩.) ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន (២.២.១០.) ការបណ្តុះបណ្តាលធនធានមនុស្ស (២.២.១១.) និងចំណុចចុងក្រោយគឺ ការអភិវឌ្ឍ (២.២.១២.)។

### ២.២.១. កិច្ចការបុរាណវិទ្យា

សកម្មភាពបុរាណវិទ្យានៅរមណីយដ្ឋានក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- រៀបចំកម្មវិធីលម្អិតដើម្បីស្រង់ពត៌មានបុរាណវត្ថុ
- ធ្វើបញ្ជីសារពើភណ្ឌស្ថានីយបុរាណ ហើយបញ្ចូលទិន្នន័យនោះចូលទៅក្នុងប្រព័ន្ធពត៌មានភូមិសាស្ត្រ (Geographic Information System)
- កំណត់លក្ខណៈវិនិច្ឆ័យ និងកម្មវិធីការងារសម្រាប់សម្គាល់ស្ថានីយណាដែលជាចំណុចមានគុណប្រយោជន៍ផ្នែកបុរាណវិទ្យា នរវិទ្យា ប្រវត្តិវិទ្យា ស្ថាបត្យកម្ម និងនគរូបនីយកម្ម
- កំណត់លក្ខណៈវិនិច្ឆ័យ និងកម្មវិធីការងារសម្រាប់សម្គាល់ទេសភាពវប្បធម៌មានលក្ខណៈបរមបុរាណដែលត្រូវការពារ
- កំណត់គោលនយោបាយដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងនោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា និងអប់រំ
- រៀបចំទិសដៅ និងគំរូកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ សម្រាប់ចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា និងអប់រំ
- រៀបចំឱ្យមានអ្នកយាមល្បាត ដើម្បីថែរក្សា និងការពារស្ថានីយបុរាណ។

ក្នុងកិច្ចការពាររមណីយដ្ឋានសំបូរព្រៃគុក អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ការពារយ៉ាងមធ្យ័ត និងទប់ស្កាត់ការរំលោភបំពានបរិវេណរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ស្នូល ហើយគ្រប់គ្រងបរិវេណនោះសម្រាប់គោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬលំហែកម្សាន្ត
- រៀបចំទីតាំងយុទ្ធសាស្ត្របម្រើដល់ការងារអន្តរាគមន៍បន្ទាន់សម្រាប់ជួសជុល និងការងារអភិរក្សប្រាសាទ។

អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពនានា ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ស្ថានីយបុរាណ។

- ការពារយ៉ាងមធ្យ័ត និងលើកតម្លៃសំណល់វប្បធម៌ ព្រមទាំងសំណល់ស្ថានីយបុរាណវិទ្យាទាំងអស់ដែលស្ថិតនៅលើដី ក្នុងដី និងក្នុងទឹក។ រាល់ការជីកកកាយ ជីកយកអាចម៍ដី និងការចាក់បំពេញ ឬលុបដីត្រូវមានការពិនិត្យ និងអនុញ្ញាតពីអាជ្ញាធរជាតិសំបូរព្រៃគុក

ក្នុងករណីសិក្សាស្រាវជ្រាវ ឬប្រទះឃើញដោយចៃដន្យនូវរចនាសម្ព័ន្ធប្រាសាទ ដូចជា ខឿនប្រាសាទ តួប្រាសាទ កសិណ ស្រះបុរាណ បារាយ៍ ស្ពាន ផ្លូវបុរាណជាដើម ក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ទោះស្ថិតក្នុងតំបន់ណាក៏ដោយ ត្រូវបានកំណត់ចម្ងាយបរិវេណជុំវិញនោះតាមទំហំ និងស្ថានភាពជាក់ស្តែង និងត្រូវការពារដូចតំបន់ស្នូលដែរ។

**២.២.២. ការគ្រប់គ្រងទេសចរ និងអ្នកស្រាវជ្រាវ**

ការគ្រប់គ្រងទេសចរ និងអ្នកស្រាវជ្រាវនៅរមណីយដ្ឋានវប្បធម៌ក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- គ្រប់គ្រងការចេញ ចូលរបស់ទេសចរ អ្នកស្រាវជ្រាវ និងសាធារណជន
- រៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រនៅក្នុងការគ្រប់គ្រងសេវាកម្មទេសចរណ៍ ខ្សែទស្សនាចរកម្មវិធីវិនិយោគទេសចរណ៍
- កំណត់តម្លៃបណ្ណទស្សនា ដោយមានការពិភាក្សា ឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កំណត់តម្លៃសេវាកម្មពាណិជ្ជកម្មដូចជា ថតផ្សាយពាណិជ្ជកម្ម ពិធីជប់លៀង ពិធីសម្តែងសិល្បៈទស្សនីយភាព ថតខ្សែរភាពយន្ត សេវាកម្មដឹកជញ្ជូន និងសេវាកម្មដទៃទៀត
- ទប់ស្កាត់រាល់សកម្មភាពបង្កផលប៉ះពាល់ទៅដល់តម្លៃនៃរមណីយដ្ឋាន និងបរិស្ថានដែលបណ្តាលមកពីទេសចរ និងអ្នកស្រាវជ្រាវ រួមទាំងសាធារណជនទូទៅ
- បន្ថយផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីទេសចរទៅលើសហគមន៍
- ពិនិត្យ និងឯកភាពលើការបោះពុម្ពផ្សាយរាល់លទ្ធផលនៃការសិក្សាស្រាវជ្រាវ បុរាណវិទ្យាជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម និងនគរូបនីយកម្ម ដោយអ្នកវិទ្យាសាស្ត្រ ហើយត្រូវរក្សាជាសិទ្ធិបេតិកភណ្ឌរបស់អ្នកស្រាវជ្រាវក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ។ ក្រោយផុតអាជ្ញាយុកាលនៃសិទ្ធិបេតិកភណ្ឌនេះ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ការបោះពុម្ពផ្សាយត្រូវរក្សាគឺជាកម្មសិទ្ធិរបស់អាជ្ញាធរជាតិសំបូរព្រៃគុក សម្រាប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ។

ការគ្រប់គ្រងទេសចរក្នុងតំបន់ស្នូល អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ហាមជក់បារីនៅក្នុងតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រ និងទប់ស្កាត់រាល់សកម្មភាពដែលបង្កឱ្យមានអគ្គិភ័យ

- កំណត់ និងរៀបចំខ្សែទស្សនាតាមបែបបទ
- ដាក់ឱ្យមានជាប្រចាំនូវមន្ត្រីរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ដើម្បីផ្តល់ពត៌មានណែនាំ ថែរក្សាសន្តិសុខ គុណភាពបរិស្ថាន និងផ្តល់សេវាផ្សេងៗដល់ទេសចរ និងសាធារណៈជន
- កម្រិតចំនួនភ្ញៀវទេសចរដែលចូលទស្សនានៅតាមទីតាំងប្រាសាទនីមួយៗ ដើម្បីរក្សាគុណភាពទស្សនកិច្ច និងការពារ
- កំណត់ប្រភេទ និងល្បឿនយានយន្តដែលត្រូវអនុញ្ញាតឱ្យចេញចូលក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

ការគ្រប់គ្រងទេសចរក្នុងតំបន់ទ្រនាប់ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- ពិនិត្យ និងកម្រិតល្បឿនបើកបរ ចេញ ចូលយានយន្តគ្រប់ប្រភេទ មិនអនុញ្ញាតឱ្យរថយន្តដឹកជញ្ជូនធុនធ្ងន់ឆ្លងកាត់ និងតម្រូវឱ្យយានយន្តទាំងនោះទៅចតនៅចំណតយានជំនិះ
- កំណត់ទីតាំងទទួលភ្ញៀវទេសចរ និងចំណតយានជំនិះ
- កសាងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតសេវាសម្រាប់បម្រើឱ្យការអភិរក្ស និងការអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងតំបន់រមណីយដ្ឋាន។

### ២.២.៣. សំណង់ទេសចរណ៍

រាល់ការសាងសង់សំណង់ទេសចរណ៍នៅរមណីយដ្ឋានសំបូរព្រៃគុកក្នុងតំបន់ទាំង ៣ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរជាតិសំបូរព្រៃគុក។

រាល់សំណង់ទេសចរណ៍ក្នុងតំបន់ស្នូល អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- អនុញ្ញាតឱ្យមានសំណង់តិចបំផុត សម្រាប់បម្រើសេវាកម្មទេសចរណ៍ដូចជា តូបលក់អាហារ និងភេសជ្ជៈ ផ្លូវថ្មើរជើង បង្គន់អនាម័យ កន្លែងរង់ចាំ កន្លែងសង្គ្រោះបឋម កន្លែងផ្តល់ពត៌មានស្រាវជ្រាវ និងអភិរក្ស។ សំណង់ទាំងនោះ ជាប្រភេទសំណង់ស្រាល និងត្រូវបន្សុីជាមួយបរិស្ថាន
- កំណត់ទីកន្លែង និងរៀបចំចំណតរង់ចាំឱ្យតិចបំផុត
- រៀបចំកន្លែងសម្រាប់ភ្ញៀវទេសចរ និងសាធារណជនបានទស្សនានៅក្នុងទីតាំងកំណាយបុរាណវិទ្យា និងការងារជួសជុលប្រាសាទដែលកំពុងអនុវត្ត។

ក្នុងតំបន់ទ្រនាប់ និងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- កំណត់ទីកន្លែងជាក់លាក់ និងរៀបចំឱ្យមានចំណតយានជំនិះ
- រៀបចំទីកន្លែងមណ្ឌលសិប្បកម្មតូចៗ ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ

- លើកទឹកចិត្តឱ្យមានការសាងសង់សំណង់សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជនក្នុងសហគមន៍មូលដ្ឋានឱ្យមានមុខជំនាញក្នុងផ្នែកទេសចរណ៍ កសិកម្ម បរិស្ថាន សិប្បកម្ម និងឧស្សាហកម្មខ្នាតតូច ដោយធានាឱ្យបាននូវសេវាសមរម្យ។

**២.២.៤. រមណីយដ្ឋានវប្បធម៌**

រមណីយដ្ឋានវប្បធម៌ក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- រៀបចំផែនការដើម្បីបង្ហាញសក្តានុពលបុរាណវិទ្យា ជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម ព្រមទាំងទេសភាពវប្បធម៌ និងប្រពៃណីអ្នកស្រុកក្នុងតំបន់
- រៀបចំឱ្យមានកន្លែងផ្តល់ពត៌មាននៅតាមតំបន់នីមួយៗ និងសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ បង្កើតកន្លែងផ្តល់ពត៌មាននៅក្រៅរមណីយដ្ឋានការពារ ដើម្បីផ្តល់ជូនទេសចរ និងសាធារណជននូវការណែនាំស្តីពីបេតិកភណ្ឌប្រាសាទសំបូរព្រៃគុក។

ក្នុងតំបន់ស្នូល និងតំបន់ទ្រនាប់ អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវរៀបចំឱ្យមានមគ្គុទេសក៍ និងដាក់ផ្លាកសញ្ញាបង្ហាញពីរមណីយដ្ឋានដែលមានលក្ខណៈដោយឡែកដូចជា ក្រុមប្រាសាទសំខាន់ទាំងបី (ប្រាសាទសំបូរ ប្រាសាទយាយពន្ធ និងប្រាសាទតោ) ក្រុមប្រាសាទរបងរមាស និងប្រាសាទរណបផ្សេងៗទៀត ព្រមទាំងរចនាសម្ព័ន្ធក្រុងបុរាណ។

អាជ្ញាធរជាតិសំបូរព្រៃគុក អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំបង្កើតកម្មវិធីបង្ហាញដល់សិស្ស និស្សិត និងទេសចរ ស្តីពីជីវភាពរស់នៅរបស់ប្រជាជន តាមរយៈទស្សនីយភាពរបាំបុរាណ ប្រពៃណី ទំនៀមទម្លាប់ ផលិតកម្ម សិប្បកម្ម និងទិដ្ឋភាពពិសេសៗរបស់រមណីយដ្ឋានសំបូរព្រៃគុក។

**២.២.៥. ការគ្រប់គ្រងធនធានធម្មជាតិ**

ការគ្រប់គ្រងទេសភាពនៅរមណីយដ្ឋានក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- គ្រប់គ្រងទឹក ព្រៃឈើ និងសត្វព្រៃ ដើម្បីថែរក្សា ការពារប្រព័ន្ធអេកូឡូស៊ី និងបង្កើនជីវៈចម្រុះដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ការពារ និងបង្កើនតម្លៃទេសភាពធម្មជាតិ និងវប្បធម៌
- បញ្ចូលទៅក្នុងផែនការ និងសកម្មភាពនៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាន នូវគោលនយោបាយ និងទិសដៅសម្រាប់ចាត់ចែងគ្រប់គ្រងទេសភាព
- ហាមដាច់ខាតរាល់ការផ្សាយពាណិជ្ជកម្មគ្រប់រូបភាពក្នុងតំបន់ស្នូល និងតំបន់ទ្រនាប់។

ក្នុងតំបន់ស្នូល អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- ថែរក្សាទឹក ដីព្រៃឈើ ព្រមទាំងដាំឡើងវិញនូវព្រៃឈើធម្មជាតិ

- ថែទាំ ដាំដើមឈើនៅជុំវិញប្រាសាទ និងយកចេញនូវដើមឈើដែលប៉ះពាល់ទៅដល់សោភ័ណភាព ឬអាចបំផ្លាញដល់រចនាសម្ព័ន្ធសំណង់បុរាណ
- រៀបចំបង្ហាញសភាពដើមពិតនៃបុរាណវិទ្យា ដោយរៀបចំទេសភាពឱ្យមានលក្ខណៈសមស្របតាមបុរាណវិទ្យា
- ចាត់ចែងរៀបចំទេសភាពនៅជុំវិញប្រាសាទ តាមប្លង់គោលនៃគម្រោងរៀបចំអភិរក្ស និងអភិវឌ្ឍតំបន់មានប្រាសាទ។

ក្នុងតំបន់ទ្រនាប់ និងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- បង្កើនសួនរុក្ខជាតិ និងផ្លូវលំតាមដងព្រៃ
- អនុវត្តកម្មវិធីដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់
- រក្សា និងបង្កើតឱ្យមានតំបន់ព្រៃទ្រនាប់ ដោយរៀបចំដាំដើមឈើឡើងវិញ
- ការពារលើកស្ទួយតម្លៃទេសភាពតាមរយៈការងបង្កើតសកម្មភាព បរិស្ថាន កសិកម្ម និងការរៀបចំដែនដី។

ការចាត់ចែងទឹកនៅរមណីយដ្ឋានក្នុងតំបន់ការពារទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ជួសជុលកែលម្អដោយផ្នែកៗនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ និងចាត់ចែងរបបគ្រប់គ្រងទឹកតាមសំណង់ធារាសាស្ត្រថ្មី ឱ្យមានប្រសិទ្ធភាព
- ជៀសវាងការប្រើបច្ចេកវិទ្យា និងរចនាសម្ព័ន្ធថ្មី ដែលធ្វើឱ្យប៉ះពាល់ដល់សំណង់បុរាណ។

ក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ថែរក្សាប្រព័ន្ធធារាសាស្ត្របុរាណដែលមានស្រាប់ និងបរិស្ថានជុំវិញ
- សិក្សា និងរកលទ្ធភាពនៅក្នុងការស្តារ ដើម្បីឱ្យដំណើរការឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណ
- លើកគម្រោងផែនការស្តារប្រព័ន្ធធារាសាស្ត្រតូចៗ សម្រាប់បម្រើទៅដល់ការអភិវឌ្ឍកសិទេសចរណ៍ និងរក្សាលំនឹង និងការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្នុងករណីចាំបាច់។

ក្នុងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុក អាចអនុញ្ញាតឱ្យអភិវឌ្ឍធារាសាស្ត្រតូចៗ ដើម្បីបង្កើនផលិតផលកសិកម្ម និងការប្រើប្រាស់ផ្ទាល់របស់អ្នករស់នៅទីនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងបុរាណវត្ថុ។

### ២.២.៦. ប្រជាជន

អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- ផ្តល់អាទិភាពការងារដល់ប្រជាជនក្នុងរមណីយដ្ឋាន ដើម្បីចូលរួមចំណែកថែរក្សា និងលើកតម្លៃរមណីយដ្ឋាន
- តាមដានការប្រែប្រួលនៃកំណើន និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន ដើម្បីបង្កើនការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជនក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

អាជ្ញាធរជាតិសំបូរព្រៃគុកផងដែរ ត្រូវកែលម្អផ្លូវចេញ ចូលសម្រាប់អ្នករស់នៅក្នុងតំបន់នោះដោយជៀសវាងការប៉ះពាល់រមណីយដ្ឋាន។

ក្នុងតំបន់ស្នូល អាជ្ញាធរជាតិសំបូរព្រៃគុក មិនត្រូវអនុញ្ញាតឱ្យមានការបង្កើត និងពង្រីកភូមិព្រមទាំងទីប្រជុំជន។

ក្នុងតំបន់ទ្រនាប់៖

- រក្សាទុកភូមិបុរាណ
- មិនត្រូវអនុញ្ញាតឱ្យមានការបង្កើត និងពង្រីកភូមិ ព្រមទាំងទីប្រជុំជន
- បង្កលក្ខណៈងាយស្រួល ជំរុញ និងលើកទឹកចិត្តដល់ប្រជាជនឱ្យបង្កបង្កើនផលកសិកម្ម ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងបង្កើតមុខរបរ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ
- ផ្តល់អាទិភាពដល់អ្នករស់នៅក្នុងរមណីយដ្ឋានដោយឱ្យច្បាប់អនុញ្ញាតប្រកបមុខរបរតូចតាចជាលក្ខណៈគ្រួសារ។

ក្នុងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវរក្សាទុកមុខរបរ និងការប្រើប្រាស់តាមប្រពៃណីនូវដីដាំដុះ វាលស្មៅ ត្រពាំង និងបឹងបួ។

**២.២.៧. វត្តអារាម**

ក្នុងតំបន់ស្នូល និងតំបន់ទ្រនាប់ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- រក្សាទុកសហគមន៍សាសនាដែលមាន ហើយថែទាំងវត្តអារាមចាស់ៗ
- ហាមកសាងវត្តថ្មី ឬទីតាំងសាសនាផ្សេងៗ ក្រៅពីសំណង់ដែលមានស្រាប់។

ក្នុងតំបន់រណប ការបង្កើតវត្តថ្មីនៅតាមភូមិនានា ត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់។

**២.២.៨. សិប្បកម្ម និងសេវាកម្ម**

អាជ្ញាធរជាតិសំបូរព្រៃគុក មិនអនុញ្ញាតឱ្យមានការអភិវឌ្ឍផ្សេងៗក្នុងតំបន់ស្នូល លើកលែងតែសិប្បកម្ម និងសេវាកម្មទ្រង់ទ្រាយតូចៗដែលមានលក្ខណៈប្រពៃណី បម្រើឱ្យការអភិវឌ្ឍកសិកម្ម និងទេសចរណ៍របស់ប្រជាជនដែលមានទីលំនៅស្រាប់នៅក្នុងតំបន់នោះ.

អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវរាល់សំណល់រឹង និងរាវ ដែលបង្កើតឡើងដោយសិប្បកម្ម និងសេវាកម្ម។

នៅក្នុងតំបន់ស្នូល និងតំបន់ទ្រនាប់ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវកំណត់ទីតាំង ទំហំ និងចំនួនតូបលក់វត្ថុទាំងឡាយឱ្យមានគុណភាព និងរក្សាតម្លៃរមណីយដ្ឋាន។

ក្នុងតំបន់ទ្រនាប់ និងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវ៖

- ជំរុញបង្កើនរោងសិប្បកម្មនៅក្នុងភូមិដែលមានស្រាប់ ឬក្នុងមណ្ឌលទទួលទេសចរ
- ជំរុញសិប្បកម្មតូចៗ និងការផលិតវត្ថុអនុស្សាវរីយ៍។

### ២.២.៩. បណ្តាញចរន្តអគ្គិសនី

ក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- អនុញ្ញាតឱ្យដាក់បណ្តាញចរន្តអគ្គិសនី ដែលផ្តល់ដល់មូលដ្ឋាននោះ ដោយរក្សាសោភ័ណភាពរមណីយដ្ឋាន
- គ្រប់គ្រងរាល់ការតុបតែងភ្លើងបំភ្លឺ និងការរៀបចំពិធីផ្សេងៗក្នុងរមណីយដ្ឋាន ដោយត្រូវអនុវត្តតាមលក្ខណៈបច្ចេកទេស។

### ២.២.១០. ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន

ក្នុងតំបន់ទាំង អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវផ្តើមអនុវត្តកម្មវិធី ដើម្បីឱ្យមានការទាក់ទាញអារម្មណ៍ប្រជាជនមូលដ្ឋាន និងទស្សនិកជនចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ និងចំពោះបញ្ហាបរិស្ថាន។

ក្នុងតំបន់ស្នូល អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- កំណត់ទីតាំង និងរៀបចំតូបលក់វត្ថុអនុស្សាវរីយ៍តាមរចនាបថខ្មែរ
- កំណត់ទីតាំង និងរៀបចំឱ្យមានបង្គន់អនាម័យ ធុងសម្រាមឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

### ២.២.១១. ការបណ្តុះបណ្តាលធនធានមនុស្ស

អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវ៖

- បណ្តុះបណ្តាលអ្នកជំនាញសម្រាប់ការដ្ឋានកំណាយ និងការងារអភិរក្ស
- សហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ នៅក្នុងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរ ឆ្មាំរមណីយដ្ឋាន បុគ្គលិកថែទាំ
- សហការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដើម្បីបណ្តុះបណ្តាលមន្ត្រីជំនាញគ្រប់កម្រិត
- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុរាណវិទូ ស្ថាបត្យករ អ្នកអភិរក្ស និងអ្នកប្រកបវិជ្ជាជីវៈផ្សេងៗទៀតក្នុងផ្នែកចាត់ចែង និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

- យកចិត្តទុកដាក់ដល់ប្រជាជនក្នុងតំបន់ ដើម្បីរក្សានិរន្តរភាពនៅក្នុងការការពារ និងការអភិវឌ្ឍ
- លើកទឹកចិត្ត និងបណ្តុះបណ្តាលប្រជាជនឱ្យមានមុខជំនាញទូទៅ នៅក្នុងផ្នែកកសិកម្ម បរិស្ថាន និងទេសចរណ៍។

**២.២.១២. ការអភិវឌ្ឍ**

រាល់កិច្ចអភិវឌ្ឍរមណីយដ្ឋានសំបូរព្រៃគុកក្នុងតំបន់ទាំង ៣ អាជ្ញាធរជាតិសំបូរព្រៃគុកត្រូវៈ

- រៀបចំនីតិក្រមសម្រាប់ពិនិត្យ និងអនុម័តគម្រោងអភិវឌ្ឍនៅក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក
- រាល់គម្រោងអភិវឌ្ឍត្រូវគិតគូរពីផលប៉ះពាល់ សម្បត្តិវប្បធម៌ បរិស្ថានធម្មជាតិ និងសង្គម ឱ្យនៅកម្រិតទាបបំផុត
- ធ្វើកំណាយបុរាណវិទ្យាដើម្បីប្រមូលទិន្នន័យសម្រាប់សិក្សាវិភាគ និងចងក្រងឯកសារ មុននឹងចាប់ផ្តើមដំណើរការអភិវឌ្ឍ។

ការអភិវឌ្ឍនៅក្នុងតំបន់ស្នូល ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍សម្រាប់ការអភិរក្ស និងការលើកតម្លៃនៃរមណីយដ្ឋានសំបូរព្រៃគុក ដែលធ្វើឡើងដោយអាជ្ញាធរជាតិសំបូរព្រៃគុក។

ការអភិវឌ្ឍក្នុងតំបន់ទ្រនាប់ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍សម្រាប់អភិរក្ស ទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋានបុរាណ ឬសម្រាប់ថែរក្សាទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជននៅតំបន់នោះ។

ការអភិវឌ្ឍក្នុងតំបន់រណប អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវកំណត់នូវប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

រាល់ការសាងសង់សំណង់នៅក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ត្រូវមានលិខិតអនុញ្ញាតសាងសង់ពី អាជ្ញាធរជាតិសំបូរព្រៃគុក និងត្រូវគោរពទៅតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងសំណង់ជាធរមាន។

## ២.៣. ដំណើរក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោក[22]

### ២.៣.១. លក្ខណៈវិនិច្ឆ័យដើម្បីចុះបញ្ជីបេតិកភណ្ឌពិភពលោក

[22] ផល ពិសាល (អ្នកដឹកនាំ), ប៊ុន ស្រីស្រស់, នូ គីមឈីវ, វុន ពេជ្ជតា. *តំបន់ប្រាសាទសំបូរព្រៃគុក ៖ សញ្ញាណនៃបេតិកភណ្ឌពិភពលោក ក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិ* (ភ្នំពេញ៖ សាលាត្រាជូ, ២០១៧) ១៧ ដល់ ២២, http://www.salatraju.com (ចតចម្លងនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩)

ដើម្បីបញ្ចូលសម្បត្តិបេតិកភណ្ឌមួយទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក តំបន់ ឬទីតាំង ឬសំណង់នោះ ត្រូវមានតម្លៃលេចធ្លោជាសាកល និងត្រូវគោរពឱ្យបាននូវលក្ខណៈវិនិច្ឆ័យមួយ នៅក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំង ១០ (ដប់) ដែលមានរៀបរាប់ដូចខាងក្រោមនេះ៖

- លក្ខណៈវិនិច្ឆ័យទី ១៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ជាស្នាដៃល្អឯក ដែលត្រូវបង្កើតឡើងដោយការច្នៃប្រឌិត និងទេពកោសល្យរបស់មនុស្ស
- លក្ខណៈវិនិច្ឆ័យទី ២៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ជាតឹកតាងនៃការផ្លាស់ប្តូរទៅវិញទៅមកនៃឥទ្ធិពលដ៏សម្បើម លើការអភិវឌ្ឍខាងស្ថាបត្យកម្ម ឬបច្ចេកវិទ្យា ព្រមទាំងឥទ្ធិពលលើសិល្បៈនៃសំណង់ប្រាសាទ ក៏ដូចជាសិល្បៈនៃការរៀបចំទីក្រុង និងការបង្កើតទេសភាពនៅក្នុងរយៈពេលកំណត់ណាមួយ ឬក្នុងតំបន់វប្បធម៌ជាក់លាក់ណាមួយ
- លក្ខណៈវិនិច្ឆ័យទី ៣៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ជាសក្ខីកម្មគ្មានពីរ ឬយ៉ាងហោចណាស់មានលក្ខណៈពិសេសប្លែក ស្តីពីប្រពៃណីនៃវប្បធម៌មួយ ឬជាសក្ខីកម្មស្តីពីអរិយធម៌មួយដែលរស់រានមានជីវិត ឬអរិយធម៌មួយដែលបានបាត់បង់ទៅហើយ។
- លក្ខណៈវិនិច្ឆ័យទី ៤៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ផ្តល់នូវឧទាហរណ៍ដ៏លេចធ្លោមួយនៃប្រភេទសំណង់ ឬបណ្តុំនៃសំណង់ស្ថាបត្យកម្ម ឬបណ្តុំបច្ចេកវិទ្យា ឬទេសភាពដែលបង្ហាញពីសម័យកាលណាមួយ ក្នុងចំណោមសម័យកាលជាច្រើន ដែលមានសារៈសំខាន់នៅក្នុងប្រវត្តិសាស្ត្រមនុស្ស
- លក្ខណៈវិនិច្ឆ័យទី ៥៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ជាឧទាហរណ៍ដ៏លេចធ្លោនៃការបង្កើតប្រពៃណីរបស់មនុស្ស ការប្រើប្រាស់ជាប្រពៃណីនៃដែនដី ឬដែនទឹក ដែលជាតំណាងនៃវប្បធម៌មួយ ឬច្រើន ឬការទំនាក់ទំនងរបស់មនុស្សជាមួយបរិស្ថាន ពិសេសនៅពេលបរិស្ថាននោះងាយនឹងរងគ្រោះ ក្រោមឥទ្ធិពលផលប៉ះពាល់ដែលមិនអាចត្រឡប់ថយក្រោយបាននៃការប្រែប្រួលមួយ
- លក្ខណៈវិនិច្ឆ័យទី ៦៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ ឬដោយធាតុសម្ភារៈ ជាមួយនឹងព្រឹត្តិការណ៍ច្រើន ឬជាមួយនឹងទំនៀមទម្លាប់ដែលនៅរស់រានមានជីវិត ផ្សារភ្ជាប់ដោយផ្ទាល់ ឬដោយធាតុសម្ភារៈជាមួយនឹងគំនិតយោបល់ ឬជាមួយនឹងជំនឿ ឬជាមួយស្នាដៃសិល្បៈ និងអក្សរសាស្ត្រ ដែលមានភាពលេចធ្លោជាសាកល (គណៈកម្មការ ពិចារណាលក្ខណៈវិនិច្ឆ័យនេះ ទៅប្រើប្រាស់ជាអាទិភាព ដោយរួមផ្សំគ្នាជាមួយនឹងលក្ខណៈវិនិច្ឆ័យដទៃទៀត)

- លក្ខណៈវិនិច្ឆ័យទី ៧៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ បង្ហាញអំពីបាតុភូតធម្មជាតិ ឬតំបន់ធម្មជាតិដ៏ស្រស់ត្រកាល និងដែលប្រកបដោយសោភ័ណភាពលេចធ្លោជាច្រើន។
- លក្ខណៈវិនិច្ឆ័យទី ៨៖ រដ្ឋភាគី ត្រូវបង្ហាញថា តំបន់ ឬសំណង់នោះ ជាឧទាហរណ៍ដ៏លេចធ្លោ ដែលតំណាងឱ្យតំណាក់កាលធំៗនៃប្រវត្តិសាស្ត្រនៃភពផែនដី រួមទាំងសក្ខីភាពនៃជីវិត សក្ខីភាពនៃដំណើរការភូគព្ភសាស្ត្រដែលកំពុងប្រព្រឹត្តទៅ ក្នុងការអភិវឌ្ឍនៃទម្រង់ដែនដី ឬធាតុសំខាន់នៃភូមិសណ្ឋានវិទ្យា រូបលេខន៍ ដែលមានអត្ថន័យដ៏សំខាន់ (significant geomorphic or physiographic features)
- លក្ខណៈវិនិច្ឆ័យទី ៩៖ រដ្ឋភាគី ត្រូវអះអាងថា តំបន់ ឬសំណង់នោះ ជាឧទារហណ៍ដ៏លេចធ្លោ បង្ហាញពីដំណើរការនៃអេកូឡូស៊ី និងជីវវិទ្យា ដែលកំពុងប្រព្រឹត្តនៅក្នុងការវិវត្ត និងការអភិវឌ្ឍនៃប្រព័ន្ធជីវចម្រុះ និងសហាគមន៍នៃរុក្ខជាតិ និងសត្វ ដែលរស់នៅលើដី ក្នុងទឹក តាមតំបន់ឆ្នេរសមុទ្រ និងក្នុងសមុទ្រ
- លក្ខណៈវិនិច្ឆ័យទី ១០៖ រដ្ឋភាគី ត្រូវអះអាងថា តំបន់ ឬសំណង់នោះ មានពោរពេញទៅដោយជម្រកធម្មជាតិដ៏សំខាន់ និងមានអត្ថប្រយោជន៍ សម្រាប់ការអភិវឌ្ឍនៅនឹងកន្លែងនៃតំបន់ជីវចម្រុះដែលសំបូរបែប រួមបញ្ចូលទាំងជម្រកធម្មជាតិ ដែលជាកន្លែងរស់នៅនៃអម្បូរសត្វ ដែលទទួលការគំរាមកំហែង ហើយដែលមានតម្លៃជាសាកលប្រកបដោយភាពពិសេសប្លែកខាងផ្នែកវិទ្យាសាស្ត្រ ឬផ្នែកអភិរក្ស។

### ២.៣.២. ដំណើរការចុះបញ្ជីនៃប្រាសាទសំបូរព្រៃគុក

ប្រទេសកម្ពុជា បានក្លាយជាភាគីនៃ **អនុសញ្ញាស្ដីពីការអភិរក្សបេតិកភណ្ឌពិភពលោកវប្បធម៌ និងធម្មជាតិ (១៩៧២)** នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩១។ ក្នុងឋានៈជារដ្ឋភាគីនៃអនុសញ្ញានេះ ប្រទេសកម្ពុជាបានខិតខំគោរពទៅតាមបទដ្ឋានគតិយុត្ត និងនីតិវិធីនានា ក្នុងការរៀបចំឯកសារស្នើសុំពាក់ព័ន្ធនានា និងបង្កើតក្រុមបច្ចេកទេសស្រាវជ្រាវ ដើម្បីពិនិត្យមើលលទ្ធភាពក្នុងការស្នើសុំការដាក់បញ្ចូលសម្បត្តិវប្បធម៌ជាតិរបស់ខ្លួន ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ជាសារវតារ តំបន់ប្រាសាទសំបូរព្រៃគុក ត្រូវបានស្នើដោយប្រទេសកម្ពុជា ដើម្បីធ្វើការដាក់បញ្ចូលទៅក្នុងបញ្ជីបម្រុង នៅឆ្នាំ ១៩៩២ ជាមួយនឹងតំបន់ និងសំណង់ប្រាសាទចំនួន ៨ ដទៃទៀត ដែលមានដូចជា តំបន់ប្រាសាទកោះកេរ្តិ៍ តំបន់គូលេន តំបន់អង្គរបុរី និងភ្នំដា តំបន់ឧត្តុង្គ តំបន់ប្រាសាទបេងមាលា ឬបឹងមាលា តំបន់ប្រាសាទព្រះខ័នកំពង់ស្វាយ តំបន់ប្រាសាទបន្ទាយឆ្មា និងតំបន់បន្ទាយព្រៃនគរ។

បន្ទាប់ពីបានសម្រេចដាក់តំបន់ប្រាសាទនេះទៅក្នុងបញ្ជីបម្រុងនាឆ្នាំ ១៩៩២ ប្រទេសកម្ពុជាត្រូវការពេលវេលាមួយចំនួន ក្នុងការអនុម័តច្បាប់ជាតិផ្ទៃក្នុងជាច្រើន ដើម្បីកំណត់ពីការគ្រប់គ្រងរមណីយដ្ឋាននេះ និងដើម្បីដាក់តំបន់ប្រាសាទនេះ ជាតំបន់រមណីយដ្ឋានជាតិ ដែលទទួលបានការពារ និងអភិរក្សពីសំណាក់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

នៅដើមឆ្នាំ ២០១២ ក្រុមការងារដែលពាក់ព័ន្ធ បានរៀបចំកសាងឯកសារនានាដែលពាក់ព័ន្ធនឹងការស្នើដាក់ "ប្រាសាទសំបូរព្រៃគុក" ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ បន្ទាប់មក នាចុងឆ្នាំ ២០១៣ ឯកសារការងារនេះត្រូវបានសម្រួច ប្រិតប្រៀង និងសម្រិតសម្រាំងបន្ថែមទៀត អនុលោមទៅតាមទិសដៅណែនាំនៃការអនុវត្តអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌពិភពលោកវប្បធម៌ និងធម្មជាតិ។ នៅដើមខែ មករា ឆ្នាំ ២០១៦ ប្រទេសកម្ពុជា បានសម្រេចលើកសំណើជាផ្លូវការទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ដើម្បីធ្វើការសិក្សាលើឯកសារស្នើសុំនេះ។ នៅខែ កញ្ញា ឆ្នាំ ២០១៦ ដោយផ្អែកលើសំណើនេះ មជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក បានបញ្ជូនអ្នកជំនាញរបស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) មកវាយតម្លៃ "តំបន់ប្រាសាទសំបូរព្រៃគុក"។

ហើយទីបំផុត នាថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៧ ក្នុងកិច្ចប្រជុំលើកទី ៤១ នៅប្រទេសប៉ូឡូញ (ទីក្រុងក្រាកូវ) តាមរយៈសេចក្តីសម្រេច "DECISION 41 COM 88.15" គណៈកម្មការបេតិកភណ្ឌពិភពលោកបានសម្រេចដាក់បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកនេះ ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ពិភពលោក ដោយអនុលោមតាមមាត្រា ១ នៃអនុសញ្ញាឆ្នាំ ១៩៧២ និងផ្អែកលើលក្ខណៈវិនិច្ឆ័យទី ២ ទី ៣ និងទី ៦។ ពោលគឺ តំបន់ប្រាសាទសំបូរព្រៃគុកត្រូវបានចាត់ទុកថា ជាបុរាណស្ថាននៃស្ថាបត្យកម្មលេចធ្លោមួយជាសាកល ដោយឈរលើមូលហេតុ ៣ យ៉ាង (ស្របទៅតាមលក្ខណៈវិនិច្ឆ័យទី ២, ទី ៣ និងទី ៦)៖

ទី ១៖ ជាតឹកតាងនៃការផ្លាស់ប្តូរទៅវិញទៅមក នៃឥទ្ធិពលដ៏សម្បើម លើការអភិវឌ្ឍខាងស្ថាបត្យកម្ម ឬបច្ចេកវិទ្យា ព្រមទាំងឥទ្ធិពលលើសិល្បៈនៃសំណង់ប្រាសាទ ក៏ដូចជាសិល្បៈនៃការរៀបចំទីក្រុង និងការបង្កើតទេសភាព នៅក្នុងរយៈពេលកំណត់ណាមួយ ឬនៅក្នុងតំបន់វប្បធម៌ជាក់លាក់ណាមួយ។ ជាក់ស្តែងយោងតាមលោកសាស្ត្រាចារ្យ ប្រាក់ សុណ្ណារ៉ា៖ "ការកំណត់ទីតាំងសម្រាប់សង់ប្រាសាទនៅសំបូរព្រៃគុក បង្ហាញនូវលក្ខណៈវិសេសវិសាលនៃការរៀបចំក្រុង និងស្ថាបត្យកម្មពីស្រុកឥណ្ឌា។ លក្ខណៈវិសេសវិសាលនៃស្ថាបត្យកម្មនៅសម្បូរព្រៃគុកអាចឃើញតាមរយៈតួប្រាង្គដែលមាន ៨ ជ្រុង ចម្លាក់ប្រាសាទអណ្តែត និងរូបមេដាយុងនៅលើជញ្ជាំងឥដ្ឋ។ បន្ថែមលើនេះទៅទៀតគឺ ផ្តែរទ្វារ និងរូបចម្លាក់ធ្វើពីថ្មភក់ ដែលមានរចនាបថហៅថា សំបូរព្រៃគុក។

សិល្បៈ និងស្ថាបត្យកម្ម វិវត្តន៍ឡើងនៅរាជធានីនេះបានក្លាយជាស្នាដៃក៏គំរូមួយ ដែលបានសាយភាយទៅកាន់ទីតាំងផ្សេងៗទៀតនៅក្នុងតំបន់ និងទីបំផុតបានជួយធ្វើឱ្យកាន់តែប្រសើរឡើង និងច្បាស់លាស់នូវអ្វីដែលជាសិល្បៈខ្មែរ ដែលយើងឃើញមាននៅសម័យអង្គរ(...)"។

ទី ២៖ ជាសក្ខីកម្មគ្មានពីរ ឬយ៉ាងហោចណាស់ មានលក្ខណៈពិសេសប្លែកស្តីពីប្រពៃណីនៃវប្បធម៌មួយ ឬជាសក្ខីកម្មស្តីពីអរិយធម៌មួយដែលនៅរស់រានមានជីវិត ឬអរិយធម៌មួយដែលបានបាត់បង់ទៅហើយ។ ជាក់ស្តែងយោងតាមលោកសាស្ត្រាចារ្យ ប្រាក់ សុណ្ណារ៉ា លក្ខណៈវិនិច្ឆ័យនេះត្រូវស្តែងឡើងដោយ "រាជធានីឥសានបុរៈ បានទទួលឥទ្ធិពលឥណ្ឌាខ្លាំង តាមរយៈស្ថាប័នសង្គម សាសនា និងសិល្បៈ។ ជំនឿសាសនានៅតំបន់ស្នូលនៃរាជធានីនេះ អាចចាត់ទុកបានថា វាជាមជ្ឈមណ្ឌលធម្មយាត្រាសាសនា ដ៏ធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។"។

ទី ៣៖ ត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ ឬដោយធាតុសម្ភារៈ ជាមួយនឹងព្រឹត្តិការណ៍ជាច្រើន ឬជាមួយនឹងទំនៀមទម្លាប់ដែលនៅរស់រានមានជីវិត ផ្សារភ្ជាប់ដោយផ្ទាល់ ឬដោយធាតុសម្ភារៈ ជាមួយនឹងគំនិតយោបល់ ឬជាមួយនឹងជំនឿ ឬជាមួយស្នាដៃសិល្បៈ និងអក្សរសាស្ត្រ ដែលមានភាពលេចធ្លោជាសាកល។ យោងតាមលោកសាស្ត្រាចារ្យ ប្រាក់ សុណ្ណារ៉ា លក្ខណៈវិនិច្ឆ័យនេះ ត្រូវស្តែងឡើងដោយ "រាជធានីឥសានបុរៈមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយតម្លៃជាសកលនៃភាពចុះសម្រុងគ្នា ការឯកភាព និងដោយសន្តិវិធី ពោលជាការសំយោគសាសនា (សិវៈ ទុគ៌ា ហរិហរៈ ព្រហ្ម ព្រះពុទ្ធ)។ លើសពីនេះ ទីតាំងនេះជាកន្លែងដែលមានសិលាចារឹកខ្មែរ និងសិលាចារឹកសំស្រ្កឹតនិយាយពី ទេវរាជដែលជាទស្សនៈនយោបាយមួយ អាចផ្សារភ្ជាប់ជាមួយនឹងទស្សនៈនយោបាយ (ទេវរាជ) ដែលតាមរយៈរឿងព្រេងបានវិវត្តន៍មកពីប្រាសាទវត្តភូ និងបានបន្តប្រើប្រាស់ក្នុងរជ្ជកាលផ្សេងៗក្នុងសម័យអង្គរ។ ប្រព័ន្ធរដ្ឋបាលបង្ហាញក្នុងសិលាចារឹកនៅរាជធានីនេះ ក៏មានឥទ្ធិពលនៅលើប្រព័ន្ធរដ្ឋបាលបង្គោលបួនរបស់ក្រុងអយុធ្យា។ យើងត្រូវដឹងថា ទស្សនៈទេវរាជនេះនៅតែបន្តរស់រាននាពេលសព្វថ្ងៃនេះ ក្នុងប្រព័ន្ធនយោបាយនៃប្រទេសកម្ពុជា និងថៃ។

### ២.៣.៣. កត្តាត្រូវយកចិត្តទុកដាក់

លក្ខណៈវិនិច្ឆ័យទាំង ១០ ដូចដែលបានរៀបរាប់ខាងលើនេះ មានលក្ខណៈបច្ចេកទេសខ្លាំងដែលតម្រូវឱ្យរដ្ឋភាគី បង្ហាញសក្ខីកម្ម និងភស្តុតាងនានាតាមបែបវិទ្យាសាស្ត្រ ដោយយោងទៅលើអំណះអំណាងផ្សេងៗខាងផ្នែកបុរាណវិទ្យា ស្ថាបត្យកម្ម នរវិទ្យា ភូគព្ភវិទ្យា រូបវិទ្យា រូបលេខន៍ ភូមិសណ្ឋានវិទ្យា ជាតិពន្ធុវិទ្យា ជីវវិទ្យា និងអេកូឡូស៊ី ព្រមទាំងសោភ័ណវិទ្យា ជាដើមក្នុងការទាមទារក៏ដូចជាបញ្ចុះបញ្ចូលគណៈកម្មាការវាយតម្លៃឱ្យទទួលយកនូវទឡ្ហីករណ៍របស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ សម្បត្តិបេតិកភណ្ឌដែលត្រូវបានសម្រេចចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកហើយ ក៏

អាចនឹងត្រូវដកចេញវិញគ្រប់ពេលផងដែរ បើពុំគោរពបាននូវលក្ខខណ្ឌដែលអង្គការបេតិកភណ្ឌពិភពលោកបានដាក់ជូន។

តាមការស្រាវជ្រាវ រហូតមកដល់ពេលបច្ចុប្បន្ននេះ គេសង្កេតឃើញថា មានបេតិកភណ្ឌជាតិចំនួន ១០៧៣ នៃបណ្តារដ្ឋភាគី ១៦៧ ប្រទេសដែលបានបំពេញលក្ខណៈវិនិច្ឆ័យដូចដែលបានរៀបរាប់ខាងលើ និងដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាការបេតិកភណ្ឌពិភពលោក ថាជាបេតិកភណ្ឌពិភពលោករបស់មនុស្សជាតិ ដែលក្នុងនោះរួមមានដូចជា សម្បត្តិបេតិកភណ្ឌវប្បធម៌ចំនួន ៨៣២ បេតិកភណ្ឌដែលអាចនឹងងាយទទួលរងគ្រោះចំនួន ៥៤ បេតិកភណ្ឌធម្មជាតិចំនួន ២០៦ និងបេតិកភណ្ឌចម្រុះចំនួន ៣៥។

ដោយឡែក គេឃើញមាន បេតិកភណ្ឌពិភពលោកចំនួន ២ ដែលត្រូវបានដកចេញពីបញ្ជីនៃបេតិកភណ្ឌពិភពលោកវិញ ដោយសាររដ្ឋភាគី ពុំបានអនុវត្តកាតព្វកិច្ចដែលតម្រូវដោយអនុសញ្ញាឆ្នាំ ១៩៧២ នេះ និងដែលបានធ្វើឱ្យតំបន់រមណីយដ្ឋាននោះបាត់បង់នូវភាពលេចធ្លោជាសាកល។ បេតិកភណ្ឌពិភពលោកទាំង ២ នោះគឺ តំបន់ Dresden Elbe Valley នៃប្រទេសអាល្លឺម៉ង់ (ដកចេញនៅឆ្នាំ ២០០៩) និង Arabian Oryx Sanctuary នៃប្រទេសអូម៉ង់ (ដកចេញនៅឆ្នាំ ២០០៧)។

# សេចក្តីសន្និដ្ឋាន

យោងតាមការអធិប្បាយផ្នែក ១.១. នៃជំពូកទី ១ យើងសង្កេតឃើញថា អាជ្ញាធរជាតិសំបូរព្រៃគុក គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នដទៃទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងនាមជាស្ថាប័នស្ថិតនៅក្រោមលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ តាមរយៈផ្នែក ១.២. នៃជំពូកទី ១ ក៏បានបញ្ជាក់យ៉ាងច្បាស់ពី សេនាធិការទាំងឡាយរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ដែលបង្ហាញនូវភាពពេញលេញផ្នែករចនាសម្ព័ន្ធនៃអាជ្ញាធរនេះ។ នៅក្នុងផ្នែកទី ២.១. នៃជំពូកទី ២ ផងដែរ ក៏បានកំណត់ពីព្រំដែនសមត្ថកិច្ចរបស់អាជ្ញាធរនេះ តាមរយៈការកំណត់បែងចែកតំបន់នានានៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ ព្រមជាមួយគ្នានេះផងដែរ នៅក្នុងផ្នែក ២.២. នៃជំពូកទី ២ បានកំណត់កាន់តែជាក់លាក់បន្ថែមទៀតអំពីការរៀបចំ និងការគ្រប់គ្រងរបស់អាជ្ញាធរនេះ នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដែលជាដែនសមត្ថកិច្ចរបស់ខ្លួន។

តាមរយៈការអធិប្បាយផ្នែកនីមួយៗនៃជំពូកទាំងពីរខាងលើ បានសបញ្ជាក់ថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ពិតជាមានលក្ខណៈគ្រប់គ្រាន់ និងពេញលេញ ដើម្បីនឹងដំណើរការការងាររបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងបេសកកម្មនៃការការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ប្រាសាទសំបូរព្រៃគុក។ កត្តានេះផងដែរឆ្លុះបញ្ចាំងឱ្យឃើញថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានការយកចិត្តទុកដាក់ និងមានផែនការច្បាស់លាស់នៅក្នុងការចូលរួមលើកស្ទួយតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ក៏ដូចជាវិស័យវប្បធម៌ទាំងមូលផងដែរ។ កត្តាទាំងអស់នេះហើយ ទើបនាំឱ្យប្រទេសកម្ពុជាសម្រេចបាននូវសមិទ្ធិផលដូចរៀបរាប់ក្នុងផ្នែក ២.៣. នៃជំពូកទី ២ គឺ ការចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

ភាពជោគជ័យអាចកើតមានឡើងបាន ក៏ដោយសាររមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានតម្លៃជាប្រវត្តិសាស្ត្រ រួមជាមួយនឹងតម្លៃនៃការងារអភិរក្ស មានការចូលរួមពីសំណាក់សហគមន៍ និងប្រជាពលរដ្ឋ ការអភិវឌ្ឍលក្ខណៈបែបទេសចរណ៍ សហគមន៍វប្បធម៌ ជាពិសេសរាជរដ្ឋាភិបាលមានផែនការច្បាស់លាស់នៅក្នុងការអភិវឌ្ឍរមណីយដ្ឋាននេះប្រកបដោយចីរភាព ដោយមិនមែនជាភាពចៃដន្យដែលអាចកើតឡើងឯកឯងនោះទេ។

សរុបសេចក្តីមក យើងអាចសន្និដ្ឋានបានថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិសំបូរព្រៃគុក គឺមានលក្ខណៈសមស្រប និងពិតជាមានសារៈសំខាន់ក្រៃលែងក្នុងការចូលរួមលើកស្ទួយវិស័យវប្បធម៌ ជាពិសេសជំរុញឱ្យតំបន់រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុកដែលជាតំបន់ប្រវត្តិសាស្ត្រកម្ពុជាទី ៣ បានក្លាយខ្លួនទៅជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក បន្ទាប់ពីតំបន់រមណីយដ្ឋានអង្គរ និងតំបន់រមណីយដ្ឋានព្រះវិហារ។

# អនុសាសន៍

ដូចអ្វីដែលបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានខាងលើ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក អាចក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោកបាន ក៏ព្រោះរមណីយដ្ឋាននេះមានតម្លៃជាប្រវត្តិសាស្ត្រ រួមជាមួយនឹងតម្លៃនៃការងារអភិរក្ស មានការចូលរួមពីសំណាក់សហគមន៍ និងប្រជាពលរដ្ឋ ការអភិវឌ្ឍដែលមានលក្ខណៈបែបទេសចរណ៍ សហគមន៍វប្បធម៌ ជាពិសេសគឺរាជរដ្ឋាភិបាលកម្ពុជា មានផែនការច្បាស់លាស់ក្នុងការអភិវឌ្ឍតំបន់រមណីយដ្ឋាននេះប្រកបដោយចីរភាព។

ប៉ុន្តែបើទោះជាយ៉ាងនេះក្តី នៅក្នុងករណីប្រសិនបើប្រជាពលរដ្ឋ និងអ្នកវិនិយោគទុន ឬអ្នកអាស្រ័យផលនានាក្នុងតំបន់នេះ ធ្វើការអភិវឌ្ឍនាំឱ្យមានការបំពុលបរិស្ថាន បាត់បង់សោភ័ណភាព បាត់អត្តសញ្ញាណនៃសម្បត្តិវប្បធម៌មានតម្លៃជាប្រវត្តិសាស្ត្រ ដែលខុសពីគោលការណ៍របស់អង្គការបេតិកភណ្ឌពិភពលោកយូណេស្កូ នោះវានឹងធ្វើឱ្យតំបន់រមណីយដ្ឋាននេះធ្លាក់ពិន្ទុឈានទៅដល់ការបាត់បង់ភាពទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិ ហើយអាចនាំឱ្យរមណីយដ្ឋាននេះឈានដល់ការដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោកបានផងដែរ។

អាស្រ័យដូចដែលបានលើកឡើងនៅខាងលើ យើងខ្ញុំសូមមានមតិយោបល់ដូចតទៅ៖

- សូមសំណូមពរដល់អាជ្ញាធរជាតិសំបូរព្រៃគុក រួមជាមួយក្រសួងស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ទាំងឡាយ សូមជួយយកចិត្តទុកដាក់លើបញ្ហានេះឱ្យបានកាន់ខ្ពស់ឡើង បើទោះបីជាបច្ចុប្បន្ននេះមានលក្ខណៈល្អប្រសើរយ៉ាងណាក៏ដោយ ជាពិសេសជំរុញនូវការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តនានា ក៏ដូចជាចំណេះដឹងដែលទាក់ទងនឹងអាជ្ញាធរខ្លួនផ្ទាល់ក្នុងសង្គមឱ្យកាន់តែទូលំទូលាយផងដែរ ទៅដល់សាធារណៈជនផងដែរ។
- សូមសំណូមពរដល់ប្រជាពលរដ្ឋ អ្នកវិនិយោគទុន និងអ្នកអាស្រ័យផលនានានៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក សូមសហការជាមួយនឹងអាជ្ញាធរជាតិសំបូរព្រៃគុក ក៏ដូចជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបន្តជំរុញ និងលើកកម្ពស់ក្នុងការអភិរក្ស និងការអភិវឌ្ឍនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកឱ្យកាន់តែរលូនបន្តទៅមុខ ចៀសវាងការធ្វើឱ្យធ្លាក់នូវតម្លៃនៃសម្បត្តិបេតិកភណ្ឌពិភពលោកមួយនេះ។
- សូមសំណូមពរដល់សាស្ត្រាចារ្យ អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជា សិស្ស និស្សិតទាំងឡាយ សូមចូលរួមក្នុងការសិក្សាស្រាវជ្រាវអំពីអាជ្ញាធរជាតិសំបូរព្រៃគុកនេះ ឱ្យកាន់តែសំបូរបែប និងទូលំទូលាយដូចគ្នានឹងការសិក្សាស្រាវជ្រាវអំពីអាជ្ញាធរជាតិផ្សេងៗ ដើម្បីជាផ្នែកមួយក្នុងការលើកកម្ពស់ការសិក្សាផ្នែកនីតិសាស្ត្រ ក៏ដូចជាការលើកកម្ពស់ដល់វិស័យវប្បធម៌ជាតិនៃប្រទេសកម្ពុជាយើងផងដែរ។

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្ត

### ១. ព្រះរាជក្រម

- ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

### ២. ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌សំបូរព្រៃគុក
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា ៥ និងមាត្រា ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគ្រឹះស្ថានសាធារណៈរដ្ឋបាល

### ៣. អនុក្រឹត្យ

- អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក
- អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌សំបូរព្រៃគុក

## ខ. សៀវភៅឯកសារ


- លោកបណ្ឌិត អ៊ុន សកក្កដា. ២០១៩. *សៀវភៅនីតិនគរូបនីយវិទ្យា.* (ភ្នំពេញ)
- ផល ពិសាល (អ្នកដឹកនាំ), ប៊ុន ស្រីស្រស់, នូ គីមឈីវ, វុន ពេជ្ជតា. *តំបន់ប្រាសាទសំបូរព្រៃគុក ៖ សញ្ញាណនៃបេតិកភណ្ឌពិភពលោក ក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិ* (ភ្នំពេញ ៖ សាលាត្រាជូ, ២០១៧) ១៧ ដល់ ២២, http://www.salatraju.com (ថតចម្លងនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩)d

- ព្រះសង្ឃរាជ ជួនណាត. *វចនានុក្រមខ្មែរ*

## ខ. គេហទំព័រ

- http://www.national-assembly.org.kh
- https://data.opendevelopmentmekong.net
- http://ebooks.libraryrule.com
- https://www.coj.gov.kh
- https://salatraju.com

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

# ច្បាប់

## ស្តីពី

# កិច្ចការពារបេតិកភណ្ឌវប្បធម៌

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតេយតី**

******************

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំទឹកដីនគរបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែ កុម្ភះ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភះ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់និង រៀបចំតំបន់អង្គរ ហៅថា" **អប្សរា**"
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស/ចុះថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និង ការចាត់ចែងគ្រប់គ្រងតំបន់សៀមរៀបអង្គរ
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែ តុលា ឆ្នាំ ១៩៩៥
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគររូបនីយកម្មនិង សំណង់

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូរប្រែបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់ ។

**មាត្រា ២.-**

បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើងឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ ។

**មាត្រា ៣.-**

ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈនិងអចលនៈ ទោះជាកម្មសិទ្ធិសាធារណៈក្តី ឬក៏ជាឯកជនក្តីហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ ។

លើកលែងតែមានបទបញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ ។

**មាត្រា ៤.-**

តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្សនិងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តន៍របស់អារ្យធម៌ឬរបស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បំរើផលប្រយោជន៍សាធារណៈ ។

សម្បត្តិវប្បធម៌ដែលបានរៀបរាប់ក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២

## បទបញ្ញត្តិពិសេស

### ផ្នែកទី ១

### ស្ថាប័នគ្រប់គ្រងនិងប្រតិបត្តិ

**មាត្រា ៥.-**

ការលើកគោលនយោបាយទូទៅ ក្នុងវិស័យសម្បត្តិវប្បធម៌ជាតិជាពិសេសដើម្បីការពារថែរក្សានិងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ (ក.ជ.វ.ជ) ដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាស្ថាប័នប្រតិបត្តិ ។

ដោយឡែកនៅតំបន់សៀមរាបអង្គរ ការការពារថែរក្សានិងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិត្រូវប្រគល់អោយអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរអប្សរា ។

ការសម្របសម្រួលភារកិច្ចរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវកំណត់ដោយអនុក្រឹត្យ ។

### ផ្នែកទី ២

### រមណីយដ្ឋានដែលត្រូវការពារ

**មាត្រា ៦.-**

រមណីយដ្ឋានដែលត្រូវការពាររួមមាន :

-ឧទ្យានដែលមានបុរាណវត្ថុឬរមណីយដ្ឋានដទៃទៀតដែលមានអត្ថប្រយោជន៍សំរាប់បុរាណវិទ្យា នរវិទ្យាឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន ។

-ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់ ក.ជ.វ.ជ ។

# ផ្នែកទី ៣
## បញ្ជីសារពើភណ្ឌ

**មាត្រា ៧.-**

ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ជូលនូវសម្បត្តិវប្បធម៌សាធារណៈឬឯកជន ដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ទោះជាសម្បត្តិទាំងនោះមិនតំរូវឱ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ ។

**មាត្រា ៨.-**

ការចុះបញ្ជីសារពើភណ្ឌនេះ ត្រូវប្រកាសឡើងដោយសេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៥ ។

**មាត្រា ៩.-**

ក្រោយពីបានចុះបញ្ជីសារពើភណ្ឌរួចហើយ ចាំបាច់ត្រូវឱ្យម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ទ្រព្យសម្បត្តិនោះ ជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចមួយខែមុននឹងខ្លួនធ្វើសកម្មភាពណាមួយក្នុងបំណងនឹងលក់ឬផ្ទេរកម្មសិទ្ធិ ផ្លាស់ប្តូរទី តាំង បំផ្លាញចោល ប្រែក្លាយផ្លាស់ប្តូររូបរាង ជួសជុលឬធ្វើការស្តាបនាឡើងវិញនូវសម្បត្តិវប្បធម៌នោះ ។

អាជ្ញាធរមានសមត្ថកិច្ចអាចប្រឆាំងនឹងសកម្មភាពខាងលើបែបនេះបាន លុះត្រាតែបានចាត់វិធានការសមស្របតាមនីតិក្រមចំណាត់ថ្នាក់ ។

**មាត្រា ១០.-**

ការចុះបញ្ជីសារពើភណ្ឌត្រូវទុកជាមោឃៈបើសិនជាមិនបានបញ្ជូនបន្ថែមនូវសំណើសុំបញ្ចូលចំណាត់ថ្នាក់ជាសម្បត្តិវប្បធម៌ក្នុងរយៈពេលប្រាំមួយខែ ចាប់តាំងពីពេលដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរនោះមក ។

# ផ្នែកទី ៤
## ចំណាត់ថ្នាក់

**មាត្រា ១១.-**

ចំណាត់ថ្នាក់គឺការកត់ត្រាសម្បត្តិវប្បធម៌សាធារណៈឬឯកជនទាំងឡាយដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ហើយកិច្ចការពារនោះគឺដើម្បីបំរើផលប្រយោជន៍សាធារណៈក្នុងវិស័យវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ។

**មាត្រា ១២.-**

សំណើសុំចំណាត់ថ្នាក់ ត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកជូនដំណឹងឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ ។

**មាត្រា ១៣.-**

បន្ទាប់ពីការជូនដំណឹងជាលាយល័ក្ខណ៍អក្សររួចមក បើសិនជាគ្មានសេចក្តីសំរេចក្នុងរយៈពេលដប់ពីរខែ សំណើសុំចំណាត់ថ្នាក់នឹងត្រូវទុកជាមោឃៈ។

**មាត្រា ១៤.-**

ចំណាត់ថ្នាក់ ត្រូវប្រកាសឡើងដោយសេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ច ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើសេចក្តីសំរេចក្នុងរយៈពេលបីខែ គិតចាប់តាំងពីថ្ងៃដែលម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់បានទទួលលិខិតជូនដំណឹងរបស់អាជ្ញាធរនោះ ។

**មាត្រា ១៥.-**

ចំណាត់ថ្នាក់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ ក្នុងករណីជាចាំបាច់ ត្រូវជូនដំណឹងទៅមន្ទីររក្សាអចលវត្ថុ (មន្ទីរទទួលបន្ទុកគ្រប់គ្រងបញ្ជីអចលនវត្ថុ)។

**មាត្រា ១៦.-**

ក្នុងករណីដែលម្ចាស់កម្មសិទ្ធិមិនយល់ព្រម ចំណាត់ថ្នាក់សម្បត្តិវប្បធម៌នៅតែត្រូវធ្វើជាដដែល ។

**មាត្រា ១៧.-**

ការបង់ខាតដែលបណ្ដាលមកពីចំណាត់ថ្នាក់សម្បត្តិវប្បធម៌នេះ អាចត្រូវទូទាត់ជាប្រាក់បំណាច់ឱ្យដល់ម្ចាស់កម្មសិទ្ធិ ។

ពាក្យសុំទារប្រាក់បំណាច់ត្រូវដាក់មកអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេលបីខែគិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្ដីពីសេចក្ដីសំរេចនៃចំណាត់ថ្នាក់នេះ ។

ចំនួនប្រាក់បំណាច់ខាងលើនេះ ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ការតវ៉ាចំពោះសេចក្ដីសំរេចស្ដីពីគោលការណ៍ឬពីចំនួនប្រាក់បំណាច់ អាចនឹងធ្វើឡើងនៅចំពោះមុខតុលាការមានសមត្ថកិច្ច ។

**មាត្រា ១៨.-**

អាជ្ញាធរមានសមត្ថកិច្ចធ្វើតារាងសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយជារៀងរាល់ដំណាច់ឆ្នាំ ។

តារាងសម្បត្តិវប្បធម៌ចាត់ថ្នាក់នេះត្រូវធ្វើតាមខេត្តនីមួយៗ ហើយត្រូវចុះក្នុងរាជកិច្ច ។

ប្រការដែលត្រូវចុះមានជាអាទិ៍ :

-ប្រភេទនៃសម្បត្តិវប្បធម៌ដែលត្រូវបានចាត់ថ្នាក់

-ទីកន្លែងដែលសម្បត្តិវប្បធម៌នោះស្ថិតនៅ

-គោត្តនាមនិងនាមរបស់ម្ចាស់កម្មសិទ្ធិ

-កាលបរិច្ឆេទនៃចំណាត់ថ្នាក់ ។

**មាត្រា ១៩.-**

សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ មិនអាចកែប្រែបានឡើយ ។

**មាត្រា ២០.-**

សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ ដែលជាកម្មសិទ្ធិរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈមិនអាចលក់ឬផ្ទេរកម្មសិទ្ធិបានឡើយ ។

មាត្រា ២១.-

ជនណាក៏ដោយដែលលក់ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដែលបំរុងចាត់ថ្នាក់ឬត្រូវបានចាត់ថ្នាក់រួចហើយ ត្រូវតែ :

-ជូនដំណឹងជាមុនដល់អ្នកទទួល អំពីស្ថានភាពរបស់សម្បត្តិវប្បធម៌ ។

-ជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីចេញប័ណ្ណលក់ឬផ្ទេរ ដោយបញ្ជាក់ពីគោត្តនាម នាមនិងទីលំនៅនៃអ្នកទទួល ព្រមទាំងកាលបរិច្ឆេទនៃការលក់ឬផ្ទេរនោះ។ បើផ្ទុយពីបទបញ្ញត្តិខាងលើនេះ ការលក់ឬផ្ទេរនឹងត្រូវចាត់ទុកជាមោឃៈ ។

មាត្រា ២២.-

ការលក់ឬផ្ទេរកម្មសិទ្ធិនូវសម្ភារៈឬបំណែកផ្សេងៗ ដែលផ្តាច់ចេញដោយខុសច្បាប់ពីសម្បត្តិវប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ក៏ដូចជារាល់អំពើណាដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិឬកាន់កាប់សម្ភារៈឬផ្នែកណាមួយនៃសម្បត្តិវប្បធម៌ទៅឱ្យអ្នកដទៃ ត្រូវទុកជាមោឃៈនិងអសារឥតការ ។

អ្នកដទៃនោះត្រូវរួមទទួលខុសត្រូវជាមួយម្ចាស់កម្មសិទ្ធិក្នុងការរៀបដាក់កន្លែងដើមវិញនូវសម្ភារៈឬបំណែកដែលខ្លួនបានទទួល ។ ជននោះគ្មានសិទ្ធិនឹងទាមទារជំងឺចិត្តពីរដ្ឋឡើយ ។

មាត្រា ២៣.-

សម្បត្តិវប្បធម៌ដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ពុំអាចត្រូវទទួលការផ្លាស់ប្តូរទីកន្លែង ការបំផ្លិចបំផ្លាញ ការធ្វើអោយខូចខាត ការប្រែរូបរាង ការទទួល ការជួសជុលឬស្តារឡើងវិញ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលជាអ្នកកំណត់លក្ខខណ្ឌនិងត្រួតពិនិត្យការអនុវត្តការងារនោះឡើយ ។

មាត្រា ២៤.-

ម្ចាស់កម្មសិទ្ធិដែលដាក់ពាក្យសុំការអនុញ្ញាតដើម្បីកែប្រែ ជួសជុលសម្បត្តិវប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ត្រូវដាក់គំរោងប្លង់ព្រមទាំងឯកសារផ្សេងៗទៀតជូនអាជ្ញាធរមានសមត្ថកិច្ចពិនិត្យនិងសំរេច ។

មាត្រា ២៥.-

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ត្រូវធានាដល់ការការពារសម្បត្តិវប្បធម៌នោះ ដែលបានចាត់ថ្នាក់រួចហើយ ។

ចំណាយទាំងឡាយលើការជួសជុលឬថែទាំសម្បត្តិវប្បធម៌នោះ គឺជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ។

អាជ្ញាធរមានសមត្ថកិច្ចអាចនឹងចេញសងជាភាគខ្លះ ។ ចំពោះចំណាយទាំងស្រុងជាសមត្ថកិច្ចរបស់គណៈរដ្ឋមន្ត្រី ។

មាត្រា ២៦.-

អាជ្ញាធរមានសមត្ថកិច្ចជាអ្នកត្រួតពិនិត្យនូវការងារជាបន្ទាន់ក្នុងការជួសជុលសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយនិងទុកឱ្យគណៈរដ្ឋមន្ត្រីសំរេច ។

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ខាងលើ មិនអាចប្រឆាំងនឹងការអនុវត្តទាំងនោះបានឡើយ ។

មាត្រា ២៧.-

អនុភាពនៃការចាត់ថ្នាក់នឹងចាប់មានប្រសិទ្ធិភាព ចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីអំពីសំណើសុំចាត់ថ្នាក់ ។

អនុភាពនោះនៅតែមានតំលៃជានិច្ច ទោះបីសម្បត្តិវប្បធម៌នោះត្រូវប្តូរកម្មសិទ្ធិក៏ដោយ ។

## ផ្នែកទី ៥
## សិទ្ធិទិញបានមុនគេនិងសិទ្ធិដកហូតកម្មសិទ្ធិ

មាត្រា ២៨.-

អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិទិញបានមុនគេលើរាល់ការលក់ឬសម្បត្តិវប្បធម៌ដែលចុះបញ្ជីសារពើភណ្ឌរួចហើយ កំពុងស្នើចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ។

ជនណាដែលមានបំណងនឹងលក់សម្បត្តិវប្បធម៌ដែលចែងក្នុងកថាខ័ណ្ឌខាងលើនេះ ត្រូវតែជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការលក់នេះក្នុងរយៈពេល ៣០ថ្ងៃជាមុន ។

**មាត្រា ២៩.-**

ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទនៃការទទួលដំណឹងដែលមានចែងនៅក្នុងមាត្រា ២៨ កថាខ័ណ្ឌទី ២ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់បញ្ជាក់ជាលាយល័ក្ខណ៍អក្សរដល់ម្ចាស់កម្មសិទ្ធិ អំពីការសំរេចចិត្តរបស់ខ្លួនដើម្បីទិញយកឬមិនទិញយកសម្បត្តិវប្បធម៌ដែលស្នើលក់តាមល័ក្ខខ័ណ្ឌនិងតាមថ្លៃកំណត់ ។

ការខកខានមិនបានឆ្លើយតបដោយហួសរយៈពេល ៣០ថ្ងៃ ដូចបានចែងក្នុងកថាខ័ណ្ឌខាងលើនេះ គឺមានន័យថាជាការបោះបង់មិនអនុវត្តសិទ្ធិទិញបានមុនគេ ។

**មាត្រា ៣០.-**

អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតកម្មសិទ្ធិអចលនសម្បត្តិវប្បធម៌ ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌដែលត្រូវបានបំរុងឱ្យធ្វើចំណាត់ថ្នាក់ឬបានធ្វើចំណាត់ថ្នាក់រួចហើយ អាចត្រូវបានដកហូតកម្មសិទ្ធិតាមបែបបទដែលចែងដោយច្បាប់ស្តីពីការដកហូតកម្មសិទ្ធិដើម្បីផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ៦
## ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ

**មាត្រា ៣១.-**

ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុផ្សេងៗ អាចអនុញ្ញាតបានក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះក្រោយពីមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។ បែបបទនៃការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣២.-**

លិខិតអនុញ្ញាតនេះត្រូវចុះជាអាទិ៍ : គោត្តនាម នាម លំនៅឋានពាណិជ្ជករ សមត្ថភាពឯកទេសព្រមទាំងប្រភេទបុរាណវត្ថុនិងមានការបញ្ជាក់ច្បាស់លាស់ពីទីកន្លែងដែលខ្លួនរកបំណងប្រកបអាជីវកម្មនេះ ។ លិខិតអនុញ្ញាតនេះផ្តល់ជូនសំរាប់រយៈពេល ១ឆ្នាំ ព្រមទាំងអាចបន្ត១ឆ្នាំម្តងៗ ហើយពុំអាចបង្វែរទៅឱ្យ ជនដទៃបានឡើយ ។

**មាត្រា ៣៣.-**

រាល់ពាណិជ្ជករដែលមានច្បាប់អនុញ្ញាត ត្រូវប្រកាន់ខ្ជាប់នូវកាតព្វកិច្ចដូចតទៅ ៖

ក-បិទសេចក្ដីប្រកាសបញ្ជាក់ថា ខ្លួនបានទទួលច្បាប់អនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មបុរាណវត្ថុ នៅត្រង់ទ្វារចូលនៃអាគារលក់ដូររបស់ខ្លួន ។

ខ-មិនត្រូវដាក់បុរាណវត្ថុមួយសំរាប់លក់នៅក្រៅអាគារ ដែលខ្លួនបានច្បាប់អនុញ្ញាតឱ្យប្រកបអាជីវកម្ម ។

គ-ចុះជាប្រចាំក្នុងបញ្ជីកត់ត្រាជាលំអិតនូវបុរាណវត្ថុដែលខ្លួនមាននិងសកម្មភាពលក់ចេញ និងទិញចូលរាល់ថ្ងៃ ។

ឃ-ត្រូវបង្ហាញដល់ភ្នាក់ងារត្រួតពិនិត្យនូវសៀវភៅបញ្ជីខាងលើនេះ រាល់ពេលណាដែលភ្នាក់ងារទាំងនោះទាមទារពិនិត្យ ។

ង-ត្រូវបិទបញ្ញត្តិគ្រប់ប្រការស្ដីពីការនាំចេញបុរាណវត្ថុ នៅនឹងអាគារលក់ដូររបស់ខ្លួនត្រង់កន្លែងដែលងាយមើលឃើញ ។

ច-បង្ហាញបុរាណវត្ថុទាំងអស់ដែលខ្លួនមានចំពោះភ្នាក់ងារត្រួតពិនិត្យតាមសំណូមពររបស់ភ្នាក់ងារ ។

ឆ-ផ្ដល់ទៅភ្នាក់ងារត្រួតពិនិត្យនូវរូបថតបុរាណវត្ថុទាំងឡាយណាក៏ដោយដែលខ្លួនមានឬអនុញ្ញាតឱ្យភ្នាក់ងារនោះ ថតរូបណាមួយដែលគេចង់បាន ។

ជ-បង្កលក្ខណៈងាយស្រួលដល់ភ្នាក់ងារត្រួតពិនិត្យនៅក្នុងពេលធ្វើអធិការកិច្ច ។

ឈ-ជូនពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីដែលមានការប្ដូរទីកន្លែងលក់ដូររបស់ខ្លួន។

**មាត្រា ៣៤.-**

ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅក្នុងអាគារលក់ដូរ ហើយធ្វើការត្រួតពិនិត្យកត់ត្រាសម្បត្តិវប្បធម៌ដែលមាននៅក្នុងអាគារលក់ទាំងនោះនិងផ្ទៀងផ្ទាត់បញ្ជីនៅគ្រប់ពេលដែលអធិការដ្ឋានយល់ឃើញថាជាការគួរនឹងធ្វើអធិការកិច្ច ។

ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅធ្វើការត្រួតពិនិត្យក្នុងលំនៅឋានរបស់ពាណិជ្ជករ បើសិនជាលំនៅឋាននោះត្រូវប្រើធ្វើជាឃ្លាំងឬអាគារលក់ ស្របទៅតាមខ្លឹមសារនៃសេចក្ដីអនុញ្ញាតដែលចេញអោយពាណិជ្ជករនោះ ។

មាត្រា ៣៥.-

អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតលិខិតអនុញ្ញាតធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ ពេលដែលពិនិត្យឃើញម្ចាស់ដែលមានការអនុញ្ញាតនោះធ្វេសប្រហែសឬរំលោភទៅលើកាតព្វកិច្ចណាមួយ ឬដោយសារតែអ្នកនោះបានទទួលការផ្តន្ទាទោសពីតុលាការមានសមត្ថកិច្ចដោយហេតុថា ខ្លួនបានប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៣៦.-

នៅពេលដែលលិខិតអនុញ្ញាតត្រូវបានដកហូត ដូចមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ៣៥នោះ ពាណិជ្ជករលែងមានសិទ្ធិទិញបុរាណវត្ថុទៀតហើយ ។

ពាណិជ្ជករនោះនឹងត្រូវអនុញ្ញាតឱ្យលក់បុរាណវត្ថុដែលខ្លួនកំពុងកាន់កាប់នៅឡើយក្នុងរយៈពេលមួយមិនលើសពី ៦ខែ ។

## ជំពូកទី ៧

### ការប្រទះឃើញដោយចៃដន្យ

មាត្រា ៣៧.-

នៅពេលកំពុងដំណើរការងារផ្សេងៗឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ដូចជាប្រាសាទបាក់បែក វត្តបុរាណ សំណល់ផ្ទះសំបែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹកឬសម្បត្តិវប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រដែលសិក្សាពីអតីតកាលឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះនិងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់ ។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង ។ អភិបាលខេត្ត ក្រុង ត្រូវជូនពត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌និងរមណីយដ្ឋានវប្បធម៌នោះ ។

**មាត្រា ៣៨.-**

ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គិតចាប់តាំងពីថ្ងៃទទួលសេចក្ដីរាយការណ៍ដូចមានចែងក្នុងមាត្រា ៣៧ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ជាលាយលក្ខណ៍អក្សរស្ដីពីការផ្អាកជាបណ្ដោះអាសន្ននូវការងារជួលជុលឬសាងសង់និងស្ដីពីវិធានការសង្គ្រោះដែលត្រូវអនុវត្ត ។

បើក្នុងរយៈពេល ៣០ថ្ងៃ អាជ្ញាធរមានសមត្ថកិច្ចមិនបានធ្វើកំណត់ជាលាយលក្ខណ៍អក្សរជូនដំណឹងទៅម្ចាស់អចលនវត្ថុទេនោះ ការផ្អាកជាបណ្ដោះអាសន្នត្រូវទុកជាអាសាបង់។

អាជ្ញាធរមានសមត្ថកិច្ចត្រូវសំរេចជាស្ថាពរនូវវិធានការចំពោះការប្រទះឃើញដោយចៃដន្យ។

**មាត្រា៣៩.-**

សម្បត្តិវប្បធម៌ជាចលនវត្ថុដែលប្រទះឃើញដោយចៃដន្យត្រូវចាត់ទុកជាសម្បត្តិសាធារណៈ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្ដល់រង្វាន់លើកទឹកចិត្តដល់អ្នកប្រទះឃើញ ដោយចៃដន្យដោយកំណត់តាមការស្រុះស្រួលគ្នាឬតាមការវាយតំលៃរបស់អ្នកជំនាញ ក្នុងរយៈពេលបីសប្ដាហ៍ក្រោយពីបានរកឃើញ។

## ជំពូកទី ៨

### ការជីករុករកវត្ថុបុរាណ

**មាត្រា ៤០.-**

គ្មានជនណាមួយអាចធ្វើការជីករុករកឬធ្វើការវាស់ស្ទង់លើដីឬក្រោមដី ក្នុងគោលបំណងស្រាវជ្រាវរកសម្បត្តិវប្បធម៌ដែលមានផលប្រយោជន៍ដល់ការសិក្សាខាងបុរេប្រវត្តិវិទ្យា ប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យាឬសាខានៃវិទ្យាសាស្ត្រផ្សេងៗ ដែលសិក្សាពីអតីតកាលឬទាក់ទងដល់មនុស្សសាស្ត្រដោយមិនបានទទួលច្បាប់អនុញ្ញាតិជាមុនពីសមត្ថកិច្ចឡើយ។

**មាត្រា ៤១.-**

មានតែស្ថាប័នវិទ្យាសាស្ត្រដែលមានជំនាញ មានបទពិសោធន៍និងមានធនធានគ្រប់គ្រាន់ហើយដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទទួលស្គាល់ទេ ទើបអាចអនុញ្ញាតិឱ្យធ្វើការរុករកវត្ថុបុរាណបាន។

ស្ថាប័នវិទ្យាសាស្ត្របរទេសដែលបានទទួលច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករក ត្រូវតែសហការជាមួយស្ថាប័នវិទ្យាសាស្ត្រជាតិ ក្នុងការអនុវត្តការងាររបស់ខ្លួន ។

## មាត្រា ៤២.-

ស្ថាប័នវិទ្យាសាស្ត្រដែលទទួលបានច្បាប់អនុញ្ញាតអោយធ្វើការជីករុករក ត្រូវតែ :

ក-កត់ត្រាសម្បត្តិវប្បធម៌ដែលរកឃើញនៅក្នុងបញ្ជីពិសេសមួយ ហើយត្រូវប្រគល់ជូនដល់អាជ្ញាធរមានសមត្ថកិច្ចនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ខ-ការពារទីលានជីករុករកបុរាណវត្ថុនិងសម្បត្តិវប្បធម៌ដែលរកឃើញ ព្រមទាំងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងដើម្បីថែរក្សានិងការពារ ។

គ-ជូនពត៌មានឱ្យទៀងទាត់ដល់អាជ្ញាធរមានសមត្ថកិច្ច ស្ដីពីការប្រព្រឹត្តទៅនៃប្រតិបត្តិការជីករុករកវត្ថុបុរាណ ។

ឃ-ធ្វើរបាយការណ៍សង្ខេបរួមទាំងសៀវភៅរូបថតសម្បត្តិវប្បធម៌ទាំងអស់ដែលបានរកឃើញនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ង-ធ្វើរបាយការណ៍វិទ្យាសាស្ត្រមួយលំអិតស្ដីពីលទ្ធផលជីករុករកក្នុងកំណត់មួយមិនហួសពីមួយឆ្នាំ គិតចាប់តាំងពីការបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ច-អនុញ្ញាតឱ្យភ្នាក់ងារនៃអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យមើលការជីករុករកសម្បត្តិវប្បធម៌រាល់តំរូវការរបស់អាជ្ញាធរនោះ ព្រមទាំងពិនិត្យបញ្ជីពិសេសដូចមានចែងក្នុងកថាខ័ណ្ឌ " ក " ។

ឆ-អនុញ្ញាតឱ្យអ្នកស្រាវជ្រាវដទៃទៀតចូលធ្វើការស្រាវជ្រាវ ក្នុងលក្ខខ័ណ្ឌដែលពួកអ្នកស្រាវជ្រាវទាំងនោះសុខចិត្តគោរពសិទ្ធិកម្មសិទ្ធិរបស់ស្ថាប័នវិទ្យាសាស្ត្រនោះ ។

ជ-ជួយអប់រំបណ្ដុះបណ្ដាលអ្នកបច្ចេកទេស វិទ្យាសាស្ត្រនៅក្នុងស្រុក ។

ឈ-បោះពុម្ពផ្សាយលទ្ធផលវិទ្យាសាស្ត្រស្ដីពីការជីករុករកវត្ថុបុរាណដែលធ្វើក្នុងកំឡុងពេលប្រាំឆ្នាំ បន្ទាប់ពីការបញ្ចប់នៃការងារ ។

## មាត្រា ៤៣.-

ស្ថាប័នវិទ្យាសាស្ត្រដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជីករុករកបុរាណវត្ថុ មានសិទ្ធិ

ក-ជាម្ចាស់កម្មសិទ្ធិវិទ្យាសាស្ត្រ ចំពោះវត្ថុដែលបានរកឃើញ ។

ខ-ជាម្ចាស់កម្មសិទ្ធិនៃសម្បត្តិវប្បធម៌ដែលខ្លួនអាចបានទទួលក្នុងល័ក្ខខ័ណ្ឌដែលមានចែង ក្នុងមាត្រា ៤៤ កថាខ័ណ្ឌទី ២ ។

គ-ទទួលអាទិភាពក្នុងការផ្សាយលទ្ធផលវិទ្យាសាស្ត្រនៃការជីករុករកក្នុងល័ក្ខខ័ណ្ឌដែល លទ្ធផលនោះ ត្រូវផ្សាយក្នុងរយៈពេលដូចមានចែងក្នុងមាត្រា ៤២ ចំណុច " ឈ " ។

**មាត្រា ៤៤.-**

សម្បត្តិវប្បធម៌ទាំងចលនវត្ថុនិងអចលនវត្ថុ ដែលបានរកឃើញដោយស្ថាប័នវិទ្យាសាស្ត្រ គឺជាសម្បត្តិសាធារណៈ ។

អាជ្ញាធរមានសមត្ថកិច្ចអាចជូនដល់ស្ថាប័នវិទ្យាសាស្ត្រនេះបាននូវវត្ថុបុរាណមួយដែលដូច គ្នាទាំងស្រុងនិងវត្ថុដែលមានរួចហើយ ព្រមទាំងវត្ថុណាដែលមិនមែនជាវត្ថុចាំបាច់ដោយហេតុថា មាន រក្សាទុករួចហើយនូវវត្ថុដែលមានលក្ខណៈដូចគ្នាបេះបិទនឹងវត្ថុដែលរកឃើញនោះ ទាំងខាងប្រភេទ រចនាបទ វត្ថុធាតុ របៀបផលិត ក៏ដូចជាមានតំលៃខាងវិទ្យាសាស្ត្រឬសិល្បៈ។ ការផ្តល់ជូននេះអាចធ្វើបាន តែក្នុងល័ក្ខខ័ណ្ឌដែលសម្បត្តិវប្បធម៌នេះត្រូវបានយកមកតម្កល់ទុកក្នុងស្ថាប័នវិទ្យាសាស្ត្របច្ចេកទេសសំរាប់ សាធារណជន ។

**មាត្រា ៤៥.-**

អាជ្ញាធរមានសមត្ថកិច្ចធានារ៉ាប់រងត្រួតពិនិត្យការជីករុករកនិងជួយចាត់វិធានការចាំបាច់ ដើម្បីការពារបរិវេណការដ្ឋាននោះ ។

**មាត្រា ៤៦.-**

អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតអោយធ្វើការជីករុករកនៅលើដីជាកម្មសិទ្ធិឯកជន បន្ទាប់ពីបានជូនដំណឹងជាមុនដល់ម្ចាស់កម្មសិទ្ធិ ។

អ្នកជីករុករកត្រូវធ្វើបញ្ជីសារពើភណ្ឌទីកន្លែងដែលនឹងជីករុករកនោះ ហើយលុះត្រាតែបាន ទទួលការស្រុះស្រួលពីភាគីទាំងអស់ ទើបអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនបាន ។

អ្នកជីករុករកបុរាណវត្ថុត្រូវធ្វើការងារនោះក្នុងរយៈពេលពីរឆ្នាំ ហើយនឹងអាចបន្តទៅ ទៀតបាន ក្រោយរយៈពេលពីរឆ្នាំនេះ ។

**មាត្រា ៤៧.-**

ម្ចាស់កម្មសិទ្ធិ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤៦ មានសិទ្ធិនឹងកាន់កាប់ដីឡើងវិញ និងទទួលបាននូវប្រាក់បំណាច់ចំពោះការខកខានពុំបានស្នាក់អាស្រ័យនៅប្រកបមុខរបរនិងចំពោះការបង់ខាត ឬខូចខាតផ្សេងៗទៀតដោយថាហេតុ ។

**មាត្រា៤៨.-**

ក្នុងករណីដែលប្រទះឃើញសម្បត្តិវប្បធម៌ជាអចលនវត្ថុ អាជ្ញាធរមានសមត្ថកិច្ចអាចប្រើសិទ្ធិដកហូតស្របតាមច្បាប់ស្តីពីការដកហូតកម្មសិទ្ធិ ដោយយោងទៅលើផលប្រយោជន៍សាធារណៈ។

**មាត្រា ៤៩.-**

ក្នុងករណីដែលអ្នកមានច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករកបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចណាមួយដូចមានចែងក្នុងមាត្រា ៤២ អាជ្ញាធរមានសមត្ថកិច្ចអាចសំរេចដកហូតច្បាប់អនុញ្ញាតឬនិងសិទ្ធិលើកម្មសិទ្ធិវិទ្យាសាស្ត្រនោះមកវិញបាន ។

ការជីករុករកត្រូវផ្អាកសកម្មភាពភ្លាម គិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរស្តីពីការដកហូតច្បាប់អនុញ្ញាតមកវិញ ។

**មាត្រា ៥០.-**

នៅពេលដែលច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករកត្រូវបានដកហូតមកវិញហើយ អ្នកបានច្បាប់អនុញ្ញាតនោះមិនអាចទាមទារថ្ងៃសងជំងឺចិត្តណាមួយ បណ្តាលមកពីការបញ្ឈប់ការរុករកឬសោហ៊ុយដែលខ្លួនបានចំណាយនោះឡើយ ។

## ផ្នែកទី ៩

## ការនាំចេញសម្បត្តិវប្បធម៌

**មាត្រា ៥១.-**

ការនាំចេញសម្បត្តិវប្បធម៌ណាមួយទៅក្រៅដែនដីកម្ពុជាត្រូវហាមឃាត់បើសិនជាគ្មានអាជ្ញាប័ណ្ណពិសេសដើម្បីនាំចេញសម្បត្តិវប្បធម៌ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចទេនោះ ។

មាត្រា ៥២.-

អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញសេចក្តីសំរេចក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃដែលអ្នកសុំនាំចេញ បានបំពេញទំរង់បែបបទជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់សព្វគ្រប់ហើយ ។

មាត្រា ៥៣.-

ការនាំចេញសម្បត្តិវប្បធម៌ត្រូវបង់ពន្ធនិងអាករផ្សេងៗ ។

ការកំរិតប្រាក់ពន្ធនិងអាករលើសម្បត្តិវប្បធម៌ត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៥៤.-

មុននឹងផ្តល់អាជ្ញាប័ណ្ណនាំចេញណាមួយ អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាអោយបានច្បាស់ថា :

ក-ការនាំចេញនឹងមិនបណ្តាលឱ្យខូចខាតខ្សោយធនធានបេតិកភណ្ឌវប្បធម៌ជាតិឡើយ។

ខ-សមុច្ច័យសាធារណៈនៅមានសម្បត្តិវប្បធម៌ដែលមានរូបរាងដូចគ្នាទៅនឹងសម្បត្តិ-វប្បធម៌ ដែលត្រូវបានស្នើសុំធ្វើការនាំចេញ ។

គ-សម្បត្តិវប្បធម៌ដែលអនុញ្ញាតឱ្យនាំចេញ មិនមែនជាវត្ថុដែលមានតំលៃខ្ពស់សំរាប់ផ្នែកពិសេសណាមួយនៃការសិក្សាអំពីវិទ្យាសាស្ត្រអតីតកាលឬវិទ្យាសាស្ត្រមនុស្សទូទៅនោះទេ ។ បែបបទនាំចេញសម្បត្តិវប្បធម៌ ប្រភេទសម្បត្តិវប្បធម៌ដែលត្រូវអនុញ្ញាតឱ្យនាំចេញនិងប្រភេទសម្បត្តិវប្បធម៌ដែលមិនអនុញ្ញាតឱ្យនាំចេញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៥.-

អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញអាជ្ញាប័ណ្ណសំរាប់ការនាំចេញសម្បត្តិវប្បធម៌ដូចតទៅ :

-សម្បត្តិវប្បធម៌ដែលបានឱ្យដល់ស្ថាប័នវិទ្យាសាស្ត្របរទេស ដែលមានការអនុញ្ញាតឱ្យធ្វើការជីករុករកស្របតាមមាត្រា ៤៤ កថាខ័ណ្ឌទី ២

-សម្បត្តិវប្បធម៌ដែលបញ្ជូនទៅបរទេសសំរាប់មួយរយៈពេល ដើម្បីតាំងពិពរណ៍ឬក្នុងទិសដៅសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ

-សម្បត្តិវប្បធម៌ជាថ្នូរជាមួយសម្បត្តិមកពីសារមន្ទីរឬស្ថាប័នបរទេស

-សម្បត្តិវប្បធម៌នាំចូលស្របច្បាប់មកក្នុងទឹកដីកម្ពុជា

ប៉ុន្តែក្នុងករណីសម្បត្តិវប្បធម៌ដូចរៀបរាប់ក្នុងកថាខ័ណ្ឌទី ១ ត្រង់ចំណុចទី២ នៃមាត្រានេះ ការនាំចេញមួយរយៈពេលត្រូវតែគោរពល័ក្ខខ័ណ្ឌផ្សេងៗ ដើម្បីធានាកុំឱ្យមានការខូចខាតព្រមទាំងការបញ្ជូនមកវិញនូវសម្បត្តិវប្បធម៌ទាំងនោះ ។

**មាត្រា ៥៦.-**

ការប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានអាជ្ញាប័ណ្ណត្រូវឃាត់ទុកនិងរឹបអូសសម្បត្តិវប្បធម៌ទាំងនោះ ទុកជាសម្បត្តិសមូហ៍សាធារណៈ ។

**មាត្រា ៥៧.-**

អាជ្ញាធរមានសមត្ថកិច្ចអាចទាមទារយកពាល់សម្បត្តិវប្បធម៌ដែលមានការទំនាស់មិនឱ្យនាំចេញ ដោយសារមានហេតុផលសំខាន់ៗផ្សេងធ្វើឱ្យមានការសង្ស័យថាប៉ុនប៉ងនាំចេញដោយខុសច្បាប់។ សម្បត្តិវប្បធម៌ទាំងនេះត្រូវបញ្ចូលជាសម្បត្តិសមូហ៍សាធារណៈ ដោយមានការទូទាត់តំលៃតាមការស្រុះស្រួលគ្នា ឬតាមការវាយតំលៃរបស់អ្នកជំនាញការ ។

## ផ្នែកទី ១០

## ការនាំចូលសម្បត្តិវប្បធម៌

**មាត្រា ៥៨.-**

ការនាំចូលសម្បត្តិវប្បធម៌ដែលបាននាំចេញដោយល្មើសនឹងច្បាប់របស់ប្រទេសដើមត្រូវហាមឃាត់ ។ បែបបទនាំចូលសម្បត្តិវប្បធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៩.-**

សម្បត្តិវប្បធម៌ដែលនាំចូលដោយខុសច្បាប់ ត្រូវឃាត់ទុកនិងដាក់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច ។ ឈរលើគោលការណ៍បដិការ រាជរដ្ឋាភិបាលអាចចេញសេចក្តីសំរេចប្រគល់សម្បត្តិវប្បធម៌នោះទៅប្រទេសដើមវិញស្របតាមកិច្ចព្រមព្រៀងនិងច្បាប់អន្តរជាតិ ។

**មាត្រា ៦០.-**

ចំណាយដែលពាក់ព័ន្ធទៅនឹងការបញ្ជូនសម្បត្តិវប្បធម៌ទៅវិញ គឺជាបន្ទុករបស់រដ្ឋដែលទាមទារ។

**មាត្រា ៦១.-**

សម្បត្តិវប្បធម៌ដែលនាំចូលស្របច្បាប់ ត្រូវតែប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ ។

បង្កាន់ដៃដែលទីចាត់ការគយចេញឱ្យម្ចាស់កម្មសិទ្ធិជាភស្តុតាងនោះ ត្រូវយកមកបង្ហាញភ្នាក់ងារគយឡើងវិញ នៅពេលត្រូវនាំរបស់នោះចេញសាជាថ្មី ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៦២.-**

សេចក្តីសំរេចរបស់រាជ្ញាធរមានសមត្ថកិច្ចដោយយកច្បាប់នេះជាមូលដ្ឋាន អាចបើកលទ្ធភាពឱ្យតវ៉ាបានចំពោះមុខតុលាការ ។

**មាត្រា ៦៣.-**

ក-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ខែ ទៅ ៥ឆ្នាំ ព្រមទាំងពិន័យជាទឹកប្រាក់តាមតម្លៃដែលអ្នកជំនាញបានប៉ាន់ស្មាន ចំពោះជនណាដែលបានប្រព្រឹត្តល្មើសដោយធ្វេសប្រហែសក្នុងប្រការដូចរៀបរាប់ខាងក្រោមនេះ :

-លក់ឬផ្ទេរកម្មសិទ្ធិ ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលស្ថាបនាឡើងវិញនូវសម្បត្តិវប្បធម៌ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ដោយមិនបានជូនដំណឹងជាមុន (មាត្រា ២៩ កថាខ័ណ្ឌទី ១) ។

-លក់ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដែលបានស្នើអោយចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ ( មាត្រា ២១ និង ២៨ កថាខ័ណ្ឌទី ២ ) ។

-ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលដោយគ្មានការអនុញ្ញាតនូវសម្បត្តិវប្បធម៌ដែលបានស្នើឱ្យចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ(មាត្រា២៣កថាខ័ណ្ឌទី១)៖

-មិនបានរក្សាការពារដោយត្រឹមត្រូវនូវសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយដែលខ្លួនជាម្ចាស់កម្មសិទ្ធិ (មាត្រា ២៥ កថាខ័ណ្ឌទី ១) ។

-ធ្វើឬប៉ុនប៉ងធ្វើដោយគ្មានច្បាប់អនុញ្ញាតនូវការងារទាំងឡាយណាដែលច្បាប់តំរូវឱ្យមានការអនុញ្ញាត ( មាត្រា ៣១ និង ៤០ ) ។

-មិនបានបំពេញកាតព្វកិច្ចដែលត្រូវខ្លួនអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៣៣ និង ៤២ ។

-មិនបានប្រកាសអំពីការរកឃើញសម្បត្តិវប្បធម៌ នៅក្នុងអំឡុងពេលសាងសង់និងមិនបានបញ្ឈប់ការងារនោះភ្លាម ( មាត្រា ៣៧ ) ។

-នាំចេញឬប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានការអនុញ្ញាត(មាត្រា ៥១ និង ៥៦)។

-មិនអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់នៃការនាំចេញមួយរយៈ (មាត្រា ៥៥ កថាខ័ណ្ឌទី ២)។

-នាំចូលសម្បត្តិវប្បធម៌ដោយខុសច្បាប់ ( មាត្រា ៥៨ ) ។

-មិនបានប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ អំពីការនាំចូលដោយស្របច្បាប់នូវសម្បត្តិវប្បធម៌ ( មាត្រា ៦១ កថាខ័ណ្ឌទី ១ ) ។

ខ-ជនណាដែលប្រព្រឹត្តបទល្មើសដោយចេតនាដូចចំណុចរៀបរាប់ខាងលើ ត្រូវទទួលទោសជាប់ពន្ធនាគារពី ២ឆ្នាំដល់ ៥ឆ្នាំនិងពិន័យទ្វេគុណនៃតម្លៃសម្បត្តិវប្បធម៌នោះតាមតំលៃដែលអ្នកជំនាញបានប៉ាន់ស្មាន ។

ក្នុងករណីខ្លះដូចមានចែងក្នុងចំណុច(កនិងខ)ខាងលើនេះ ទោសនេះគ្រាន់តែជាប់ពន្ធនាគារឬគ្រាន់តែបង់ប្រាក់ពិន័យ ។

**មាត្រា ៦៤.-**

ទុកបំរុងនៅដដែលនូវបទល្មើសពីទោសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ៦៣ ពិរុទ្ធបាលដែលបញ្ញត្តិក្នុង មាត្រា ២១ , ២២ , ៣៥ , ៤៩ , ៥៦ , និង ៥៩ ត្រូវតម្កល់ទុកដដែល ។

មាត្រា ៦៥.-

បទល្មើសទាំងឡាយត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសភ្នាក់ងារគយដែលបានធ្វើសម្បថព្រមទាំងដោយមន្ត្រីអភិរក្ស និងបុគ្គលិកដទៃទៀតនៃសារមន្ទីរសាធារណៈ ដែលត្រូវបានចាត់តាំងនិងបានធ្វើសម្បថចំពោះការងារនេះ។

# ជំពូកទី ៣

## អវសានប្បញ្ញត្តិ

មាត្រា ៦៦.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦៧.-

ច្បាប់នេះ ត្រូវប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ
វប្បធម៌និងវិចិត្រសិល្បៈ រៀបចំ
ទីកដីនគរូបនីយកម្ម និង សំណង់

វណ្ណ មូលីវណ្ណ

# ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស រកត ១២៩៧ ៩១**

**ស្តីពី**

**លក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-០១៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស-រកម-១២០៥-០៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦
- តាមសេចក្តីក្រាបបង្គំទូលស្នើ ពីនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ និងពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានីតិបុគ្គលនៃច្បាប់សាធារណៈដែលទទួលបន្ទុកចម្បង នូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈ រដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬបច្ចេកទេស ។

**មាត្រា ២.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពហិរញ្ញវត្ថុ ។ ក្នុងក្របខ័ណ្ឌនេះ គ្រឹះស្ថានត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

១- មាននាមករណ៍ និងទីស្នាក់ការ

២- មានកម្មវត្ថុ ដែលកំណត់ពីប្រភេទសកម្មភាព

៣- មានក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងដោយឡែក

៤- មានថវិការផ្ទាល់ខ្លួន

៥- មានទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាព ដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់គ្រឹះស្ថាន

៦- មានសម្តតភាពចុះកិច្ចសន្យា និងប្តឹង ឬការពារនៅតុលាការ

៧- ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និង រដ្ឋប្បវេណីលើទង្វើរបស់អ្នកតំណាងស្របច្បាប់ ឬនិយោជិតរបស់ខ្លួនក្នុងពេលបំពេញការងារជូនគ្រឹះស្ថាន ។

**មាត្រា ៣.-**

៣.១ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានបង្កើតឡើងដោយអនុក្រិត្យតាមសំណើរួម របស់ក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣.២ អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាននេះ ត្រូវកំណត់ជាពិសេសនូវបេសកកម្ម បុព្វសិទ្ធិកាតព្វកិច្ចសមាសភាពនៃក្រុមប្រឹក្សាភិបាល ព្រមទាំងវិធានពិសេសសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យលើគ្រឹះស្ថាន ។ អនុក្រឹត្យនេះ ត្រូវបញ្ជាក់ផងដែរនូវក្រសួង ឬអាជ្ញាធរ ដែលជាអាណាព្យាបាល ។

៣.៣ ការប្រព្រឹត្តទៅរបស់គ្រឹះស្ថានត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ដែលរៀបចំនិងស្នើឡើងដោយប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បទបញ្ជាផ្ទៃក្នុងត្រូវភ្ជាប់ជាឧបសម្ព័ន្ធជាមួយអនុក្រឹត្យ ស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**មាត្រា ៤.-**

៤.១ បទបញ្ជាផ្ទៃក្នុងអាចកែសម្រួលក្រោយពេលបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយក្រុមប្រឹក្សាភិបាល ហើយត្រូវមានការយល់ព្រមពីប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៤.២ ការបញ្ចូលគ្នា ការបែកចេញ ការប្រែប្រួល ឬការរំសាយពាក់ព័ន្ធដល់គ្រឹះស្ថាន ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរួម របស់ក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤.៣ ក្នុងករណីត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយអនុក្រឹត្យ ទ្រព្យសកម្មដែលជាចលនវត្ថុ និងអចលនវត្ថុរបស់គ្រឹះស្ថាន ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ។ ចំពោះទ្រព្យសម្បត្តិជារូបិយវត្ថុត្រូវបង្វិលចូលរតនាគារជាតិ ។

## ជំពូកទី២
## រដ្ឋបាល និងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា ៥.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ក្នុងនាមរបស់គ្រឹះស្ថានសម្រាប់ចាត់ចែងការងារ ក្នុងក្របខ័ណ្ឌនៃកម្មវត្ថុរបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ។

**មាត្រា ៦.-**

៦.១ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានសមាជិកយ៉ាងតិច ០៥ រូប និងយ៉ាងច្រើន ១១ រូប ដែលក្នុងនោះជាចាំបាច់ត្រូវមានៈ

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តំណាងក្រសួងអាណាព្យាបាលបច្ចេកទេស
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី

៦.២ បុគ្គលិករបស់គ្រឹះស្ថាន ត្រូវមានអាសនៈមួយកន្លែងនៅក្នុងក្រុមប្រឹក្សាភិបាល ។ តំណាងនេះ ជាសមាជិកស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយបុគ្គលិក ក្នុងចំណោមបុគ្គលិកសម្រាប់ រយៈពេលយ៉ាង យូរ ០៣ ឆ្នាំ អាស្រ័យទម្រង់បែបបទកំណត់ដោយក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន ។ អាណត្តិរបស់តំណាង បុគ្គលិកអាចបន្តជាថ្មីទៀតបាន ។ តំណាងនេះស្ថិតនៅក្នុងក្រុមប្រឹក្សាភិបាល ចាប់ពីថ្ងៃជាប់ឆ្នោតដោយមិន ចាំបាច់មានការតែងតាំងឡើយ ។ នៅពេលចប់អាណត្តិតំណាងនេះ ត្រូវអស់សិទ្ធិចូលរួមក្នុងក្រុមប្រឹក្សាជាស្វ័យប្រវត្តិ ។

៦.៣ អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចគ្រោងសមាជិកស្វ័យប្រវត្តិ ដទៃទៀតក្នុងក្រុមប្រឹក្សាភិបាល ។ សមាជិកស្វ័យប្រវត្តិនេះស្ថិតក្នុងក្រុមប្រឹក្សាភិបាល ចាប់ពីថ្ងៃតែងតាំងមុខងារដែលខ្លួនអាចចូលរួមក្នុងក្រុមប្រឹក្សាភិបាល ដោយមិនចាំបាច់ឲ្យសច្ចាប័ន ការចូលរួមនេះដោយអនុក្រឹត្យទេ ។ សមាជិកស្វ័យប្រវត្តិទាំងនេះបំពេញអាណត្តិក្នុងរយៈពេលដែលខ្លួនកាន់កាប់មុខងារ ។

៦.៤ សមាជិកក្រុមប្រឹក្សាភិបាល ក្រៅពីសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់រយៈពេល ០៣ឆ្នាំ រៀបចំដោយក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់

ក្រសួងអាជ្ញាធរដែលសមាជិកទាំងនោះតំណាងឲ្យ ។ សមាជិកក្រុមប្រឹក្សាភិបាលទាំងឡាយ ត្រូវបានជ្រើសតាំង ដោយផ្អែកតាមលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ក្នុងចំណោមមន្ត្រីរាជការបម្រើការងារយ៉ាងតិច ០៥ឆ្នាំ ឬអ្នកចូលនិវត្តន៍ ឬក្នុងចំណោមឥស្សរជនខ្មែរ ដែលត្រូវបានទទួលស្គាល់ថាមានសមត្ថភាពខាង ផ្នែកសេដ្ឋកិច្ច នីតិសាស្ត្រ និងខាងវិទ្យាសាស្ត្រ ។ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ។

នៅគ្រប់កាលៈទេសៈ ការបញ្ចប់អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់អាជ្ញាធរដែលសមាជិកនោះតំណាងឲ្យ ។

៦.៥ ប្រធានក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ ក្នុងចំណោមសមាជិក ក្រុមប្រឹក្សាភិបាល តាមសំណើរបស់ក្រសួងអាណាព្យាបាលបច្ចេកទេស ។

៦.៦ មុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល មានវិសមិតភាពជាមួយមុខងារជាសមាជិកសភា ឬជាសមាជិករដ្ឋាភិបាល ។

៦.៧ បុគ្គលម្នាក់ ពុំអាចត្រូវតែងតាំងក្នុងក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬក្រុមប្រឹក្សាភិបាលរបស់អាណាព្យាបាលរបស់សហគ្រាសសាធារណៈណាមួយលើកពី ០២កន្លែងឡើយ ។

៦.៨ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងក្របខ័ណ្ឌ នៃការអនុវត្តន៍បេសកម្មជាសមាជិកក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវជាបន្ទុករបស់រដ្ឋ លើកលែងតែករណីដែលសមាជិកធ្វើកំហុសដោយចេតនា ឬប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់យ៉ាងច្បាស់ក្រឡែត ។ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌត្រូវជាបន្ទុកផ្ទាល់របស់សមាជិកនីមួយៗ ។

**មាត្រា ៧.-**

៧.១ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកសម្រេចជាគោលការណ៍ចំពោះលាភការ នៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលដែលពុំគោរពនូវកាតព្វកិច្ចនៃអាណត្តិរបស់ខ្លួនៈ

១- ការឧស្សាហ៍ព្យាយាម

២- គោរពបទប្បញ្ញត្តិនៃច្បាប់ បទបញ្ជារបស់គ្រឹះស្ថាន

៣- មិនបានបំពេញភារកិច្ចតាមចំណាត់តាំងរបស់ខ្លួន

៤- កាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ។

**មាត្រា ៨.-**

ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិស្ដីពី ការអនុវត្តអាណាព្យាបាលភាពរបស់រដ្ឋ ក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់នូវបេសកម្មទូទៅមួយ សម្រាប់ការតម្រង់ទិសនិងការត្រួតពិនិត្យគ្រឹះស្ថាន ។ ក្នុងក្របខ័ណ្ឌនេះក្រុមប្រឹក្សាភិបាលត្រូវៈ

- សម្រេចលើចំណូល និងចំណាយប្រចាំឆ្នាំ និងលើថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- ពិនិត្យសម្រេចលើរបាយការណ៍គ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះផ្សេងៗដទៃទៀត

- ផ្សព្វផ្សាយដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការដែលមានគ្រោងក្នុងអនុក្រឹត្យ ស្តីពីការបង្កើតគ្រឹះស្ថាន ឬក្នុងបទបញ្ជាផ្ទៃក្នុង ហើយចាត់ការបង្កើតគណៈកម្មការ និងគណៈកម្មការប្រសិនបើមានការចាំបាច់
- កំណត់នូវមែបបទធ្វើការជ្រើសរើស ការតំឡើងឋានន្តរសក្តិ ឬការផ្តល់លាភការ ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ ឬ បទបញ្ជាពាក់ព័ន្ធដល់ប្រយោជន៍បុគ្គលិករបស់គ្រឹះស្ថាន
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់គ្រឹះស្ថាន
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្ម
- ធ្វើការវាយតំលៃតាមចន្លោះពេលទៀងទាត់ នូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត ។

**មាត្រា ៩ -**

៩.១ អនុលោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ក្រុមប្រឹក្សាភិបាលអាចផ្ទេរ អំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃរបស់គ្រឹះស្ថានទៅឲ្យប្រធាន ឬនាយករបស់គ្រឹះស្ថានតែការផ្ទេរអំណាចនេះពុំមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

៩.២ ការបែងចែកអំណាច ត្រូវបញ្ជាក់ថាប្រធាន ឬនាយក ត្រូវបានទទួលអំណាចទាំងអស់ ដែលចាំបាច់សម្រាប់ដំណើរការគ្រឹះស្ថានប្រចាំថ្ងៃ លើកលែងតែអំណាចដែលក្រុមប្រឹក្សាភិបាល យល់ឃើញថាត្រូវរក្សាទុក ហើយអំណាចទាំងនេះ ត្រូវរៀបរាប់ឲ្យបានច្បាស់ ។ អំណាចពីរប្រភេទដែលក្រុមប្រឹក្សាត្រូវរក្សាទុកគឺ:

ក- អំណាចដែលកំណត់ក្នុងមាត្រា៨ខាងលើ ដែលជាអំណាចក្នុងសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល ។

ខ- អំណាចទាំងឡាយដែលការបែងចែក អាស្រ័យលើការកំណត់ផ្ទាល់របស់ក្រុមប្រឹក្សាភិបាល។

យោលទៅតាមប្រភេទសកម្មភាព និងទំហំរបស់គ្រឹះស្ថាន ក្រុមប្រឹក្សាភិបាលអាចសម្របសម្រួលអំណាចដែលខ្លួនរក្សាទុក ដើម្បីធ្វើឲ្យមានតុល្យភាពរវាងកាតព្វកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងភាពចាំបាច់នៃការគ្រប់គ្រងប្រចាំថ្ងៃ ។

៩.៣ ទម្រង់បែបបទនៃការបែងចែកអំណាច ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកទី១របស់ខ្លួន បន្ទាប់ពីក្រុមប្រឹក្សាភិបាលនេះត្រូវបានបង្កើតឡើង ហើយត្រូវមានធ្វើកំណត់ហេតុផង ។

**មាត្រា ១០.-**

១០.១ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរួមប្រជុំរាល់ពេលដែលផលប្រយោជន៍របស់គ្រឹះស្ថានតម្រូវ និងយ៉ាងតិចបីខែម្តង ។

ក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សា លើបញ្ហាដែលមានចុះក្នុងរបៀបវារៈ ។ របៀបវារៈនេះ ត្រូវបានជូនដំណឹងជាមុនយ៉ាងតិច១០ថ្ងៃ ដល់គ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ និងដល់សមាជិកពាក់ព័ន្ធដទៃផ្សេងទៀត ដែលមានចែងក្នុងមាត្រាទី២៨ នៃព្រះរាជក្រឹត្យនេះ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវចូលរួមប្រជុំតាមគំនិតផ្តួចផ្តើមរបស់ប្រធាន តាមការស្នើពីសមាជិកចំនួន២ភាគ៣ ឬពីនាយក ។ នាយកត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយរើសលេខា

ធិការនៃអង្គប្រជុំ តែគ្មានសិទ្ធិបោះឆ្នោតទេ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រា ៣៦ នៃព្រះរាជក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត ។

១០.២ ក្រុមប្រឹក្សាភិបាល អាចប្រជុំយកជាការបាន លុះត្រាតែមានសមាជិកលើសពី ៥០% ចូលរួម ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលដែលអវត្តមាន ពុំអាចឲ្យគេជំនួសបានឡើយ ។

ប្រសិនបើកូរ៉ុមពុំបានគ្រប់គ្រាន់ ការកោះអញ្ជើញប្រជុំជាលើកទីពីរ ត្រូវបានធ្វើ១៥ថ្ងៃ ក្រោយ ។ ការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សា តែលើរបៀបវារៈ នៃការកោះអញ្ជើញលើកទី១ ។

ត្រូវមានបញ្ជីវត្តមាន ដែលត្រូវចុះហត្ថលេខាដោយសមាជិកវត្តមាន ។ សេចក្តីសម្រេចដែលបានអនុម័តតាមមតិភាគច្រើន នៃសមាជិកវត្តមាន ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលចាត់ទុកជាឧត្តមានុភាព ។

១០.៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាទុកជាលាយលក្ខអក្សររក្សាទុកនៅទីស្នាក់ការរបស់គ្រឹះស្ថាន ដោយមានចុះហត្ថលេខាប្រធាន និងបុគ្គលដែលត្រូវបានចាត់ជាលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះ ត្រូវបញ្ជូនក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ ក្រោយការប្រជុំទៅជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និង ទៅជូនសមាជិកពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្នុងព្រះរាជក្រិត្យនេះ ។ កំណត់ហេតុ ត្រូវឆ្លុះបញ្ចាំងជាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាលត្រូវមានកត់ត្រា ការជំទាស់ទាំងអស់នោះក្នុងកំណត់ហេតុនៃការប្រជុំចុងក្រោយនេះផង ។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិការរបស់គ្រឹះស្ថាន

**មាត្រា ១១**.-

១១.១ អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានបារណៈរដ្ឋបាល អាចប្រគល់ការងារប្រតិបត្តិ របស់គ្រឹះស្ថានឲ្យ:

១- ប្រធានក្រុមប្រឹក្សាភិបាលដែលមានឈ្មោះថា ប្រធាន

២- នាយកដែលអាចជាសមាជិក ឬមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាភិបាល ហើយដែលត្រូវតែងតាំងដោយអនុក្រិត្យ តាមសំណើរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។ នាយកអាចត្រូវដកហូតតំណែងក្នុងគ្រប់កាលៈទេសៈ ដោយអនុក្រឹត្យដែលមាន ចែងក្នុងល័ក្ខខ័ណ្ឌ ដូចកំណត់ខាងលើ ។

១១.២ មុខងារប្រធាន ឬនាយកនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល មានវិសមិតភាពជាមួយមុខងារសមាជិកសភា ឬសមាជិករដ្ឋាភិបាល ។

**មាត្រា ១២**.-

១២.១ ប្រធាន ឬនាយកបំពេញបេសកម្មក្នុងក្របខ័ណ្ឌ នៃការបែងចែកអំណាច ដូចមានចែងក្នុងមាត្រា៩ ខាងលើ ។

១២.២ ប្រធាន ឬនាយកចាត់តំណាងរបស់គ្រឹះស្ថានក្នុងការទំនាក់ទំនងជាមួយតតិយជន។

១២.៣ ប្រធាន ឬនាយកមានភារកិច្ចៈ

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

- ទទួលបន្ទុកប្រតិបត្តិសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង ដាក់ឲ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល

- រៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច

- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ

- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ នូវភារកិច្ចរបស់អង្គភាពចំណុះនានានៃគ្រឹះស្ថាន

- បំពេញមុខតំណែងរបស់គ្រឹះស្ថាន ក្នុងកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងដោយគោរពទៅតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក ។

- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់គ្រឹះស្ថាន ។

- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតពីបញ្ហានេះ ។

- ជារួមគឺបំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយ ដែលត្រូវបានប្រគល់ឲ្យខ្លួនតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

## ផ្នែកទី ៣
## បុគ្គលិករបស់គ្រឹះស្ថាន

**មាត្រា ១៣.-**

១៣.១ បុគ្គលិកអចិន្ត្រៃយ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមានមន្ត្រីរាជការដែលត្រូវបានតែងតាំង ឬផ្ទេរបញ្ជូនមកបម្រើការងារនៅក្នុងគ្រឹះស្ថាន ដោយអនុលោមតាមបទបញ្ជាទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការ និងអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាន ។

១៣.២ អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាន អាចអនុញ្ញាតឲ្យធ្វើការជ្រើសរើសបុគ្គលិក ក្រៅក្របខ័ណ្ឌនៃមុខងារសាធារណៈតាមរយៈកិច្ចសន្យា ដើម្បីបំពេញការងារពិសេសណាមួយ ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ ។

**មាត្រា ១៤.-**

បុគ្គលិករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្តីពីបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈបទបញ្ជាស្តីពីបុគ្គលិកនេះ មិនត្រូវផ្ទុយពីបទបញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ ។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន

**មាត្រា ១៥.-**

១៥.១ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទប្បញ្ញត្តិទាំងឡាយស្តីពីបញ្ហានេះ ។

១៥.២ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចមានទ្រព្យផ្ទាល់ខ្លួន ដែលស្ថិតជាកម្មសិទ្ធិឯកជនហើយដែលអាចទទួលយកនិងគ្រប់គ្រងបាន ដោយអនុលោមទៅតាមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុងដែលគ្រប់គ្រងគ្រឹះស្ថាន ។

## ផ្នែកទី ៥
## ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ នៃគ្រឹះស្ថាន

**មាត្រា ១៦.-**

លើកលែងតែមានបទបញ្ញត្តិដោយឡែក ដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រឹះស្ថានត្រូវស្ថិតនៅក្រោមគោលការណ៍ នៃគណនេយ្យសាធារណៈលើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ដូចដែលមានកំណត់ក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៧.-**

១៧.១ ប្រធាន ឬនាយកជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ។ ក្នុងន័យនេះ ដើម្បីអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ប្រធាន ឬនាយកត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៧.២ អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិឲ្យអាណាប័កផ្ទេរសិទ្ធិ ឬបង្កើតដោយមានការព្រមព្រៀងពីគណនេយ្យករនូវរដ្ឋទេយ្យចំណូល ឬបុរេប្រទាន ។

**មាត្រា ១៨.-**

១៨.១ ប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។

គណនេយ្យករនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុដោយត្រូវសច្ចាប្រណិទានមុនចូលកាន់ភារងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចគ្រោងនូវការតែងតាំងគណនេយ្យករជាអ្នកទទួលខុសត្រូវបណ្តាអង្គភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ។ ក្នុងមុខតំណែងនេះ គណនេយ្យករត្រូវស្ថិតក្រោមឱវាទរបស់ប្រធាន ឬនាយក ។

១៨.២. គណនេយ្យករ មានភារកិច្ចៈ

- ប្រមូលចំណូល

- បើប្រាក់ចំណាយ

- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតំលៃ

- រក្សាទុកនូវលិខិតយុត្តិការ និងភាន់កាមបញ្ជីគណនេយ្យ

១៨.៣. គណនេយ្យករ អាចផ្ទេរសិទ្ធិខ្លះឲ្យទៅមន្ត្រីក្នុងការិយាល័យ ។

**មាត្រា ១៩.-**

១៩.១. ប្រភពធនធានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានៈ

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់គ្រឹះស្ថាន នៅពេលចាប់ផ្តើមបង្កើតដំបូង

- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានចែងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន

- អាករដែលសហគ្រាសមានសិទ្ធិទទួលយកដោយផ្ទាល់ ហើយត្រូវបានគ្រោងដោយអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាននេះ

- ការផ្ទេរពន្ធ និងអាករចូលក្នុងប្រាក់ចំណេញរបស់គ្រឹះស្ថាន ចែងដោយច្បាប់ហិរញ្ញវត្ថុ

- អំណោយ និងអច្ច័យទានដែលគ្រឹះស្ថានបានទទួល

- ផលនៃការងារ និងការផ្តល់សេវាសម្រេច ឬផ្តល់ដោយគ្រឹះស្ថាន

- កំរៃនៃទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន និងចំណូលនៃការលក់ទ្រព្យសម្បត្តិទាំងនោះ

- កំរៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឲ្យគ្រឹះស្ថាន

១៩.២. ចំណូលនិងចំណាយជាប្រចាំ និងជាមូលធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ។ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ត្រូវចែងអំពីបែបបទ នៃការរៀបចំការចាត់ចែងនិងអនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំការចាត់ចែង និង អនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.៣. ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវ ធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឲ្យមានលំនឹងរវាងចំណូល និងចំណាយ ។

**មាត្រា ២០.-**

២០.១. ការងារគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានៈ

- គណនេយ្យទុទៅកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិកាថវិការតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន ។

- គណនេយ្យអសង្ហារឹម រូបធាតុ និងគណនេយ្យតំលៃ

- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់គ្រឹះស្ថានត្រូវៈ

១- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់គ្រឹះស្ថាន ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណ

នេយ្យនេះ ត្រូវបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២០.២. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គ្រឹះស្ថាន ត្រូវរៀបចំឡើងដោយគណនេយ្យករហើយ ត្រូវដាក់ដោយអាណាប័កដើមខ្សែ ភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២១.-**

មូលនិធិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២២.-**

ការប្រើប្រាស់នូវប្រាក់ដែលលើស របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពលើគណនីដោយក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។ ធនធានដែលលើសនេះ អាចធ្វើការបណ្ដាក់ទុន ឬចងការ តែត្រូវមានការយល់ព្រមពីក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៣.-**

អនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចមានចែងនូវការផ្ដល់បុព្វសិទ្ធិ និងអំណាចសាធារណៈក្នុងការប្រមូលចំណូល ការសងបំណុល និងការការពារទ្រព្យសម្បត្តិ ។

## ផ្នែកទី ៦
## របបសារពើពន្ធនៃគ្រឹះស្ថាន

**មាត្រា ២៤.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតនៅក្រោមនីតិរូមចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី៧
## លទ្ធកម្មដោយគ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា ២៥.-**

ការសំរេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្ម ក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦០អនក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ១៩៩៥ ស្ដីពីលទ្ធកម្មសាធារណៈ និងបទបញ្ជាដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះ។

# ជំពូកទី៣
# អាណាព្យាបាលភាព

**មាត្រា ២៦.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតនៅក្រោមៈ

១- អាណាព្យាបាលបច្ចេកទេសរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាល ដែល

ទទួលបន្ទុកសកម្មភាពនៃគ្រឹះស្ថាន ឬរបស់អាជ្ញាធរសាធារណៈផ្សេងណាមួយដែលមានចែងក្នុងអនុក្រឹត្យស្តីពីការបង្កើត

២- អាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២៧.-**

ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាល អាចចាត់មន្ត្រីអោយធ្វើអធិការកិច្ច ឬត្រួតពិនិត្យបើយល់ថាចាំបាច់។

**មាត្រា ២៨.-១**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តល់ជូនគណៈរដ្ឋមន្ត្រី ប្រធាននស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងមាត្រា ៣៦ ខាងក្រោមនេះនូវឯកសារដូចតទៅ ៖

-កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ផែនការពង្រីកគ្រឹះស្ថាន

-ថវិកាប្រចាំឆ្នាំ

-របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ

**មាត្រា ២៨.-២**

ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលទទួលបន្ទុកក្នុងរយៈពេលមិនអោយហួសពី១៥ថ្ងៃ។

## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៩.-**

២៩.១-ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធាន ឬនាយកត្រូវផ្ញើជូនប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍន៍ និងគំរោងថវិកាដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេល១ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារត្រូវរៀបចំយោបល់របស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។ ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេសមានពេល ២ខែគិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយប្រធាន ឬ នាយកដើម្បីសំរេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

២៩.២- លិខិតយល់ព្រម ត្រូវចុះហត្ថលេខាត្រឹមត្រូវដោយប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ឬអ្នកតំណាង ហើយត្រូវផ្ញើជូន ឬនាយក ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រធាន ឬនាយកត្រូវជូនព័ត៌មាននេះ ទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស មិនបានឆ្លើយតបតាមរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកា ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស បានធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬ គំរោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់

ដើម្បីពិភាក្សា និងវិះរកមធ្យោបាយ សំរាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍ និង ថវិកាចំណាយជាមូលធនមិនអាចដាក់អោយអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

ថវិកាចំណាយជាប្រចាំ អាចដាក់អោយអនុវត្តត្រឹមលំនាំប្រព័ន្ធជា - ដប់ពីរ - ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។

**មាត្រា ៣០.-**

៣០.១- ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស ក្នុងក្របខ័ណ្ឌនៃសិទ្ធិធ្វើការជំទាស់របស់ខ្លួនអាចលើកឡើងនូវការជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួន ដូចមានចែងក្នុង មាត្រា២៨ ខាងលើនេះ : កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។ ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស មានរយៈពេលមួយខែសំរាប់លើកឡើងនូវការជំទាស់ទាំងនោះ។

៣០.២- ប្រធាន ឬនាយកត្រូវជំរាបជូនដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់ដែលបានលើកឡើងដោយប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស។

ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាអោយបានឆាប់បំផុត លើការជំទាស់របស់ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងវិះរកមធ្យោបាយសំរាប់ដោះស្រាយជំទាស់តាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសមរេចពុំយកជាការនូវការជំទាស់ទាំងនោះ សេចក្តីសំរេចទាំងនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ភ្លាមស្តីពីបញ្ហានេះ ជាលាយលក្ខអក្សរដល់ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស។

**មាត្រា ៣១.-**

៣១.១-ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស អាចធ្វើការលុប ឬផ្អាកទុកនូវសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ប្រធានឬនាយក ក្នុងករណីដែលសេចក្តីសំរេចនោះ

- ផ្ទុយនឹងគោលដៅរបស់គ្រឹះស្ថាន
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលមិនអាចមានសិទ្ធិសំរេច ឬធ្វើឡើងដោយការប្រជុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

៣១.២- ការលុបចោល ឬការផ្អាកទុកនេះត្រូវសំរេចឡើងតាមរយៈប្រកាស របស់ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ដោយមានការបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួនរបស់ប្រធានស្ថាប័ន ឬ អជ្ញាធរអាណាព្យាបាល ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាកទុកចោលនូវសេចក្តីសំរេចនេះ ត្រូវជូនដំណឹងដល់ប្រធាន ឬនាយក ហើយប្រធាន ឬនាយកត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ៣២.-**

ក្នុងករណីដែលក្រុមបប្រឹក្សាភិបាល ប្រធាន ឬនាយកពុំប្រតិបត្តិតាមបណ្តាវិធាន ដែលមានចែង

ក្នុងអត្ថបទច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស បន្ទាប់ពីធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខអក្សរមកអាចចាត់វិធានការងារ និងចេញសេចក្តីសំរេចខាងលើ ហើយអាចប្រើប្រាស់នូវវិធានការចាំបាច់ទាំងអស់ ។

**មាត្រា ៣៣.-**

ប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស អាចចាត់ចែងឡើងនូវការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងករណីដែលដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៤.-**

៣៤.១- ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធាន ឬនាយក ត្រូវធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុ ប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានស្ថាប័ន ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។ ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស មានពេលមួយខែគិតចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលពីរខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយប្រធាន ឬនាយក ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនោះ។

៤២.២- លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើជូនប្រធាន ឬនាយកដោយមានចំលងជូនប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស ។ ប្រធាន ឬនាយក ត្រូវជំរាបដំណឹងនេះ ជូនក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបតាមរយៈពេលកំណត់ របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានការជំទាស់លើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំធ្វើការប្រជុំក្រុមប្រឹក្សាភិបាលអោយបានឆាប់បំផុតដើម្បីពិភាក្សា និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ទាំងនោះ ។ របាយការណ៍ពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសំរេចយល់ព្រមបានឡើយក្នុងករណីដែលការជំទាស់ដែលលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

**មាត្រា ៣៥.-**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ប្រធាន ឬនាយក ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមានៈ

-សេចក្តីសំរេចស្តីពីការលក់ ឬផ្ទេរសិទ្ធអចលនៈទ្រព្យ

-សេចក្តីសំរេចស្តីពីការលើកលែងគណនេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់

ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-សេចក្តីសំរេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រងព្រាងសំរាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការតែងតាំងប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើគ្រឹះស្ថាន ដូចមានចែងក្នុងអនុក្រឹត្យ លេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវហិរញ្ញវត្ថុលើចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣៧.-**

៣៧.១- ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើគ្រឹះស្ថានលើសាធារណៈរដ្ឋបាល ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣៧.២-ការគ្រប់គ្រងរបស់គណនេយ្យករត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។

៣៧.៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ចឬការត្រួតពិនិត្យលើគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ជំពូក៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣៩.-**

នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤០.-**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទ១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ឹង ហួត ហ៊ុន សែន

ជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១

និងសម្តេចនាយករដ្ឋមន្ត្រីទី២

ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៨១០

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើត ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈ គតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការ កំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការ កែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ហៅកាត់ថា អាជ្ញាធរជាតិសំបូរព្រៃគុក ដែលសរសេរជាអក្សរកាត់ថា អ.ជ.ស.ព. ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្ត មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។

គ្រឹះស្ថានសាធារណៈនេះស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## ជំពូកទី២
## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា២ .-**

អ.ជ.ស.ព. មានបេសកកម្មអភិរក្សនិងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

**មាត្រា៣ .-**

អ.ជ.ស.ព. មានតួនាទី និងភារកិច្ចដូចតទៅ៖

- ការពារ ថែរក្សា អភិរក្ស និងលើកតម្លៃឧទ្យានបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គិតគូរនិងអនុវត្តឱ្យបានសម្រេចនូវផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកប្រកបដោយចីរភាព
- គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ទប់ស្កាត់បទល្មើសព្រៃឈើ និងអំពើអនាធិបតេយ្យនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវការងារដែលបានកំណត់ក្នុងផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍទេសចរណ៍ដូចបានរៀបរាប់ខាងលើ
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយរបស់ អ.ជ.ស.ព

- សហការជាមួយក្រសួង ស្ថាប័ន មូលនិធិ អង្គការ សហគមន៍ជាតិនិងអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានទិសដៅស្របនឹងសមត្ថកិច្ចរបស់ អ.ជ.ស.ព.
- ចុះកិច្ចព្រមព្រៀង ស្តីពីគម្រោងឬកម្មវិធីនានាជាមួយអង្គការជាតិ និងអន្តរជាតិ
- ចុះកិច្ចសន្យាជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមានគម្រោងផែនការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និងការផ្តល់សេវាផ្សេងៗជាយថាហេតុ
- លើកគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីដំណើរការ អ.ជ.ស.ព.
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ អ.ជ.ស.ព. ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៣
## ក្រុមប្រឹក្សាភិបាល

**មាត្រា៤ .-**

អ.ជ.ស.ព. ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ស.ព. | សមាជិក និងជាលេខាធិការ។ |

សមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៥ .-**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដឹកនាំ អ.ជ.ស.ព. និងមានសិទ្ធិអនុម័តលើ៖

- ការតម្រង់ទិសរាល់សកម្មភាពរបស់ អ.ជ.ស.ព.
- ការអនុញ្ញាតឱ្យប្រធាន អ.ជ.ស.ព. ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាអន្តរជាតិទាំងឡាយស្របតាមនីតិវិធីជាធរមាន
- បទបញ្ញាផ្ទៃក្នុងរបស់ អ.ជ.ស.ព.
- គម្រោងថវិកាប្រចាំឆ្នាំរបស់ អ.ជ.ស.ព.
- របាយការណ៍ប្រចាំឆ្នាំដែលប្រធាន អ.ជ.ស.ព. បានដាក់ជូន

- ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបដែល អ.ជ.ស.ព. ប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់វិធានការ និងដំណោះស្រាយបញ្ហាដែលប្រធាន អ.ជ.ស.ព.ដាក់ជូនពិនិត្យ។

**មាត្រា៦ .-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំ៣(បី)ខែម្តង តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់ ក្នុងករណីមានការស្នើសុំពីប្រធានឬសមាជិកយ៉ាងតិចចំនួន១/៤(មួយភាគបួន)។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជនឬអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានាមកចូលរួមក្នុងអង្គប្រជុំបានតាមការចាំបាច់ដើម្បីជាប្រយោជន៍ដល់ អ.ជ.ស.ព.។

**មាត្រា៧ .-**

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល៣(បី)ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន។ ការបញ្ចប់អាណត្តិសមាជិកណាម្នាក់ ត្រូវធ្វើឡើងតាមសំណើរបស់ក្រសួងសាមី។

**មាត្រា៨ .-**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃ អ.ជ.ស.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

## ជំពូកទី៤
## ការគ្រប់គ្រង និងរចនាសម្ព័ន្ធ

**មាត្រា៩ .-**

ប្រធានក្រុមប្រឹក្សាភិបាលនៃ អ.ជ.ស.ព. គឺជាប្រធាន អ.ជ.ស.ព. នេះ ដែលមានសិទ្ធិអំណាចដូចមានចែងនៅក្នុងមាត្រា១២នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមានតួនាទី និងភារកិច្ចបន្ថែមដូចតទៅ៖

- ជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធី និងការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ទទួលអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការគ្រប់គ្រងក្នុងដំណើរការរបស់ អ.ជ.ស.ព.
- ជាអាណាប័កដើមខ្សែនៃ អ.ជ.ស.ព. ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ
- លើកសំណើតែងតាំង និងដំឡើងឋានៈមន្ត្រី និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល
- ដឹកនាំ និងគ្រប់គ្រងសកម្មភាពការងាររបស់ អ.ជ.ស.ព.។

**មាត្រា១០ .-**

អ.ជ.ស.ព. មានអគ្គនាយកដ្ឋានមួយ ជាសេនាធិការដែលដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ស.ព. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១១ .-**

អ.ជ.ស.ព. អាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់។

**មាត្រា១២ .-**

អ.ជ.ស.ព. មានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់ការស្ថាបនាទាំងឡាយក្នុងវង្វង់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។ ការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេងក្រៅពី អ.ជ.ស.ព. ទាក់ទងនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកត្រូវទុកជាមោឃៈ។

**មាត្រា១៣ .-**

អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវចូលរួមសហការជាមួយ អ.ជ.ស.ព. ក្នុងការទប់ស្កាត់ការសាងសង់ខុសច្បាប់ និងបទល្មើសផ្សេងៗដែលកើតឡើងក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

**មាត្រា១៤ .-**

អ.ជ.ស.ព. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក។

## ជំពូកទី៥
## មូលនិធិបុរាណវិទ្យាប្រាសាទសំបូរព្រៃគុក

**មាត្រា១៥ .-**

ត្រូវបានបង្កើតគណនីពិសេសមួយមានឈ្មោះថា «មូលនិធិបុរាណវិទ្យាប្រាសាទសំបូរព្រៃគុក» ដើម្បីប្រមូល និងទទួលយកមូលនិធិ ព្រមទាំងវិភាគទាន និងអំណោយពីសហគមន៍ជាតិ និងអន្តរជាតិសម្រាប់ជាប្រយោជន៍ក្នុងកម្មវិធីទ្រទ្រង់ប្រាសាទសំបូរព្រៃគុក។

មូលនិធិបុរាណវិទ្យាប្រាសាទសំបូរព្រៃគុក ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងប្រើប្រាស់របស់ប្រធាន អ.ជ.ស.ព.។

## ជំពូកទី៦
## ប្រភពធនធាន

**មាត្រា១៦ .-**

អ.ជ.ស.ព. មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាជាតិដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

អ.ជ.ស.ព. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍន៍និងប្រភពផ្សេងៗទៀតដូចជា៖

- វិភាគទានពីរដ្ឋ
- អំណោយ និងវិភាគទានអន្តរជាតិដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃ អ.ជ.ស.ព.
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់ អ.ជ.ស.ព. ដូចជាបំណុល ថ្លៃឈ្នួល បានមកពីការចេញច្បាប់ការកាប់ផ្សេងៗ

- ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្ដល់ដោយអង្គការសាធារណៈឬឯកជន
- កម្ចីដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃ អ.ជ.ស.ព.
- ចលនវត្ថុ និងអចលនវត្ថុដែលសប្បុរសជន អង្គការជាតិ និងអន្តរជាតិប្រគល់ឱ្យ។

**មាត្រា១៧ .-**

គម្រោងចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រស.១៥០៧.៨១៩ **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ហត្ថលេខា**

**ភឿង សកុណា**

លេខៈ ៨៧២ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៦

## ស្តីពី

## ការកំណត់រមណីយដ្ឋានសំបូរព្រៃគុក

*****

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង គ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ជារមណីយដ្ឋានការពារ ជាអតីតរាជធានីខ្មែរ ឈ្មោះថា ឥសានបុរៈ ក្នុងសតវត្សទី ៦-៧ ស្ថិតក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកំរិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

### ជំពូកទី ២

### ការកំណត់តំបន់

**មាត្រា ៣.-**

តំរូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក ត្រូវចាត់ជា ៣ (បី)តំបន់ ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

១- **តំបន់ស្នូល** : ជាតំបន់ឧទ្យានប្រាសាទតូច-ធំ រួមទាំងសម្បត្តិវប្បធម៌ បុរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដី ឬកប់ក្នុងដី កំពុងស្រាវជ្រាវ ឬ ពុំទាន់ស្រាវជ្រាវ

K ( 505604 ; 1425246 )

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការការពារ ទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និង ការអភិវឌ្ឍន៍មិនសមស្រប ។

៣- **តំបន់រណប :** ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់រណប ដោយរក្សាជីវភាពមុខរបរ អាជីវកម្ម តាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច A B C D E F G H I J K ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឱ្យមានចីរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥ .-**

ការអភិរក្សរាល់តំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង ក៏តនៃសារៈសំខាន់ដោយឡែកៗ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦ .-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពារ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧ .-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផល នៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាព

រកឃើញ ដោយអ្នកបុរាណវិទ្យា ។ តំបន់នេះ ហៅថា **តំបន់ស្នូល** មានផ្ទៃក្រឡាសរុប ៣៨១.១១ហិកតា។

តំបន់ស្នូលនេះ រួមមានតំបន់ ៣ ( បី ) : តំបន់ **ក** តំបន់ **ខ** តំបន់ **គ** ។

តំបន់ស្នូលត្រូវបានកំណត់ដូចខាងក្រោមនេះ :

តំបន់ ក : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_1$ ( 504939 ; 1423496 ) , $B_1$ ( 504521 ; 1423004 )
$C_1$ ( 504210 ; 1422372 ) , $D_1$ ( 504110 ; 1421913 )
$E_1$ ( 504262 ; 1421680 ) , $F_1$ ( 504580 ; 1421665 )
$G_1$ ( 504536 ; 1421428 ) , $H_1$ ( 504380 ; 1421102 )
$I_1$ ( 504391 ; 1420751 ) , $J_1$ ( 504462 ; 1420736 )
$K_1$ ( 504680 ; 1421187 ) , $L_1$ ( 504773 ; 1421665 )
$M_1$ ( 505094 ; 1421665 ) , $N_1$ ( 505224 ; 1421950 )
$T_1$ ( 506889 ; 1422109 ) , $S_1$ ( 506575 ; 1422575 )
$P_1$ ( 505365 ; 1422549 ) , $Q_1$ ( 505513 ; 1423064 )
$R_1$ ( 505376 ; 1423437 )

តំបន់ ខ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_2$ ( 503211 ; 1425262 ) , $B_2$ ( 502904 ; 1424858 )
$C_2$ ( 503081 ; 1424185 ) , $D_2$ ( 504458 ; 1424288 )
$E_2$ ( 504613 ; 1425289 )

តំបន់ គ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$U_3$ ( 502552 ; 1421073 ) , $V_3$ ( 502045 ; 1420962 )
$W_3$ ( 501557 ; 1423004 ) , $Z_3$ ( 503577 ; 1423256 )

តំបន់ **ក** **ខ** **គ** ជាតំបន់មានប្រាសាទសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

២- **តំបន់ទ្រនាប់** : ជាតំបន់ឧទ្យានបុរាណវត្ថុ ដែលមានបន្សល់ទុកនូវដានស្នាកស្នាម ឬ កប់ក្នុងដីរាក់ ឬជ្រៅ ពុំទាន់រកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬ ក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាពលរដ្ឋជាដើម ។ តំបន់នេះ **ហៅថាតំបន់ទ្រនាប់** មានផ្ទៃក្រឡា ២៩៨២.៤៥ហិកតា។

តំបន់នេះស្ថិតនៅក្រៅបរិវេណនៃតំបន់ **ក** តំបន់ **ខ** និង តំបន់ **គ** នៃតំបន់ស្នូល ហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A ( 502721 ; 1426711 ) , B ( 501633 ; 1425998 )
C ( 500537 ; 1423348 ) , D ( 501733 ; 1418978 )
E ( 504456 ; 1420172 ) , F ( 505480 ; 1420622 )
G ( 505567 ; 1421717 ) , H ( 508911 ; 1421701 )
I ( 508909 ; 1422487 ) , J ( 505583 ; 1424066 )

ជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនិងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ .-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស/រកត.០៣០៣.១២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខៈ ៩៦ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សុខ តាន់**

# ផែនទីកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣/១១៦
ចុះថ្ងៃទី.១១...ខែ..មីនា..ឆ្នាំ២០០៣
ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក




សញ្ញាសំគាល់

- ប្រាសាទ
- ផ្លូវថ្នល់
- ស្ទឹង អូរ
- តំបន់ស្នូល ៣៨១.០៥ហិកតា
- តំបន់ទ្រនាប់ ២ ៩៨៧.៥១ហិកតា
- ភូមិដ្ឋាន ទីលំនៅ
- វាលស្រែ
- វាលចំការ
- កសិកម្មពនេចរ (កាប់រាន និងដុត)
- សួនចំការក្នុងភូមិ
- សួនចំការ
- ព្រៃស្ដោងចំរុះ
- វាលបោះបង់ចោលគ្របដោយព្រៃស្ដោង
- ព្រៃស្ដោងលិចទឹក
- ព្រៃមានពណ៌បៃតងជានិច្ចមានស្លឹកធំ
- ព្រៃស្រៀវ និងព្រៃល្បោះ
- បឹង ត្រពាំង ទន្លេ ស្ទឹង
- ដីគ្មានជីវជាតិ
- ខ្សាច់

មាត្រដ្ឋាន 1:35000

ប្រភពទិន្នន័យ :

- រូបថតពីលើអាកាស មាត្រដ្ឋាន១:២៥០០០ ថតក្នុងឆ្នាំ១៩៩២.
- ទិន្នន័យទីតាំងប្រាសាទវាស់វែងដោយ GPS របស់អង្គការ WASEDAឆ្នាំ២០០១
- ផែនទីការប្រើប្រាស់ដី ខ្នាត១:១០០០០០ ឆ្នាំ១៩៩៩។

រៀបចំដោយនាយកដ្ឋានភូមិសាស្ត្រ.២៨.០២.០២.

ចំណោលផែនទី អ៊ុយធេអឹម តំបន់ ៤៨
Datum : WGS 84

# ព្រះរាជក្រឹត្យ

នស/រកត/១២១៤/១៤៤៥

## ស្តីពី

## ការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៨/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រាមួយ.-**

មាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៤ថ្មី.-**

រមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក ត្រូវចាត់ជា៣(បី)តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកម្រិតការពារខុសៗគ្នា៖

១- **តំបន់ស្នូល** : តំបន់មានប្រាសាទសំខាន់ជាងគេនិងជាតំបន់ឧទ្យានប្រាសាទតូចធំ រួមទាំងសម្បត្តិវប្បធម៌ បុរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដីឬកប់ក្នុងដីកំពុងស្រាវជ្រាវឬពុំទាន់ស្រាវជ្រាវរកឃើញដោយអ្នកបុរាណវិទ្យា ហើយត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។

តំបន់នេះមានផ្ទៃក្រឡាសរុប ១ ៣៥៤,២៦ហិកតា ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| | | |
|---|---|---|
| $A_1$ (503211, 1425262) | , | $B_1$ (502904, 1424858) |
| C1 (502873, 1423171) | , | $D_1$ (501557, 1423004) |
| $E_1$ (502045, 1420962) | , | $F_1$ (504536, 1421428) |
| $G_1$ (504380, 1421102) | , | $H_1$ (504310, 1420606) |
| $I_1$ (504355, 1420592) | , | $J_1$ (504462, 1420736) |
| $K_1$ (504680, 1421187) | , | $L_1$ (504773, 1421665) |
| $M_1$ (505094, 1421665) | , | $N_1$ (505224, 1421950) |
| $O_1$ (507688, 1422128) | , | $P_1$ (507571, 1422534) |
| $Q_1$ (504458, 1424288) | , | $R_1$ (504613, 1425289) |

២- តំបន់ទ្រនាប់ : តំបន់សម្បូរដោយសំណល់បុរាណវត្ថុ និងជាឧទ្យានបុរាណវត្ថុដែលមានបន្សល់ទុកនូវស្លាកស្នាមកប់ក្នុងដីរាក់ឬជ្រៅ ហើយពុំទាន់រុករកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាជនជាដើម ដែលត្រូវការពារ ទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លីនិងការអភិវឌ្ឍមិនសមស្រប។

តំបន់នេះ មានផ្ទៃក្រឡា២ ០០៩,៣០ហិកតា ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| | | |
|---|---|---|
| A (502721; 1426711) | , | B (501633; 1425998) |
| C (500537; 1423348) | , | D (501733; 1418978) |
| E (504456; 1420172) | , | F (505480; 1420622) |
| G (505567; 1421717) | , | H (508911; 1421701) |
| I (508909; 1422487) | , | J (505583; 1424066) |
| K (505604; 1425246) | | |

៣- តំបន់រណប : តំបន់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទម្លាប់ ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាជនក្នុងតំបន់។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមកាចំណុច A B C D E F G H I J K ចម្ងាយ១៥០០ម៉ែត្រ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឲ្យមានចីរភាព និងមានការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៥ថ្មី .-**

ការអភិរក្សរាល់តំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យនេះ និងកម្រិតនៃសារៈសំខាន់ដោយឡែកៗទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាជនរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយ៍ដ្ឋានការពារឲ្យមានតម្លៃកាន់តែខ្ពស់ឡើង។

**មាត្រា៧ថ្មី .-**

បរិវេណនិងរាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យានិងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា៤ថ្មី។

ការកែប្រែតំបន់និងរាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៤

នស/រកត/១២១៤/១៥៧៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**ហត្ថលេខា**
**ភឿង សកុណា**

លេខ: ១៥០៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ .ចុះថ្ងៃទី ២៤..ខែ.. ធ្នូ .....ឆ្នាំ ២០១៤ ...ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក




**បញ្ជាក់**: ចំពោះការកាន់កាប់ដីក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកទាំងមូលនឹងត្រូវធ្វើការសិក្សាដើម្បីកំណត់អំពីសិទ្ធិនិងវិធាននៃការប្រើប្រាស់ដីជាក្រោយ ។

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៤

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៤

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ភឿង-សកុណា

# អនុក្រឹត្យ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១១៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធាន អ.ជ.ស.ព.

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ដែលហៅកាត់ថាអគ្គនាយកដ្ឋាន អ.ជ.ស.ព.។

## ជំពូកទី២
## មុខងារនិងភារកិច្ច

**មាត្រា២.-**

អគ្គនាយកដ្ឋាន អ.ជ.ស.ព. មានតួនាទីជាសេនាធិការជូន អ.ជ.ស.ព. និងមានមុខងារនិងភារកិច្ចដូចតទៅ៖

- សម្របសម្រួលនិងរៀបចំផែនការសម្រាប់រយៈពេលខ្លី មធ្យម និងវែងស្តីពីការអភិរក្សនិងការអភិវឌ្ឍក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- អនុវត្តផែនការនានាដើម្បីលើកតម្លៃ ជំរុញផ្សព្វផ្សាយ និងគ្រប់គ្រងការធ្វើអាជីវកម្មនិងសេវាកម្មទេសចរណ៍នៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ចាត់វិធានការបង្ការ ការពារ ថែរក្សា និងគ្រប់គ្រងប្រាសាទនានា រួមទាំងទេសភាពនិងបរិស្ថានដែលនៅជុំវិញប្រាសាទទាំងនោះ
- ធ្វើការស្ទង់មើលនិងធ្វើកំណាយបុរាណវិទ្យា
- ធ្វើការសិក្សា ស្រាវជ្រាវ និងចងក្រងឯកសារស្តីពីវប្បធម៌នៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកនិងតំបន់ពាក់ព័ន្ធផ្សេងទៀត
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្តល់ជាគុណប្រយោជន៍ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ និងផ្តល់ព័ត៌មានដល់ភ្នាក់ងារនិងអ្នកផ្តល់សេវាកម្មទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរៀបចំអភិវឌ្ឍតំបន់រណប(តំបន់៣) ឱ្យបានល្អប្រសើរ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើនិងអំពើអនាធិបតេយ្យក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំនិងគ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធនានាដែលបម្រើឱ្យវិស័យទេសចរណ៍ក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក

- រៀបចំចេញលិខិតអនុញ្ញាតសាងសង់សំណង់នានានិងចាត់វិធានការចំពោះសំណង់គ្មានច្បាប់អនុញ្ញាតនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សិក្សាវាយតម្លៃនិងផ្តល់ការអនុញ្ញាតលើគម្រោងវិនិយោគនានាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងតាមដានការអនុវត្តគម្រោងវិនិយោគទាំងនោះ
- រៀបចំប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យគុណភាពលើការធ្វើអាជីវកម្មនិងសេវាកម្មនានាក្នុងគោលដៅការពារបរិស្ថាននិងអភិវឌ្ឍប្រកបដោយចីរភាព
- រៀបចំកិច្ចសន្យាជាមួយវិនិយោគិននិង/ឬសម្បទានិក ព្រមទាំងធ្វើការដោះស្រាយរាល់វិវាទទាំងឡាយ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំ ចាត់ចែង គ្រប់គ្រងចំណូលចំណាយថវិកា និងទ្រព្យសម្បត្តិរបស់ អ.ជ.ស.ព. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បង្កើតការងារនិងជំរុញឱ្យមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សម្របសម្រួលលើការងារពិធីការនិងបដិសណ្ឋារកិច្ចជូនគណៈប្រតិភូជាតិនិងអន្តរជាតិដែលអញ្ជើញមកទស្សនាតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពចំណូលនិងចំណាយរបស់ អ.ជ.ស.ព. ជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលជាប្រធាន អ.ជ.ស.ព. និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំជូន អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន អ.ជ.ស.ព. ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣** ._

អគ្គនាយកដ្ឋាន អ.ជ.ស.ព. មានរចនាសម្ព័ន្ធដូចតទៅ៖

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានសណ្តាប់ធ្នាប់
- នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្ស
- នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ
- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍
- នាយកដ្ឋានទេសភាពវប្បធម៌និងបរិស្ថាន។

អង្គការលេខរបស់អគ្គនាយកដ្ឋាន អ.ជ.ស.ព. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤** ._

អគ្គនាយកដ្ឋាន អ.ជ.ស.ព. ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងចំនួនច្រើនបំផុត ៥(ប្រាំ)រូប។

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ)រូប និងមានអនុប្រធាននាយកដ្ឋានចំនួនច្រើនបំផុតពី៣(បី)រូបទៅ៥(ប្រាំ)រូប។

នាយកដ្ឋាននីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលជាប្រធាន អ.ជ.ស.ព.។

## ជំពូកទី៤

## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៥ –**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររួមមាន រដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ផែនការ សម្ភារៈបរិក្ខារ ស្ថិតិ នីតិកម្ម និងពិធីការ
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលក្នុងក្របខ័ណ្ឌ អ.ជ.ស.ព. ជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធនានា ព្រមទាំងទំនាក់ទំនងជាមួយស្ថាប័នជាតិនិងអន្តរជាតិ
- គ្រប់គ្រងនិងសម្របសម្រួលការផ្តល់សេវាកម្មរដ្ឋបាលនានាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.ជ.ស.ព.
- ពិនិត្យនិងគ្រប់គ្រងការងាររបៀបរួមមាន លិខិតចេញចូល ចរាចរណ៍លិខិតផ្ទៃក្នុង និងតម្កល់ឯកសារ
- គ្រប់គ្រងនិងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រមលើបុគ្គលិកទាំងអស់របស់អគ្គនាយកដ្ឋាន អ.ជ.ស.ព.
- រៀបចំផែនការ ស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិក ព្រមទាំងធ្វើតារាងការងារដែលអគ្គនាយកដ្ឋានបានអនុវត្តកន្លងមកនិងត្រូវអនុវត្តបន្តនៅពេលអនាគត
- អនុវត្តតាមតារាងកំណត់ប្រាក់បៀវត្សរ៍ ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ការងារនីមួយៗរបស់មន្ត្រីរាជការនិងបុគ្គលិក តាមការកំណត់របស់ប្រធាន អ.ជ.ស.ព.
- រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានានូវកម្មវិធីស្តីពីការកំណត់តំណែងឯកទេសនិងការបែងចែកធនធានមនុស្សនិងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការនិងបុគ្គលិក
- រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនូវសំណើសុំថវិកាឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់
- តាក់តែងកិច្ចសន្យាគម្រោងវិនិយោគនិងអាជីវកម្មនានា ព្រមទាំងពិនិត្យនិងតាមដាននូវរាល់ការអនុវត្តកិច្ចសន្យាដើម្បីធានាការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព
- ប្រមូលប្រាក់ចំណូលនិងចាត់ចែងចំណាយឱ្យមានតម្លាភាព
- រក្សាទុកនិងចាត់ចែងការប្រើប្រាស់មូលនិធិនិងរូបិយវត្ថុ
- កាន់កាប់បញ្ជីគណនេយ្យនិងរក្សាទុកនូវលិខិតយុត្តិការបណ្ណសារ
- គ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋាន អ.ជ.ស.ព.
- រៀបចំបញ្ជីសារពើភណ្ឌ សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនរបស់ អ.ជ.ស.ព.
- ទទួលបន្ទុកការងារថែទាំ ជួសជុលអគារការិយាល័យ គ្រឿងបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនរបស់ អ.ជ.ស.ព.
- គ្រប់គ្រងនិងផ្គត់ផ្គង់ប្រេងឥន្ធនៈនិងបរិក្ខារផ្សេងៗជូន អ.ជ.ស.ព.
- ពិនិត្យនិងរៀបចំការងារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធការងារផ្គត់ផ្គង់សម្ភារៈប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ព្រមទាំងសម្រាប់ការងារចាំបាច់បន្ទាន់របស់ អ.ជ.ស.ព.

- សហការជាមួយបណ្តានាយកដ្ឋាននានានៃ អ.ជ.ស.ព. ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំជូនអគ្គនាយក អ.ជ.ស.ព.
- រៀបចំបទដ្ឋានគតិយុត្តនានានិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការក្នុងការរៀបចំព័ត៌មានស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗនិងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការ
- សហការនិងសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន អង្គទូត អង្គការជាតិនិងអង្គការអន្តរជាតិ សមាគមន៍នានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀងនិងគម្រោងស្នើសុំជំនួយដើម្បីអភិរក្សនិងអភិវឌ្ឍក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្តល់ជាគុណប្រយោជន៍ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយរដ្ឋបាលខេត្តកំពង់ធំនិងស្ថាប័នពាក់ព័ន្ធ ទទួលបន្ទុកលើពិធីការនិងមគ្គុទ្ទេសក៍ទេសចរណ៍ជូនគណៈប្រតិភូជាតិនិងអន្តរជាតិសំខាន់ៗដែលអញ្ជើញមករមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំផែនការផ្សព្វផ្សាយអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគក្នុងតំបន់រណប(តំបន់៣)
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តីពីចំណូលចំណាយរបស់ អ.ជ.ស.ព. ជូនប្រធាន អ.ជ.ស.ព. និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ស្តីពីសម្មភាពការងាររបស់អគ្គនាយកដ្ឋានតាមរយៈអគ្គនាយក អ.ជ.ស.ព. ជូនប្រធាន អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៦ .-**

នាយកដ្ឋានសណ្តាប់ធ្នាប់មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ការពារនិងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- លើកផែនការនិងចាត់ចែងកងកម្លាំងការពារនៅតាមគោលដៅនានាដែលបានកំណត់
- អង្កេត តាមដាន និងទប់ស្កាត់សកម្មភាពល្មើសផ្សេងៗនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឯកសារនិងបំពេញបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងបទល្មើសក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកជូនអគ្គនាយក អ.ជ.ស.ព. ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
- សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពពាក់ព័ន្ធ ដើម្បីមានវិធានការទប់ស្កាត់ចំពោះការសាងសង់ដែលគ្មានការអនុញ្ញាត ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដី ការគាស់រុករក ការលួចវត្ថុបុរាណ និងសកម្មភាពដែលបង្កឱ្យខូចខាតដល់រចនាសម្ព័ន្ធប្រាសាទនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៧ ._**

នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្សមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការមេស្តីពីការគ្រប់គ្រង អភិរក្ស និងថែទាំប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយរួមបញ្ចូលនូវបញ្ជីស្តីពីស្ថានភាពប្រាសាទ ផែនទីចង្អុលកន្លែងគ្រោះថ្នាក់ និងស្ថានភាពនៃការអភិរក្សជាដើម
- រៀបចំកម្មវិធីនិងអនុវត្តការងារអភិរក្សប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើការអង្កេតវាស់ស្ទង់និងធ្វើកំណាយបុរាណវិទ្យាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងចាត់វិធានការបង្ការឬសង្គ្រោះស្ថានីយតាមការចាំបាច់
- ស្រាវជ្រាវបេតិកភណ្ឌរូបីនិងអរូបី ព្រមទាំងចងក្រងឡើងវិញនូវស្ថានភាពដើមរបស់ចម្លាក់និងរចនាសម្ព័ន្ធប្រាសាទ
- ត្រួតពិនិត្យនិងសម្របសម្រួលលើការដ្ឋានអន្តរជាតិនៃកម្មវិធីអភិរក្សប្រាសាទនិងបុរាណវិទ្យា
- ចុះបញ្ជីសារពើភណ្ឌប្រាសាទនិងគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រួមចំណែកក្នុងការធ្វើវិក្រឹតការឬបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេស
- ផ្សព្វផ្សាយអំពីតម្លៃបេតិកភណ្ឌនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដល់ប្រជាពលរដ្ឋ
- កំណត់ទីតាំងសម្រាប់ការរៀបចំពិធីផ្សេងៗក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានា ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៨ ._**

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ពិនិត្យសំណើសុំសាងសង់និងរៀបចំលិខិតអនុញ្ញាតសាងសង់ ដោយត្រូវគោរពនូវតម្លៃបេតិកភណ្ឌនិងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានពិនិត្យការសាងសង់
- សិក្សានិងកំណត់រចនាបថនៃសំណង់ដែលអាចអនុញ្ញាតឱ្យសាងសង់នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំបែបបទធ្វើបណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លីឱ្យសមស្របជាមួយទិន្នន័យសុរិយោដី និងតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំឯកសារស្តីពីដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍន៍រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឱ្យមានមូលដ្ឋានទិន្នន័យប្រជាសាស្ត្រ ដើម្បីវិភាគ វាយតម្លៃ និងតាមដានការវិវត្តប្រជាសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- តាមដានការប្រែប្រួលកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដើម្បីបង្កើនការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- វិភាគនិងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគនិងអភិវឌ្ឍទាំងឡាយក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.

- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៩ ៈ**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍មានតួនាទីនិងភារកិច្ចដូចតទៅៈ

- កំណត់ទិសដៅនិងផែនការអភិវឌ្ឍទេសចរណ៍នៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធឱ្យស្របទៅនឹងគោលនយោបាយជាតិលើវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល
- ធ្វើស្ថិតិភ្ញៀវទេសចរដែលមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ក្នុងការរៀបចំនិងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ជំរុញផ្សព្វផ្សាយនិងសិក្សាទីផ្សារ ដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយដៃគូជាតិនិងអន្តរជាតិដែលមានជំនាញក្នុងវិស័យទេសចរណ៍
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំបណ្តុះបណ្តាល និងរិត្បិតការមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំការត្រួតពិនិត្យជាប្រចាំលើគុណភាពសេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា១០ ៈ**

នាយកដ្ឋានទេសភាពវប្បធម៌និងបរិស្ថានមានតួនាទីនិងភារកិច្ចដូចតទៅៈ

- គ្រប់គ្រងសំណល់រឹង គ្រប់គ្រងទឹក ទាំងបរិមាណនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងព្រៃឈើនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក រួមមានការអភិរក្ស ការថែទាំ ការដាំកូនឈើឡើងវិញ និងការកំណត់អត្តសញ្ញាណដើមឈើ
- សិក្សាពីរុក្ខជាតិនិងសត្វនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ការពារនិងលើកតម្លៃទេសភាពវប្បធម៌និងធម្មជាតិដែលមានទំនាក់ទំនងនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរ
- សិក្សានិងតាមដានព័ត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុនៅតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៥
## ការត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១១ៈ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១(មួយ)រូប អមអគ្គនាយកដ្ឋាន អ.ជ.ស.ព. ដោយអនុលោមតាមអនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាលខេត្ត ក្រុង និងតាមអង្គភាពស្វ័យភាពសាធារណៈ រដ្ឋបាល។

# ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជា**
**ប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋាន**
**វប្បធម៌នៃប្រាសាទសំបូរព្រៃគុក**

**ភឿង សកុណា**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៥**

**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក**

**អង្គការលេខរបស់អគ្គនាយកដ្ឋាន អ.ជ.ស.ព.**

